# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Universite Royale de Droit et des Sciences Economoiques

Royal University of Law and Economic


## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## ( ករណីសិក្សា៖ ការអភិវឌ្ឍផ្លូវក្នុងខណ្ឌពោធិ៍សែនជ័យ )

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **កញ្ញា យាន ណៃស៊ីម**

**លោក ផាន វេហា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ខួន ហេង**


ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ផាន វេហា** និង **យាន ណៃស៊ីម** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ជំនាន់ទី៨ ថ្នាក់D4A1 ឆ្នាំទី៤នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានសិក្សាស្រាវជ្រាវនៅសាលាខណ្ឌពោធិ៍សែនជ័យបានបញ្ចប់ទៅលើប្រធានបទ **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** បានយ៉ាងរលូនដែលមានការជួយជ្រោមជ្រែងពីសំណាក់មជ្ឈដ្ឋានជាច្រើន។ ហេតុនេះយើងខ្ញុំសូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

**លោកឪពុក អ្នកម្តាយ** ដែលជាអ្នកមានគុណបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា មើលការខុសត្រូវតាំងពីតូចរហូតមកដល់បច្ចុប្បន្ន លោកអ្នកមានគុណទាំងពីរបានលះបង់កម្លាំងកាយនិងចិត្ត ខិតខំប្រឹងប្រែងតស៊ូចិញ្ចឹម ផ្តល់ដំបូន្មានល្អៗ ព្រមទាំងអប់រំប្រៀនប្រដៅដោយព្រហ្មវិហារធម៌ និងតែងតែលើកទឹកចិត្តរហូតមកនេះ ហើយលោកអ្នកទាំងពីរតែងតែជម្រុញលើកទឹកចិត្តកូនឱ្យខិតខំរៀនសូត្ររហូតកូនមានថ្ងៃនេះ។

ឯកឧត្តមបណ្ឌិត**លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោកគ្រូ អ្នកគ្រូគ្រប់មហាវិទ្យាល័យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានយកចិត្តទុកដាក់ក្នុងការផ្តល់នូវចំណេះដឹង ទ្រឹស្តី និងណែនាំអស់ពីចិត្តនូវគ្រប់ជំនាញទាំងអស់មកកាន់យើងខ្ញុំ។

លោកសាស្ត្រាចារ្យជំនួយ **ងួន ហេង** ក្នុងការណែនាំធ្វើកិច្ចការស្រាវជ្រាវចុះកម្មសិក្សា និងបានព្យាយាមជួយពន្យល់ណែនាំ ត្រួតពិនិត្យ បង្ហាញនូវគំនិតល្អៗ និងឯកសារទាក់ទិនជាច្រើនដែលជួយក្នុងការចុះកម្មសិក្សានេះព្រមទាំងបានផ្តល់នូវអនុសាសន៍ល្អៗជាច្រើន និងបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការដឹកនាំ និងកែសម្រួលរបាយការណ៍កម្មសិក្សាមួយនេះរហូតបានបញ្ចប់ដោយរលូន។

លោក **សក់ ចន្ទ័កញ្ញារិទ្ធ** អភិបាលនៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ និងមន្ត្រីគ្រប់ជាន់ថ្នាក់ទាំងអស់ដែលបានខិតខំ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងបង្ហាត់បង្ហាញទាក់ទងនឹងប្រធានបទកម្មសិក្សាអោយមានភាពងាយស្រួល ជាពិសេសតែងតែសហការនិងសម្របសម្រួលដល់ដំណើរការចុះស្រាវជ្រាវឯកសារ បើទោះបីជាមានភាពមមាញឹកក្នុងការងារផ្ទាល់ខ្លួនយ៉ាងណាក្តីក៏នៅតែជួយជ្រោមជ្រែងរហូតដល់ដំណើរការស្រាវជ្រាវនេះបានបញ្ចប់យ៉ាងរលូន និងប្រកបដោយភាពជោគជ័យ។

ជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីសួស្តី ជូនដល់លោកឪពុក អ្នកម្តាយ គណៈគ្រប់គ្រងសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ សាស្ត្រាចារ្យរងសាស្ត្រាចារ្យជំនួយ លោកគ្រូ អ្នកគ្រូ លោកអភិបាលនៃគណៈអភិបាលខណ្ឌ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ សូមជួបប្រទះនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានបញ្ចប់ការសិក្សាទៅលើទ្រឹស្តីនៃមុខវិជ្ជាសេដ្ឋកិច្ចអភិវឌ្ឍន៍អស់រយៈពេលជិតបួនឆ្នាំមកនេះនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរនាក់ដោយទទួលបានភារកិច្ចពីសាលាក្នុងការចុះធ្វើកម្មសិក្សាដោយផ្ទាល់ ដើម្បីស្រាវជ្រាវចងក្រងសៀវភៅនេះឡើងក្នុងគោលបំណងចងភ្ជាប់នូវចំណេះដឹងផ្នែកទ្រឹស្តីដែលបានសិក្សាកន្លងមកនៅសាលាទៅនឹងសកម្មភាព ឬការអនុវត្តជាក់ស្តែងនូវប្រធានបទណាដែលចង់សិក្សា និងនៅតាមកន្លែងណាមួយដែលយើងគិតថាត្រូវនឹងប្រធានបទរបស់យើង។ ម្យ៉ាងវិញទៀតការអភិវឌ្ឍគឺជាទិសដៅដែលមានសារៈសំខាន់បំផុតសម្រាប់បណ្តាប្រទេសលើសកលលោក។ ទោះបីជាប្រទេសនោះប្រសិទ្ធនាមខ្លួនថាជាប្រទេសមហាអំណាចសេដ្ឋកិច្ចក៏ដោយក៏ប្រទេសនោះនៅតែកំពុងធ្វើការអភិវឌ្ឍជាជំហានៗទៀត។ ទោះបីជាប្រទេសនោះមានការអភិវឌ្ឍតិចតួចក៏ដោយក៏គេនៅតែបន្តការអភិវឌ្ឍរបស់គេឥតឈប់ឈរជាពិសេសនៅតាមបណ្តាខេត្ត និងទីជនបទនានានៃបណ្តាប្រទេសកំពុងអភិវឌ្ឍដែលក្នុងនោះរួមទាំងប្រទេសកម្ពុជាយើងផងដែរ។ ការអភិវឌ្ឍនៅប្រទេសកម្ពុជានៅមានលក្ខណៈខ្វះខាតនៅឡើយជាពិសេសនៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធដែលជាហេតុធ្វើឱ្យក្រសួងសាធារណការ និងដឹកជញ្ជូនក៏ដូចជាមន្ទីរ សាធារណការ និងដឹកជញ្ជូនបានខិតខំស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនេះរួមមាន ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ វត្តអារាម ធារាសាស្ត្រ អគ្គិសនី អាកាសយានដ្ឋានជាដើម ដើម្បីបម្រើដល់អត្ថប្រយោជន៍ប្រជាជននៅក្នុងប្រទេសកម្ពុជា។ ទោះបីជាការអភិវឌ្ឍលើវិស័យនេះមានការរីកចម្រើនក៏ដោយប៉ុន្តែនៅតែមានចំណុចខ្វះខាតដែលជាហេតុនាំឱ្យយើងខ្ញុំមានចំណាប់អារម្មណ៍លើកយកនូវប្រធានបទមួយដែលមានចំណងជើងថា «ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ករណីសិក្សា៖ ការអភិវឌ្ឍផ្លូវក្នុងខណ្ឌពោធិ៍សែនជ័យ) » យកមកសិក្សាស្រាវជ្រាវ។

យើងខ្ញុំមានអារម្មណ៍រីករាយណាស់ដែលបានចងក្រងសៀវភៅនេះឡើងទោះបីជាសៀវភៅនេះជាស្នាដៃដំបូងស្រឡាងរបស់យើងខ្ញុំក៏ពិតមែន និងមានកំហុសឆ្គងក្នុងការរៀបរៀងទាំងអក្ខរាវិរុទ្ធនិងអត្ថន័យដោយអចេតនាប៉ុន្តែយើងខ្ញុំសង្ឃឹមថាវាអាចជាអត្ថប្រយោជន៍សម្រាប់ជួយដល់មិត្តអ្នកអានព្រមទាំងនិសិត្សជំនាន់ក្រោយទុកជាឯកសារដើម្បីធ្វើការស្រាវជ្រាវបន្ថែម។ យើងខ្ញុំរីករាយនឹងទទួលនូវរាល់ការរិះគន់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការស្ថាបនា កែប្រែខ្លឹមសារឲ្យបានកាន់តែល្អ។

# មាតិកា

**ទំព័រ**


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីក្រាហ្វិក ........ vii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. វិធីសាស្ត្រស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី១
## សិក្សាលើទ្រឹស្តីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត


១.១ និយមន័យ ........ ៥

១.១.១ ការអភិវឌ្ឍ ........ ៥

១.១.២ ហេដ្ឋារចនាសម្ព័ន្ធ ........ ៥

១.១.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត័ ........ ៥

១.២ ទិសដៅនៃការអភិវឌ្ឍ ........ ៦

១.២.១ រចនាសម្ព័ន្ធសេដ្ឋកិច្ច ........ ៦

១.២.២ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ........ ៦

១.២.៣ ការងារ អប់រំ សុខាភិបាលនិងវប្បធម៌ ........ ៦

១.៣ ទ្រឹស្តីរបស់អ្នកសេដ្ឋកិច្ច ........ ៦

១.៣.១ ទ្រឹស្តីរបស់លោកម៉ាយខល ភី ថូដារ៉ូ (Michael P. Todaro) ........ ៦

១.៣.២ ទ្រឹស្តីរបស់លោករ៉ូបឺត មី ណាម៉ារ៉ា (Robert Me Namara)............................................៧
១.៣.៣ ទ្រឹស្តីរបស់លោកវ៉ល វីតមែន រ៉ូស្តូ (Walt Withman Rostow)..........................................៧
១.៣.៤ ទ្រឹស្តីប៊ីក ភូស (Big Push)..........................................................................................៩
១.៣.៥ ទ្រឹស្តីរបស់លោកហ្វ្រេនស្វា ភឺរ៉ូ (François Perroux).........................................................៩
១.៣.៦ ទ្រឹស្តីកំណើនសេដ្ឋកិច្ចរបស់ហារ៉ដ ដូម៉ារ(Harrod-Domar)..................................................៩
១.៤ កត្តាសំខាន់ៗដែលធ្វើឱ្យមានការអភិវឌ្ឍ និងជាបញ្ហាដល់ការអភិវឌ្ឍ.......................................... ១០
១.៤.១ កត្តាសំខាន់ៗដែលធ្វើឱ្យមានការអភិវឌ្ឍ........................................................................ ១០
១.៤.១.១ កត្តាធនធានធម្មជាតិ.............................................................................................. ១០
១.៤.១.២ កត្តាធនធានមនុស្ស.............................................................................................. ១១
១.៤.១.៣ កត្តាមូលធន........................................................................................................ ១១
១.៤.១.៤ កត្តាបច្ចេកវិទ្យា..................................................................................................... ១២
១.៤.១.៥ កត្តារចនាសម្ព័ន្ធ.................................................................................................. ១២
១.៤.២ កត្តាជាបញ្ហាដល់ការអភិវឌ្ឍ....................................................................................... ១៣
១.៤.២.១ ភាពក្រីក្រ.......................................................................................................... ១៣
១.៤.២.២ អត្រាកំណើនប្រជាជនខ្ពស់...................................................................................... ១៣
១.៤.២.៣ ការអប់រំទាប........................................................................................................ ១៤
១.៤.២.៤ បញ្ហានិកម្មភាព..................................................................................................... ១៤
១.៤.២.៥ កត្តានយោបាយ..................................................................................................... ១៥
១.៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល............................................................................. ១៥
១.៦ ការថែទាំខួប និងការសម្អាតផ្លូវថ្នល់..................................................................................... ១៦
១.៦.១ ការថែទាំខួប............................................................................................................. ១៦
១.៦.២ ការងារសម្អាត........................................................................................................... ១៦

## ជំពូកទី២

## ស្ថានភាពទូទៅនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅខណ្ឌពោធិ៍សែនជ័យ

២.១ ស្ថានភាពទូទៅនៅខណ្ឌពោធិ៍សែនជ័យ............................................................................. ១៧
២.១.១ ស្ថានភាពភូមិសាស្ត្រ.................................................................................................... ១៧

២.១.២ ស្ថានភាពប្រជាសាស្ត្រ ..................................................................... ១៧
២.២ រចនាសម្ព័ន្ធគ្រប់គ្រង និង តួនាទី ភារកិច្ចសមាជិកខណ្ឌ ..................................................... ១៨
២.៣ ស្ថានភាពសេដ្ឋកិច្ច ..................................................................... ១៨
២.៣.១ ការងារកសិកម្ម..................................................................... ១៩
២.៣.២ ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍..................................... ១៩
២.៣.៣ ការងារពាណិជ្ជកម្ម ..................................................................... ១៩
២.៣.៤ ការងារសាធារណការ..................................................................... ២០
២.៤ ចក្ខុវិស័យ គោលបំណង និង គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងខណ្ឌពោធិ៍សែនជ័យ......................... ២០
២.៤.១ ចក្ខុវិស័យអភិវឌ្ឍន៍..................................................................... ២០
២.៤.២ គោលបំណងអភិវឌ្ឍន៍ ..................................................................... ២០
២.៤.៣ គោលដៅអភិវឌ្ឍន៍ ..................................................................... ២១
២.៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងខណ្ឌពោធិ៍សែនជ័យ..................................................... ២១
២.៦ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌពោធិ៍សែនជ័យ (២០១៩-២០២១) ................................... ២២
២.៦.១ បណ្តាញផ្លូវ និងការជួសជុលដែលបានរួចរាល់ ..................................................... ២២
២.៦.១.១ ការងារស្តាបនា-ជួសជុលផ្លូវដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ ..................... ២២
២.៦.១.២ ការងារស្តាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ..................................... ២៥
២.៦.១.៣ ការងារជួសជុលដោយប្រើប្រាស់ថវិកាសប្បុរសជន និង ប្រជាពលរដ្ឋ ......................... ២៥
២.៦.១.៤ ការងារជួសជុលដោយប្រើប្រាស់ថវិកាមូលនិធិសង្កាត់............................................. ២៦
២.៦.២ ការជីកដាក់លូ..................................................................... ២៧
២.៦.២.១ ការងារស្តាបនា-ជួសជុលលូដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ..................... ២៧
២.៦.២.២ ការងារស្តាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ ..................................... ២៩
២.៦.២.៣ ការងារជួសជុលដោយប្រើប្រាស់ថវិកាសប្បុរសជន និង ប្រជាពលរដ្ឋ......................... ៣០
២.៦.២.៤ ការងារជួសជុលដោយប្រើប្រាស់ថវិកាមូលនិធិសង្កាត់ ............................................. ៣១
២.៦.៣ ចំនួនផ្លូវដែលបានជួសជុលពុំទាន់រួច (២០១៩-២០២១)............................................. ៣២
២.៦.៣.១ ការងារស្តាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ ......................... ៣២
២.៦.៣.២ ការងារស្តាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ ..................................... ៣២
២.៧ អត្ថប្រយោជន៍សម្រាប់ខណ្ឌពោធិ៍សែនជ័យ..................................................................... ៣៣

២.៧.១ ប្រជាពលរដ្ឋ.....................................................................................................................៣៣
២.៧.២ សេដ្ឋកិច្ច .........................................................................................................................៣៣
២.៨ បញ្ហាប្រឈមនៃការអភិវឌ្ឍ និងដំណោះស្រាយ........................................................................ ៣៤

## ជំពូកទី៣
## ការវិភាគទិន្នន័យនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១

៣.១ ទិន្នន័យផ្លូវដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១ .................................៣៨
៣.១.១ តារាងទិន្នន័យផ្លូវថ្នល់ដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១.......................................៣៨
៣.១.២ ក្រាហ្វិកផ្លូវថ្នល់ដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១...............................................៣៩
៣.១.៣ ការវិភាគនិងបកស្រាយទិន្នន័យផ្លូវថ្នល់តាមក្រាហ្វិកដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ ២០១៩ ដល់ ២០២១ ................................................................................................................ ៤០
៣.២.ទិន្នន័យលូដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១.................................៤០
៣.២.១ តារាងទិន្នន័យលូដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១ ............................................ ៤១
៣.២.២ ក្រាហ្វិកលូដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១..................................................... ៤១
៣.២.៣ ការវិភាគនិងបកស្រាយទិន្នន័យលូតាមក្រាហ្វិកដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ ២០១៩ដល់ ២០២១ ...................................................................................................................៤២

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ................................................................................................................... ៤៤
២. ការផ្តល់អនុសាសន៍ ................................................................................................................. ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

១. គ. ជ. អ. ប : គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

២. ច. ប. ផ : ចុះបញ្ជីផលិតផល

៣. ម. ម. ជ : មជ្ឈមណ្ឌលមាត្រសាស្ត្រជាតិ

៤. ស៥ : សម្រិតសម្រាំង សណ្ដាប់ធ្នាប់ សម្អាត ស្ដង់ដា ស្ថិតស្ថេរ

៥. GHP : Good Hygiene Practice

៦. NSC : National Safety Council

៧.GDP: Gross Domestic Product

៨. GNP : Gross National Product

៩. GMP : Good Manufacturing Practices

# បញ្ជីតារាង

តារាង ៣.១.១ទិន្នន័យផ្លូវដែលសម្រេចបាន១០០%ពីឆ្នាំ២០១៩ដល់២០២១ ...................................... ៣៨
តារាង ៣.២.១ទិន្នន័យលូដែលសម្រេចបាន១០០%ពីឆ្នាំ២០១៩ដល់២០២១ ..................................... ៤១

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១៖ ផ្លូវថ្នល់ដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១ ........................................................ ៣៩
ក្រាហ្វិកទី២៖ លូដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១ ............................................................... ៤២

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសបុរាណនៅឧបទ្វីបអាស៊ីអាគ្នេយ៍មានប្រវត្តិសាស្ត្រជាង២០០០ឆ្នាំមានឈ្មោះជាផ្លូវការថាព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយដែលស្ថិតនៅផ្នែកខាងត្បូងនៃឧបទ្វីបឥណ្ឌូចិនក្នុងអនុតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាមានផ្ទៃក្រឡាសរុប ១៨១,០៣៥គីឡូម៉ែត្រការ៉េដោយមានព្រំប្រទល់ជាប់នឹងប្រទេសថៃនៅភាគខាងលិចនិងពាយ័ព្យ ប្រទេសឡាវនៅភាគឦសាន្ត ប្រទេសវៀតណាមនៅភាគខាងកើត និងឈូងសមុទ្រថៃនៅភាគនិរតី។ រាជធានី និងទីក្រុងធំបំផុតក្នុងប្រទេសគឺរាជធានីភ្នំពេញ។[1]

បន្ទាប់ពីប្រទេសកម្ពុជាបានរួចផុតពីរបបប្រល័យពូជសាសន៍នៅថ្ងៃទី ៧ មករា ឆ្នាំ១៩៧៩ បានធ្វើឱ្យប្រទេសកម្ពុជាមានការផ្លាស់ប្តូរមុខមាត់របស់ខ្លួនសារជាថ្មីជាពិសេសក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិបានធ្វើឱ្យប្រទេសកម្ពុជាមានការផ្លាស់ប្តូរវិស័យសេដ្ឋកិច្ចនិងនយោបាយរួមទាំងវិស័យផ្សេងៗទៀតដូចជា វិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ទេសចរណ៍ និងគមនាគមន៍។ ម្យ៉ាងទៀត រដ្ឋាភិបាលក៏បានផ្តោតសំខាន់ទៅលើការសហការជាមួយ អង្គការ សមាគមន៍ ភ្នាក់ងារជាតិ និងអន្តរជាតិនានា ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាយើងឲ្យមានភាពរីកចម្រើនខ្លាំងដើម្បីឲ្យប្រជាជនមានឱកាសបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចដែលធ្វើឲ្យការបែងចែកមូលធនកាន់តែមានប្រសិទ្ធភាពថែមទៀតក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងរក្សានិរន្តភាពឲ្យអស់ពីលទ្ធភាពដែលខ្លួនមាន។ លើសពីនេះទៅទៀតរដ្ឋាភិបាល ក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តព្រោះវាជាមធ្យោបាយដ៏សំខាន់សម្រាប់សម្រួលដល់ជីវភាពរបស់ប្រជាជនចាប់ពីទីក្រុងរហូតដល់ជនបទដាច់ស្រយាលដូចជា ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ វត្តអារាម ប្រព័ន្ធស្រោចស្រព ទំនប់ ព្រែក ស្ទឹង អូរ ប្រឡាយទឹក និង អគ្គិសនី ។ល។

ស្របពេលជាមួយគ្នានេះដែរ ខណ្ឌពោធិ៍សែនជ័យជាស្ថាប័នមួយដែលបានប្រឹងប្រែងអនុវត្តន៍តាមកម្មវិធីនយោបាយរបស់រដ្ឋាភិបាលដោយមានការចូលរួមយ៉ាងសកម្មពីបណ្តាភូមិ សង្កាត់ មន្ទីរនានា អង្គភាពកងប្រដាប់អាវុធ អង្គការជាតិ និងអន្តរជាតិ សប្បុរសជន ប្រជាពលរដ្ឋដែលបានធ្វើការអភិវឌ្ឍទាំងអស់គ្នាលើគ្រប់វិស័យនានាដើម្បីរួមចំណែកជួយស្តាបនាសេដ្ឋកិច្ចប្រទេសកម្ពុជាឲ្យរីកចម្រើនឡើង។ ម៉្យាងវិញទៀតក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសនេះសាលាខណ្ឌពោធិ៍សែនជ័យបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ និងអនុវត្តន៍គោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាលដើម្បីលើកតម្កើនកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ។

[1] Wikipedia

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រជាជន។ យ៉ាងណាមិញទោះបីជាស្ថិតនៅក្នុងគោលដៅនៃការអភិវឌ្ឍរបស់រដ្ឋាភិបាលក៏ដោយក៏សាលាខណ្ឌពោធិ៍សែនជ័យនៅតែត្រូវការការសាងសង់ និងជួសជុលបន្ថែមទៅលើប្រព័ន្ធផ្លូវថ្នល់ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ដូច្នេះហើយ តើដំណោះស្រាយ ឬ ផែនការបែបណាដែលមានប្រសិទ្ធភាពចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងខណ្ឌពោធិ៍សែនជ័យ? សំណេរដែលបានលើកឡើងខាងលើនេះនឹងត្រូវពន្យល់បកស្រាយក្រោមប្រធានបទ “**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**” ករណីការអភិវឌ្ឍផ្លូវក្នុងខណ្ឌពោធិ៍សែនជ័យ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងខណ្ឌពោធិ៍សែនជ័យ និងចង់រុករករបកគំហើញនៃការស្រាវជ្រាវមួយដែលមានសារប្រយោជន៍អាចយកលទ្ធផលទៅប្រើប្រាស់ជួយដោះស្រាយបញ្ហានានាជុំវិញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងខណ្ឌ។ ម្យ៉ាងវិញទៀតយើងខ្ញុំក៏ចង់សិក្សាបន្ថែមអំពីស្ថានភាពនៃគម្រោងការអភិវឌ្ឍរបស់ខណ្ឌក៏ដូចជាសមិទ្ធផលដែលបានមកពីគម្រោងផងដែរ។ កម្មវត្ថុនៃការសិក្សាស្រាវជ្រាវនេះមានទាក់ទងនឹងចំណុចសំខាន់ៗដូចខាងក្រោម៖

- ការសិក្សាលើទ្រឹស្តីរបស់អ្នកប្រាជ្ញ
- ការសិក្សាពីស្ថានភាពអភិវឌ្ឍន៍របស់ខណ្ឌពោធិ៍សែនជ័យ
- ការសិក្សាពីការលំបាកទៅលើការអភិវឌ្ឍរបស់ខណ្ឌ
- បទពិសោធន៍នៃដំណោះស្រាយរបស់ខណ្ឌទៅលើបញ្ហាលំបាកដែលកើតមាន។

បន្ទាប់មកទៀតក្រុមយើងខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានអំពីលទ្ធផលដែលបានរកឃើញ រួមទាំងធ្វើការវិភាគ និងបកស្រាយលើសមិទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ។ ជាចុងបញ្ចប់យើងនឹងផ្តល់ជាអនុសាសន៍ចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងខណ្ឌពោធិ៍សែនជ័យ។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅក្នុងខណ្ឌពោធិ៍សែនជ័យទទួលបានសមិទ្ធផលជាច្រើនសម្រាប់បម្រើជូនដល់ប្រជាជនចាប់តាំងពីការកកើតខណ្ឌដំបូងបន្តិចម្តងៗរហូតមានផ្លូវថ្នល់ខ្វាត់ខ្វែង ប្រព័ន្ធធារាសាស្ត្រដូចសព្វថ្ងៃនេះ ប៉ុន្តែក្នុងសារណានេះយើងខ្ញុំសិក្សាស្រាវជ្រាវតែទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ និងលូនៅក្នុងខណ្ឌចាប់ពីឆ្នាំ២០១៩ ដល់ ២០២៤ តែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីអោយការស្រាវជ្រាវនេះទទួលបានលទ្ធផលល្អក៏ដូចជាទុកជាឯកសារដល់និស្សិតនិងមិត្តអ្នកអានជំនាន់ក្រោយបានស្វែងយល់បន្ថែមក្នុងការសិក្សាស្រាវជ្រាវក្រុមរបស់យើងខ្ញុំបានបែងចែកប្រភពទិន្នន័យជាពីរប្រភេទគឺ៖

**ទិន្នន័យចម្បង** គឺជាទិន្នន័យដែលយើងទទួលបានពីការសម្ភាសន៍ផ្ទាល់ជាមួយថ្នាក់ដឹកនាំខណ្ឌព្រមទាំងការិយាល័យដែលពាក់ពន្ធ័ដទៃទៀតក្នុងខណ្ឌពោធិ៍សែនជ័យ។

**ទិន្នន័យបន្ទាប់បន្សំ** ជាប្រភេទទិន្នន័យដែលមានស្រាប់ដូចជាសៀវភៅសិក្សាពីទ្រឹស្តីអភិវឌ្ឍន៍របស់អ្នកសេដ្ឋកិច្ច សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងមួយចំនួនទៀតបានមកពីរបាយការណ៍លទ្ធផលការងារក្នុងរយៈពេលមួយឆ្នាំ ២០១៩ ២០២០ ២០២១ របស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះមានសារៈសំខាន់ដូចជា៖

- ផ្សារភ្ជាប់ទ្រឹស្តីដែលបានសិក្សាកន្លងមកទៅនឹងការអនុវត្តជាក់ស្តែង
- ស្គាល់ពីដំណើរការនៃការអភិវឌ្ឍផ្លូវ វិធីសាស្ត្រនៃការជួសជុល និង ថែទាំផ្លូវរបស់ខណ្ឌ
- ស្វែងយល់ពីបញ្ហាលំបាក និងដំណោះស្រាយដែលកើតមានឡើងតាមរយៈការអនុវត្តពីមុនដើម្បីជៀសវាងនៅក្នុងគម្រោងលើកក្រោយ និងដើម្បីកាត់បន្ថយភាពក្រីក្រ
- ទុកជាឯកសារយោងសម្រាប់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិតជំនាន់ក្រោយក្នុងការបង្កើនចំណេះដឹង
- ជាឯកសារសម្រាប់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ក្រុមយើងខ្ញុំ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំកាន់តែមានភាពងាយស្រួល យើងខ្ញុំបានបែងចែកចេញជាបីជំពូកធំៗដូចខាងក្រោម៖

- **សេចក្តីផ្តើម**: រួមមានលំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- **ជំពូកទី១**: ការសិក្សាលើទ្រឹស្តីជាមូលដ្ឋានដោយលើកឡើងអំពីទ្រឹស្តីមួយចំនួនដែលបានសិក្សារយៈពេលបួនឆ្នាំកន្លងមកទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ទ្រឹស្តីរបស់អ្នកសេដ្ឋកិច្ច។

- **ជំពូកទី២**: ស្ថានភាពទូទៅរបស់ខណ្ឌពោធិ៍សែនជ័យដែលលើកឡើងពីទីតាំងភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌពោធិ៍សែនជ័យ។

- **ជំពូកទី៣**: ការវិភាគទិន្នន័យនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលខណ្ឌពោធិ៍សែនជ័យសម្រេចបាន។

- **សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**: យើងខ្ញុំនឹងធ្វើការវិភាគ និងសំយោគនូវរាល់ចំណុចសំខាន់ៗដែលបានមកពីការស្រាវជ្រាវ និងផ្តល់យោបល់របស់ក្រុមយើងខ្ញុំជាអនុសាស៍ដើម្បីឲ្យខណ្ឌមានការរីកចម្រើនទៅមុខបន្ថែមទៀត។

# ជំពូកទី១

# សិក្សាលើទ្រឹស្តីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូប
# វន្ត័

# ជំពូកទី១
# សិក្សាលើទ្រឹស្តីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

## ១.១.និយមន័យ

### ១.១.១.ការអភិវឌ្ឍ

ពាក្យអភិវឌ្ឍមានអត្ថន័យផ្សេងៗគ្នាទៅតាមន័យនិងទស្សនៈរបស់អ្នកប្រាជ្ញដែលបានរកឃើញនិងផ្លាស់ប្តូរអត្ថន័យទៅតាមការវិវត្តពីសម័យកាលមួយទៅសម័យកាលមួយទៀតដោយមានលក្ខណៈប្រហាក់ប្រហែលគ្នាប៉ុន្តែនៅរក្សានូវទិសដៅតែមួយ។ ដោយយោងតាមអក្សរសិល្ប៍ខ្មែរផ្អែកលើវចនានុក្រមដែលបានចងក្រងឡើងដោយសម្តេចជួន ណាត ពាក្យអភិវឌ្ឍ មានន័យថាសេចក្តីរីកចម្រើនក្រៃលែង ការលូតលាស់ចម្រើនឡើង។ការអភិវឌ្ឍតាមបែបសម័យទំនើបយល់ឃើញថាការអភិវឌ្ឍជាការធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត និងជីវភាពរបស់ប្រជាជនដូចជា លទ្ធភាពទទួលបានការអប់រំ ទឹកស្អាត ខ្យល់ស្អាត ការគាំពារសុខភាព ឱកាសការងារ និងគ្មានការគំរាមកំហែងពីឧក្រិដ្ឋកម្ម។

### ១.១.២.ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ គឺជាមធ្យោបាយ និងទំនាក់ទំនងផលិតកម្មដែលជាមូលដ្ឋាននៃសង្គមដូចជា ផ្លូវ ស្ពាន ព្រែក ព្រលានយន្តហោះ រោងចក្រអគ្គិសនី។

មួយវិញទៀតគឺជាពាក្យបច្ចេកទេសមួយដែលប្រើសម្រាប់រៀបរាប់អំពីមធ្យោបាយក៏ដូចជាគ្រឿងប្រដាប់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅសម័យទំនើបរបស់មនុស្សយើង។ ក្នុងនោះមានដូចជាបណ្តាញទឹក គេហដ្ឋាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ព្រលានយន្តហោះ អគាររដ្ឋាភិបាល ស្ពាន ផ្លូវដែក និងពាណិជ្ជកម្ម។ល។ ហើយហេដ្ឋារចនាសម្ព័ន្ធមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយស្តង់ដារនៃការរស់នៅនិងចំនួនប្រជាជនដ៏ច្រើន។ពេលដែលចំនួនប្រជាជនកើនទ្វេរចនាសម្ព័ន្ធក៏ត្រូវការកើនឡើងទ្វេដងដូចគ្នាដែរ ឬអាចលើសពីនេះ។ ប្រសិនបើប្រទេសនោះជាប្រទេសក្រីក្រហើយមានចំនួនប្រជាជនខ្ពស់រដ្ឋាភិបាលនឹងមិនអាចផ្តល់នូវតម្រូវការនៃរចនាសម្ព័ន្ធគ្រប់គ្រាន់នោះទេ។ ដូចនេះស្តង់ដារនៃការរស់នៅនឹងមានការធ្លាក់ចុះហើយអាចមានហានិភ័យខ្ពស់ជាងនេះ។

### ១.១.៣.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានគេមើលឃើញថាជាមធ្យោបាយដើម្បីធ្វើឲ្យប្រសើរឡើងនូវដំណើរការទំនិញ និងសេវាកម្មរបស់ប្រជាពលរដ្ឋនៅក្នុងការប្រកបរបរចិញ្ចឹមជីវិតហើយវាក៏ជាមធ្យោបាយមួយដើម្បីកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងនេះផងដែរលំនាំនៃការទទួលខុសត្រូវ និងសិទ្ធិអំណាចគឺពិតជាសំខាន់សម្រាប់ធ្វើការសម្រេចចិត្តក្នុងតំបន់និងការអភិវឌ្ឍអភិបាលកិច្ចល្អហើយការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនេះគឺជាគន្លឹះក្នុងការបង្កើនអានុភាពយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ម្យ៉ាងវិញទៀតការទទួលខុសត្រូវសម្រាប់

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវបានគេយកចិត្តទុកដាក់កាន់តែខ្លាំងឡើងនៅក្នុងការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់តំបន់។នេះគឺជាការបង្ហាញពីឱកាសដ៏ល្អបំផុតដើម្បីបង្កើនការពឹងផ្អែកលើធនធានក្នុងស្រុក ការខិតខំរបស់ប្រជាជនដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងដើម្បីបង្កើនការងារក្នុងស្រុក។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំដៅលើសំណុំហេដ្ឋារចនាសម្ព័ន្ធដែលរាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធប្រើប្រាស់សម្រាប់បម្រើវិស័យគមនាគមន៍ ថាមពល ទឹកស្អាត កាកសំណល់រឹងនិងរាវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។

## **១.២.ទិសដៅនៃការអភិវឌ្ឍ**

### **១.២.១.រចនាសម្ព័ន្ធសេដ្ឋកិច្ច**

បញ្ជាក់ពីសក្តានុពលនៅតាមតំបន់ និងបង្កើតបាននូវសមាមាត្រឧស្សាហកម្មនានាដើម្បីឲ្យប្រជាជនមានការងារធ្វើ កំណត់បាននូវទិសដៅអភិវឌ្ឍន៍ក្នុងការលើកស្ទួយជីវភាពគ្រួសារ និងបញ្ជាក់ពីកំណើនវិស័យផ្សេងៗនៅតាមតំបន់នោះ។

### **១.២.២.ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ**

ប្រព័ន្ធនេះ គឺជាមូលដ្ឋានចម្បងមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈប្រព័ន្ធគមនាគមន៍ ធារាសាស្ត្រ អគ្គិសនី ប្រព័ន្ធទឹកស្អាត ផ្ទះសម្បែង ទំនាក់ទំនងព័ត៌មាន និងមជ្ឈមណ្ឌលវប្បធម៌ សុខុមាលភាពសង្គមផ្សេងៗ។

### **១.២.៣.ការងារ អប់រំ សុខាភិបាលនិងវប្បធម៌**

អភិវឌ្ឍន៍វិស័យអប់រំឲ្យខ្លាំងក្លានៅតាមគ្រប់តំបន់ និងពង្រីកបណ្តាញសុខាភិបាលឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីបម្រើទៅដល់តម្រូវការរបស់ប្រជាពលរដ្ឋ។ ពង្រឹង និងពង្រីកបណ្តាញវប្បធម៌តាមរយៈវិទ្យុផ្សាយផ្ទាំងផ្សព្វផ្សាយនៅតាមផ្លូវ។ល។

## **១.៣. ទ្រឹស្តីរបស់អ្នកសេដ្ឋកិច្ច**

### **១.៣.១.ទ្រឹស្តីរបស់លោកម៉ាយខល ភី ថូដារ៉ូ** (Michael P. Todaro)

តាមទ្រឹស្តីរបស់សេដ្ឋវិទូលោក Michael P. TODARO ដើម្បីឲ្យមានកំណើនសេដ្ឋកិច្ចចាំបាច់បំផុតត្រូវមានកត្តាសំខាន់បីយ៉ាងដូចខាងក្រោម៖

$Y= f(L,K,A)$

- ការកើនឡើងនៃមូលធនរួមបញ្ចូលទាំងការវិនិយោគថ្មីៗទាំងឡាយលើដីធ្លីសំភារៈបរិក្ខារ និងធនធានមនុស្ស។
- ការកើនឡើងចំនួនប្រជាជនដែលនាំឲ្យមានកំណើនកម្លាំងពលកម្មជាយថាហេតុ។

➢ ភាពជឿនលឿននៃបច្ចេកទេស[2]។

**១.៣.២. ទ្រឹស្តីរបស់លោករ៉ូប៊ឺត មី ណាម៉ារ៉ា** ( Robert Me Namara )

លោក Robert Me Namara បានពន្យល់ថា ការអភិវឌ្ឍគឺជាការផ្តល់នូវសេចក្តីត្រូវការរបស់មនុស្សជាមូលដ្ឋានពិសេសអ្នកទីទាល់ក្រ។ សេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្សរួមមានចំណីអាហារអាហារូបត្ថម្ភគ្រប់គ្រាន់ ជៀសវាងនូវការទទួលទានមិនគ្រប់គ្រាន់ដែលនាំឲ្យមានឥទ្ធិពលអវិជ្ជមានដល់ការរស់នៅប្រចាំថ្ងៃ។ ទីជម្រក សម្លៀកបំពាក់ គឺសម្រាប់ការពារជីវិត និងសម្រាប់ទប់ទល់នឹងអាកាសធាតុ និងបរិស្ថានផ្សេងៗ។ សេវាកម្មសាធារណៈសមស្របបម្រើដល់ការអប់រំទឹកស្អាត និង ការថែទាំសុខភាពដែលផ្តល់ផលប្រយោជន៍ច្រើនដល់មនុស្សជាតិគ្រប់ៗគ្នា និងសមាជិកក្នុងតំបន់អភិវឌ្ឍន៍របស់ពួកគេ។

សរុបសេចក្តីមកការអភិវឌ្ឍសំដៅទៅលើការកែលម្អជីវភាពរស់នៅរួមមានប្រាក់ចំណូល សកម្មភាពផលិតកម្ម ការអប់រំ អាហារូបត្ថម្ភ សុខភាព ជម្រក និងសេវាកម្មរស់នៅយូរអង្វែងព្រមជាមួយសុខុមាលភាពនៃសង្គមផ្សេងៗ។ រីឯកត្តាដែលជះឥទ្ធិពលដល់ការកែលម្អកម្រិតសុខុមាលភាពគឺមិនត្រឹមតែគិតពីប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវរាប់បញ្ចូលទាំងសន្តិសុខក្នុងការផ្គត់ផ្គង់ស្បៀង ផ្តល់ការអប់រំតាមតម្រូវការផ្តល់សេវាសុខភាពបានគ្រប់គ្រាន់ ទឹកស្អាត ផ្លូវលំ ឥណទាន និងផ្នែកផ្សេងៗទៀតដែលចាំបាច់។[3]

**១.៣.៣ ទ្រឹស្តីរបស់លោកវ៉ល វីតមែន រ៉ូស្តូ** ( Walt Withman Rostow )

លោក W.W. Rostow បានវែកញែកដំណាក់កាលសំខាន់ៗរបស់រចនាសម្ព័ន្ធនៅក្នុងការអភិវឌ្ឍជា៥ដំណាក់កាល ដោយលោកបានអះអាងថាគ្រប់ប្រជាជាតិអាចឈានដល់កម្រិតអភិវឌ្ឍន៍ ប្រសិនបើគេដើរតាមគន្លងប្រទេសអភិវឌ្ឍ ហើយរក្សាលក្ខណៈក្នុងការធានាឲ្យមានកំណើនសេដ្ឋកិច្ចបានយូរអង្វែង។ ទ្រឹស្តីនេះបានចែកចេញជាប្រាំដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍ៖

- ដំណាក់កាលទី១ សង្គមប្រពៃណី៖ គឺជាសង្គមដែលគ្មានកំណើនទាស់តែសោះ ហើយការផលិតធ្វើឡើងតែរៀងៗខ្លួន ដូច្នេះផលដែលទទួលបានមានកម្រិតទាប។ ប្រជាជនយករបរកសិកម្មជាវិស័យចម្បងក្នុងការផលិត ហើយពួកគេគ្មានគំនិតក្នុងការផ្លាស់ប្តូរអ្វីទាំងអស់គឺបណ្តោយតាមយថាកម្ម។
- ដំណាក់កាលទី២ លក្ខណៈដែលធ្វើឲ្យមានការអភិវឌ្ឍ៖ វានឹងទៅដល់ការរួមបញ្ចូលឥទ្ធិពលពិតប្រាកដដែលធ្វើឲ្យមានផលចំណេញសង្គម ហើយការផ្លាស់ប្តូរនេះត្រូវបានដាក់ចេញមានដូចជា ការពង្រីកហេ

[2] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តស្វាយរៀង របស់និស្សិត ឡាយ សុវណ្ណ និង ហោ សាងសាង ឆ្នាំ២០១៣ ទំព័រទី ១៧

[3] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត អ៊ឹង ហ្គេចលី និង ឡេង វួចនា ឆ្នាំ២០១៩ ទំព័រទី ៩

ដ្ឋារចនាសម្ព័ន្ធ ការធ្វើឲ្យមានការកើនឡើងនូវបច្ចេកវិទ្យា និងការធ្វើឲ្យប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុព្រមទាំងធ្វើឲ្យកើនឡើងនៃសន្សំ និងវិនិយោគ។

- ដំណាក់កាលទី៣ដំណាក់កាលនៃការកើនឡើងនៃការអភិវឌ្ឍ៖ រួមមានវិស័យអាទិភាពនៃសេដ្ឋកិច្ចបានចាប់កំណើត និងរីកធំធាត់ជាលំដាប់ កំណើនសេដ្ឋកិច្ចក្លាយជាបញ្ហាសាមញ្ញ អាចរក្សាបានដោយស្វ័យប្រវត្តិនូវស្ថេរភាពដល់សេដ្ឋកិច្ច។ ប្រសិនបើប្រទេសណាមានលក្ខណៈដូចខាងលើប្រទេសនោះត្រូវបានគេចាត់ទុកថាជាឧស្សាហកម្មថ្មីដោយពឹងផ្អែកលើភាពខ្លាំងក្លានៃអត្រាវិនិយោគ អាទិភាពនៃនយោបាយស្ថាប័នដែលនាំឲ្យមានការរំកិលនៃកំណើនសេដ្ឋកិច្ច និងការបង្កើតនូវឧស្សាហកម្មសំខាន់ៗដើម្បីជាការផ្លាស់ប្តូរ។
- ដំណាក់កាលទី៤ ដំណាក់កាលទុំ៖ ការអភិវឌ្ឍបានចូលទៅគ្រប់ច្រកល្ហកនៅទូទាំងប្រទេសជាពិសេសគឺវិស័យថ្មីៗនៃផលិតកម្មនៃការលេចឡើងជារចនាសម្ព័ន្ធនៃការផលិតបានចេញជាវិស័យកសិកម្ម និងឧស្សាហកម្ម។ ការអភិវឌ្ឍចេះតែឈានទៅមុខ ឧស្សាហកម្មដែលមានវិស័យចំណាស់ត្រូវបានផ្លាស់ប្តូរចេញឲ្យវាកាន់តែមានភាពទំនើបថែមទៀត ឬវិស័យឧស្សាហកម្មថ្មី។
- ដំណាក់កាលទី៥ដំណាក់កាលនៃបម្រើបម្រាស់នៃទ្រង់ទ្រាយធំ៖ ការផលិតទំនិញនិងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ ត្រូវបានធ្វើនៅក្នុងវិស័យឧស្សាហកម្មនៃការផលិតទំនិញ។ ដោយសារតែប្រាក់ចំណូលរបស់ប្រជាជនមានការរីកចម្រើនបានអនុញ្ញាតឲ្យមានការប្រើប្រាស់ក្នុងទ្រង់ទ្រាយធំនៃទំនិញដែលមានភាពចាំបាច់។ នៅក្នុងចំណុចនេះគឺគេអាចនិយាយបានថាការអភិវឌ្ឍកំពុងចាប់ផ្តើមដំណើរការខ្លាំងព្រោះថាត្រង់ចំណុចកើនឡើងធ្វើឲ្យ៖

❖ សេចក្តីត្រូវការជាមូលដ្ឋានត្រូវបានគេដោះស្រាយជាស្ថាពរ
❖ មានការរីកចម្រើនលើវិស័យសុខុមាលភាពក្នុងសង្គម
❖ អំណាចសេដ្ឋកិច្ចត្រូវបានពង្រីក។

លោក W.W. Rostow បានយកចិត្តទុកដាក់ខ្លាំងលើការរីកសាយភាយនៃគ្រឿងយន្តដែលមានតម្លៃថោកដែលធ្វើឲ្យមានឥទ្ធិពលជីវិតនៃសង្គម ការបែងចែកប្រាក់ចំណូលថ្មី និងបង្កើតប្រព័ន្ធគម្រោងទុកនៃសង្គម។[4]

[4] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តស្វាយរៀង របស់និស្សិត ឡាយ សុវណ្ណា និង ហោ សាងសាង ឆ្នាំ២០១៣ ទំព័រទី ១៣-១៤

**១.៣.៤. ទ្រឹស្តីប៊ីក ភូស** ( Big Push )

អ្នកដែលបង្កើតទ្រឹស្តីនេះឡើងគឺលោក Paul Rosenstein-Rodan នៅក្នុងឆ្នាំ ១៩៤៣ បន្ទាប់មកនៅឆ្នាំ ១៩៨៩ លោក Murphy និង Robert W. Vishny បានយកម៉ូដែលសេដ្ឋកិច្ចនេះមកវិភាគនៅក្នុងទ្រឹស្តីល្បែង (Game Theory) ទៀតផង។

Big Push គឺជាទ្រឹស្តីដែលបង្ហាញអំពីកត្តាដែលធ្វើឲ្យប្រទេសនីមួយៗមានកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើននូវវិនិយោគឲ្យកាន់តែច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអប់រំរួមផ្សំនឹងការវិនិយោគជាលក្ខណៈឯកជន វានឹងអាចធ្វើឲ្យកើនឡើងនូវផលិតភាពក្នុងការផលិតទំនិញ និងសេវា។

ហើយទ្រឹស្តី Big Push នេះក៏ជាទ្រឹស្តីមួយនៅក្នុងសេដ្ឋកិច្ចអភិវឌ្ឍន៍ឬសេដ្ឋកិច្ចទីផ្សារសេរីដែលនឹងផ្តោតសំខាន់ទៅលើការសម្រេចចិត្តរបស់សហគ្រាស ឬក្រុមហ៊ុនមុននឹងធ្វើអ្វីមួយ ឬក៏មិនធ្វើវាមិនអាស្រ័យលើការសម្រេចចិត្តរបស់សហគ្រាស ឬក្រុមហ៊ុនផ្សេងទេ។ នៅពេលដែលសហគ្រាស ឬក្រុមហ៊ុនទាំងនោះរំពឹងទុកនឹងទទួលបានផលចំណេញពួកគេនឹងធ្វើសកម្មភាពអាជីវកម្ម និងឧស្សាហកម្មរបស់ពួកគេ។[5]

**១.៣.៥. ទ្រឹស្តីរបស់លោកហ្វ្រេនស្វា ភឺរ៉ូ** ( François Perroux )

លោកបានឲ្យនិយមន័យនៃការអភិវឌ្ឍ គឺជាការចូលរួមផ្សំនៃការផ្លាស់ប្តូរគំនិត និងសង្គមរបស់ប្រជាជនមួយក្រុមដែលការផ្សំនោះផ្តល់មកវិញនូវកំណើនផ្ទួនៗ និងភាពស្ថិតស្ថេរនៃផលិតផលសរុបពិតរបស់ពួកគេ។ លោកបានធ្វើការបែងចែករវាងការអភិវឌ្ឍ និងសញ្ញាណផ្សេងៗទៀតដែលជានិច្ចកាលវាបានចូលរួមក្នុងការពង្រីកការកើនឡើង និងការអនុវត្ត។ [6]

**១.៣.៦. ទ្រឹស្តីកំណើនសេដ្ឋកិច្ចរបស់ហារ៉ដ ដូម៉ារ** ( Harrod-Domar )

គំរូនេះយកចិត្តទុកដាក់ជាសំខាន់ទៅលើសន្សំ គឺថាគ្រប់សេដ្ឋកិច្ចត្រូវតែមានសន្សំដោយសមាមាត្រពិតប្រាកដ និងចំណូលជាតិ ក្នុងករណីដែលមានការផ្លាស់ប្តូរទំនិញមូលធនហួសសម័យ ឬការរំលស់ដូចជាអាគារ និងសម្ភារៈផ្សេងៗ។ ដើម្បីឲ្យមានកំណើនសេដ្ឋកិច្ច គឺត្រូវតែមានការវិនិយោគថ្មីសុទ្ធដែលបន្ថែមទៅលើស្តុកមូលធន (K) និង GDP សរុបមានន័យថាគេនឹងយកមួយភាគនៃGDPតាមរយៈការសន្សំទៅធ្វើវិនិយោគថ្មីដើម្បីវិនិយោគទៅលើស្តុកមូលធន។

គំរូលោក Harrod-Domar ចែកចេញជាបីដំណាក់កាលដើម្បីបង្ហាញពីទំនាក់ទំនងនៃកំណើនសេដ្ឋកិច្ចគឺ៖

១.ទំនាក់ទំនងរវាងសន្សំ និងចំណូលសរុប

---

[5] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត អ៊ឹង ហ្គេចលី និង ឡេង វួចនា ឆ្នាំ២០១៩ ទំព័រទី ១១-១២

[6] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត អ៊ឹង ហ្គេចលី និង ឡេង វួចនា ឆ្នាំ២០១៩ ទំព័រទី ១២

S $= s.Y \Rightarrow s = \frac{S}{Y}$ផលធៀបនេះឈ្មោះថាផលធៀបនៃការសន្សំ

២.ទំនាក់ទំនងរវាងការវិនិយោគ និងបំរែបំរួលស្តុកមូលធន

I =Δ K

$\frac{K}{Y} = k$ ជាផលធៀបផលិតផលមូលធន។ ផលធៀបនេះប្រាប់ K ថាតើគេអាចរកចំណូលបានប៉ុន្មាន?

$\Rightarrow \Delta K = k.\Delta Y$

៣.សន្សំជាតិសរុបត្រូវតែស្មើនឹងវិនិយោគសរុប

$$I=S, I=\Delta K, S = s.Y, \Delta K = k.\Delta Y$$
$$\Rightarrow s.Y = k.\Delta Y$$
$$\frac{\Delta Y}{Y} = \frac{s}{k}$$

( $\frac{\Delta Y}{Y}$ ជាអត្រាកំណើនGDP គិតជាភាគរយ)

ក្នុងគំរូរបស់លោក Harrod-Domar គឺយើងអាចឃើញកំណើនGDPដោយប្រកាន់យកតែ s ធៀបនឹង k តែប៉ុណ្ណោះ។ តាមមតិសេដ្ឋវិទូទាំងពីរគន្លឹះនៃការអភិវឌ្ឍគឺស្ថិតនៅលើការចេះកៀងគរធនធានក្នុងស្រុក និងក្រៅស្រុកសម្រាប់យកមកវិនិយោគ។ តាមន័យនេះដើម្បីទទួលបានការអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចត្រូវការនូវការសន្សំ និងវិនិយោគតាមសមាមាត្រមួយជាកំណត់ធៀបទៅនឹង GNP ឬ GDP។ កម្រិតនៃការសន្សំ និងការវិនិយោគកាន់តែខ្ពស់បានន័យថាមានអត្រាកំណើនកាន់តែខ្ពស់ហើយអត្រាកំណើនកាន់តែខ្ពស់គឺមានន័យថាមានការអភិវឌ្ឍកាន់តែខ្ពស់ដែរ។[7]

## ១. ៤ កត្តាសំខាន់ៗដែលធ្វើឱ្យមានការអភិវឌ្ឍ និងជាបញ្ហាដល់ការអភិវឌ្ឍ

### ១.៤.១ កត្តាសំខាន់ៗដែលធ្វើឱ្យមានការអភិវឌ្ឍ

បើយោងតាមការសិក្សាស្រាវជ្រាវទៅលើទស្សនៈវិទូជាច្រើនយើងឃើញថា តួនាទីពលកម្ម និងមូលធនជាស្នូលដែលជម្រុញឲ្យមានការអភិវឌ្ឍ។ ក៏ប៉ុន្តែក្រៅពីកត្តាទាំងពីរខាងលើនេះដំបូងគេចាប់អារម្មណ៍ទៅលើកត្តាធនធានធម្មជាតិដែលជាកត្តាសំខាន់តែមួយក្នុងការអភិវឌ្ឍដោយផ្អែកលើពេលវេលានិងការរកឃើញថ្មីៗដទៃទៀតដូចជាកត្តារចនាសម្ព័ន្ធជាដើម។ យោងតាមអ្នកសេដ្ឋវិទូបានកំណត់ថាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចអោយរីកចម្រើនមិនថាប្រទេសអ្នកមានឬអ្នកក្រគឺត្រូវមានកត្តា ៤យ៉ាងសំខាន់គឺ៖

#### ១.៤.១.១. កត្តាធនធានធម្មជាតិ

ធនធានធម្មជាតិគឺជាធនធានដែលកើតឡើងដោយឯកឯងដែលមានប្រភពមកពីលើអាកាស លើដីក្រោមដី និងក្នុងទឹកជាដើម។ ធនធានធម្មជាតិជាធាតុផ្សំសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ីដែលផ្តល់ជាទ្រព្យសម្បត្តិ

[7] របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តស្វាយរៀង របស់និស្សិត ឡាយ សុវណ្ណ និង ហោសាងសាង ឆ្នាំ២០១៣ ទំព័រទី ១៥-១៦

និងសេវាកម្មក្នុងការប្រើប្រាស់ដើម្បីបំពេញសេចក្តីត្រូវការដល់គ្រប់សភាវៈដែលមានជីវិតទាំងអស់រួមទាំងការចិញ្ចឹមជីវិតរស់នៅរបស់មនុស្សជាតិផងដែរ។ ធនធានធម្មជាតិជាធនធានដែលមានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍវិស័យកសិកម្ម និង ឧស្សាហកម្មដែលត្រូវបានគេទាញយកមកកែច្នៃដើម្បីផលិតនូវផលិតផលសម្រេចនានាដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូររបស់មនុស្ស និង សម្ភារៈ ។ល។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍគេប្រើធនធានទាំងនេះដើម្បីទ្រទ្រង់ជីវភាពក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវគុណភាពរស់នៅហើយធនធានដែលមានតម្លៃជាងគេគឺដីដែលអាចដាំដុះបានព្រោះភាគច្រើននៃប្រជាជនដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍប្រកបរបរធ្វើស្រែចំការដែលអាស្រ័យដោយផ្ទាល់ទៅលើដី។

**១.៤.១.២កត្តាធនធានមនុស្ស**

អ្នកសេដ្ឋកិច្ចបានយល់ឃើញថាធនធានមនុស្សគឺជាអ្នកកំណត់នូវអត្តចរិកលក្ខណៈសេដ្ឋកិច្ចសង្គមវប្បធម៌របស់ប្រទេសមួយដើម្បីឈានទៅរកការអភិវឌ្ឍផងដែរ។ ធនធានមនុស្សជាមនុស្សដែលពេញលេញបរិបូណ៌ដោយចំណេះដឹង និងការបណ្តុះបណ្តាលជាប្រភពសម្រាប់កសាងប្រទេសជាតិ។ យ៉ាងណាមិញលោកសាស្ត្រាចារ្យ Fredirick Harbison ដែលបង្រៀននៅសាកលវិទ្យាល័យ Princetion បានអះអាងថាធនធានមនុស្សគឺជាមូលដ្ឋានកំណត់យ៉ាងខ្ពស់បំផុតនូវទ្រព្យសម្បត្តិរបស់ជាតិមួយមនុស្សរស់នៅត្រូវតែសកម្មក្នុងការអភិវឌ្ឍដូចជាការបង្គុន ការទាញយកផលប្រយោជន៍ពីធនធានធម្មជាតិ ការថែរក្សាធនធានធម្មជាតិ កសាងសង្គមសេដ្ឋកិច្ច និង នយោបាយ។ ជាការពិតណាស់ប្រទេសមួយដែលមិនអាចបង្កើតជំនាញ និងចំណេះដឹងដល់ប្រជាពលរដ្ឋរបស់ខ្លួននឹងមិនអាចប្រើប្រាស់ពន្ធគយឱ្យមានប្រសិទ្ធភាពក្នុងសេដ្ឋកិច្ចជាតិនោះវាមិនអាចអភិវឌ្ឍន៍បានឡើយ។ ធនធានមនុស្សមានតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍដែលស្ថិតក្នុងគោលបំណងដើម្បីមនុស្សនិងសង្គមមនុស្ស។ ការអភិវឌ្ឍបានបង្ហាញអោយឃើញយ៉ាងច្បាស់ថាប្រទេសជាតិនីមួយៗអាចរីកចម្រើនទៅមុខបានគឺអាស្រ័យដោយធនធានមនុស្សដើរតួយ៉ាងសំខាន់ក្នុងការបំពេញរាល់សកម្មភាពទាំងនោះដែលមានសមត្ថភាព មនុស្សដែលមានគុណភាពពោលគឺប្រជាពលរដ្ឋសកម្មព្រោះថាមនុស្សជាកត្តាផលិតកម្មដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងសេវាកម្មផ្សេងៗក្នុងការអភិវឌ្ឍប្រទេសជាតិទាំងមូល។

**១. ៤. ១.៣.កត្តាមូលធន**

អ្នកសេដ្ឋវិទូបាននិយាយថា ដំណើរការដំបូងនៅក្នុងការអភិវឌ្ឍគឺបង្កើតអោយមានមូនធនតាមរយៈការសន្សំនិងការវិនិយោគ មូលធនគឺជាកត្តាដ៏សំខាន់បំផុតនៅក្នុងដំណើរការអភិវឌ្ឍក៏ដូចជាកំណើនសេដ្ឋកិច្ចដោយសារមូលធនជាប្រភពដែលនាំអោយមានកត្តាផលិតកម្ម ឧបករណ៍សម្រាប់ដោះដូរទំនិញនិងជាប្រភពនៃតម្រូវការចាំបាច់មួយសំរាប់មនុស្សដែលធ្វើឱ្យមានភាពប្រសើរឡើងនៃប្រាក់ចំណូលនិងគុណភាពរស់នៅរបស់

មនុស្សដើម្បីអភិវឌ្ឍន៍។ ការកើនឡើងនៃមូលធនចេញជាលទ្ធផលនៅពេលដែលសមាមាត្រនៃចំណូលបច្ចុប្បន្ន ត្រូវបានសន្សំ និងនិយោគធ្វើឱ្យកើនឡើងនូវទិន្នផលនិងប្រាក់ចំណូលនៅពេលអនាគត។ នៅពេលដែលការវិនិយោគលើមូលធនកើនឡើងនោះផលិតកម្មការងារក៏កើនឡើងផងដែរ។ ការវិនិយោគផ្ទាល់ទាំងនេះគឺត្រូវបាន បន្ថែមដោយការវិនិយោគទៅលើអ្វីដែលត្រូវបានគេស្គាល់នៅក្នុងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមដូចជា ផ្លូវថ្នល់ អគ្គិសនី ទឹកស្អាត ការទាក់ទងសម្របសម្រួលគ្នាក្នុងសកម្មភាពសមាហរណកម្មសេដ្ឋកិច្ច។

### ១. ៤.១.៤.កត្តាបច្ចេកវិទ្យា

បច្ចេកវិទ្យាអាចចាត់ទុកថាជាប្រភពចម្បងនៅក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចហើយការផ្លាស់ប្តូរបច្ចេកវិទ្យារួមចំណែកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រទេសកំពុងអភិវឌ្ឍ។ បច្ចេកវិទ្យានាំឱ្យមានបម្រែបម្រួលក្នុងដំណើរការផលិតកម្មដែលគេអាចផលិតផលិតផលបានច្រើនដែលមានគុណភាពល្អជាងមុននិងសន្សំពលកម្មព្រមទាំងសន្សំមូលធនគឺជាអ្វីដែលគេត្រូវការបំផុត។ បម្រែបម្រួលបច្ចេកវិទ្យាគឺជាការរុករកដំណើរការនៃការកែលម្អគុណភាពក្នុងទ្រង់ទ្រាយតូចទៅទ្រង់ទ្រាយធំជាបន្តបន្ទាប់ដែលទាមទារអោយមានការជម្រុញនិងការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រភពនៃបច្ចេកវិទ្យាកំពុងអភិវឌ្ឍគឺការទិញបច្ចេកវិទ្យាពីប្រទេសរីកចម្រើនដោយប្តូរជាមួយទំនិញនាំចេញរបស់ខ្លួន។ ដូច្នេះបច្ចេកវិទ្យាសំខាន់ណាស់សម្រាប់ធានានូវកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែងដែលមានការចាត់ថ្នាក់ជាមូលដ្ឋានបីគឺ៖

- កំណើនបច្ចេកវិទ្យាអព្យាក្រឹត្យ៖ កើតឡើងនៅពេលផលិតផលខ្ពស់ត្រូវបានសម្រេចនៅបរិមាណដូចគ្នាពីការផ្សំនៃកត្តាផលិតកម្ម ។
- កំណើនបច្ចេកវិទ្យាតាមរយៈការសេន្សំពលកម្ម៖ កើនឡើងនៅពេលកម្រិតនៃផលិតផលកើនឡើងជាមួយនឹងបរិមាណនៃកត្តាពលកម្មដដែលនោះ ។តួយ៉ាងកុំព្យូទ័រ អគ្គិសនី កីត្បាញស្វ័យប្រវត្តិ ត្រាក់ទ័រ ម៉ាស៊ីនច្រូតស្រូវ និងឧបករណ៍ទំនើបផ្សេងៗទៀតបានចាត់ទុកថាជាការសេន្សំពលកម្ម ។
- កំណើនបច្ចេកវិទ្យាតាមរយៈការសន្សំមូលធន៖ គឺជាការកើនឡើងនូវកម្រិតបរិមាណផលិតផលជាមួយបរិមាណកត្តាមូលធនដដែល។ ការរីកចម្រើនបច្ចេកវិទ្យានេះកើតមានតាមរយៈការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ របកគំហើញនូវឧបករណ៍ថ្មីៗសម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្មគឺការសន្សំមូលធន។

### ១. ៤. ១. ៥ កត្តារចនាសម្ព័ន្ធ

ក្រៅពីកត្តាធនធានធម្មជាតិ មនុស្ស មូលធន ដែលបានបរិយាយខាងលើកត្តារចនាសម្ព័ន្ធក៏ជាកត្តាសំខាន់មួយក្នុងការកំណត់ទិសដៅ និងខ្សែបន្ទាត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ។ នៅក្នុងការអភិវឌ្ឍគឺត្រូវមាននូវរចនាសម្ព័ន្ធពិតប្រាកដមួយដូចជារចនាសម្ព័ន្ធនយោបាយ រចនាសម្ព័ន្ធច្បាប់ រចនាសម្ព័ន្ធសង្គម និងរចនា

សម្ព័ន្ធសេដ្ឋកិច្ច។ល។ ស្តែងចេញពីរចនាសម្ព័ន្ធទាំងនេះគឺជាស្នូលនៃមូលដ្ឋានគ្រឹះធំសំខាន់មួយក្នុងការអភិវឌ្ឍ ប្រទេសជាតិពោរពេញដោយស្ថេរភាពសង្គម និងសន្តិភាពនយោបាយ។ ដោយការរួមបញ្ចូលនូវកត្តាទាំងនេះគឺ មានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងល្អនោះទើបធ្វើអោយសេដ្ឋកិច្ចមានការអភិវឌ្ឍប្រកបដោយនិរន្តភាព។

**១.៤.២ កត្តាជាបញ្ហាដល់ការអភិវឌ្ឍ**

ការអភិវឌ្ឍជាទូទៅពុំអាចធ្វើអោយស្មើគ្នាគ្រប់តំបន់ឡើយជាពិសេសក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនិង ប្រទេសក្រីក្រដែលងាយរងគ្រោះនឹងជួបឧបសគ្គមួយចំនួនដូចជា៖

**១. ៤. ២. ១ ភាពក្រីក្រ**

ភាពក្រីក្រត្រូវបានគេចាត់ទុកថាជាអ្នកបំផ្លិចបំផ្លាញបរិស្ថានដ៏ធ្ងន់ធ្ងរបំផុតនៅលើលោកយើងនេះ។ ហើយភាពក្រីក្រទាំងនេះត្រូវបានគេចាត់ទុកថាជាអ្នកធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍផងដែរដោយសារតែភាពក្រីក្រ ឬហៅថាក្រស្ទើរដាច់ពោះនោះបានធ្វើឲ្យពួកគេចំណាយធនធានដ៏មានតម្លៃដែលពួកគេមានដូចជា ព្រៃឈើ ប រិស្ថានធ្វើជាថ្នូរដោះដូរនឹងចំណីអាហារមួយចម្អែតតែប៉ុណ្ណោះជាក់ស្តែងដូចជាតំបន់ Sao Pulo របស់ប្រទេសប្រេ ស៊ីលទីនោះត្រូវបានគេចាត់ទុកថាជាតំបន់ដែលទទួលរងការបំពុលបរិស្ថានខ្លាំងក្លាបំផុត និងជាកន្លែងមួយពិបាក ក្នុងការអភិវឌ្ឍដែរដើម្បីរស់ពួកគេសុខចិត្តកាប់បំផ្លាញធនធានធម្មជាតិដ៏មានតម្លៃរបស់ពួកគេដូចជាឈើល្អៗ មួយចំនួនដើម្បីយកមកធ្វើជាអុសសម្រាប់ចម្អិនអាហារតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតបើផ្អែកលើទ្រឹស្តីរបស់ពួក Classic ភាពក្រីក្រជាកត្តាមួយធ្វើឲ្យមានការសន្សំទាប ការសន្សំទាបនោះធ្វើឲ្យមានការវិនិយោគទាបដែរ (ការវិ និយោគលើសម្ភារៈ និងមិនមែនសម្ភារៈ) ព្រោះសន្សំជាប្រភពនៃការវិនិយោគ កង្វះវិនិយោគធ្វើឲ្យមានផលិតកម្ម ទាប ធ្វើឲ្យប្រាក់ចំណូលទាប។ ចំណែកពួក Keynes យល់ថានៅពេលដែលក្រធ្វើឲ្យមានតម្រូវការទាបដែលនាំ ឲ្យមានទីផ្សារតូច ធ្វើឲ្យកង្វះការវិនិយោគនាំឲ្យផលិតកម្មទាបចុងបញ្ចប់ធ្វើឲ្យប្រាក់ចំណូលទាប។ បញ្ហាប្រាក់ សន្សំ ការវិនិយោគ និងមូលធនគឺជាបញ្ហាដែលរាំងស្ទះដល់ការអភិវឌ្ឍបញ្ហាទាំងនេះគឺតែងតែកើតមានឡើង ចំពោះតំបន់ដែលក្រីក្រទាំងអស់។

**១.៤.២.២. អត្រាកំណើនប្រជាជនខ្ពស់**

យោងតាមការអង្កេតរបស់សេដ្ឋកិច្ចវិទូជាច្រើនបានឲ្យដឹងថានៅក្នុងប្រទេសតតិយលោក អត្រាកំណើន ប្រជាជនមានការកើនឡើងលឿនជាងពីរដងច្រើនជាងប្រទេសអភិវឌ្ឍដែលកត្តានេះបានធ្វើឲ្យមានការរាំងស្ទះ ដល់ការអភិវឌ្ឍក្នុងប្រទេសក៏ដូចជាតំបន់ដែរ។ មូលហេតុនៃការកើនឡើងលឿននេះបណ្តាលមកពីការប្រកាន់ ទំនៀមទម្លាប់ដ៏ចាស់គម្រិលរបស់ប្រទេសតតិយលោកមួយចំនួនដូចជាមនុស្សមានអាយុក្រោមដប់ប្រាំបីឆ្នាំ ចាស់ទុំមានការគិតគួររៀបអាពាហ៍ពិពាហ៍ទាំងវ័យក្មេងខ្ចី។ ការធ្វើដូចនេះវាមានលក្ខណៈផ្ទុយស្រលះទៅនឹង ប្រទេសមួយចំនួនដែលកំពុងអភិវឌ្ឍដែលកាត់បន្ថយអត្រាកំណើនប្រជាជន។ កំណើនប្រជាជនខ្ពស់អាចជះឥទ្ធិ

ពលដល់ការសន្សំ និងការវិនិយោគចំពោះគ្រួសារដែលមានសមាជិកច្រើនគេមិនសូវមានការសន្សំប៉ុន្មានទេ ដោយសារតែចំណូលដែលរកបានត្រូវបានបែងចែកលើការចំណាយផ្សេងៗជាច្រើនដែលធ្វើឲ្យការសន្សំមានតិចតួច ឬក៏គ្មានតែម្តង។ ការជះឥទ្ធិពលលើផលិតភាពកើតនៅពេលដែលមានចំនួនប្រជាជនមានការកើនឡើងខ្លាំង គេចាំបាច់ត្រូវទាក់ទាញវិស័យវិនិយោគឲ្យមានការកើនឡើងផងដែរ ដើម្បីឲ្យមានកំណើនផលិតភាព បើពុំដូច្នេះទេប្រជាពលរដ្ឋមួយចំនួននឹងគ្មានការងារធ្វើជាមិនខាន។ កំណើនប្រជាជនអាចប៉ះពាល់ដល់ទីក្រុងនៅពេលដែលមានកំណើនប្រជាជនខ្លាំងវាក៏ជះឥទ្ធិពលអាក្រក់ដល់ទីក្រុងដោយមានមនុស្សកកកុញនៅទីក្រុង និងមានបញ្ហាជាច្រើនកើតឡើងដូចជា អំពើឆក់ប្លន់ ពេស្យាចារ និងការរស់នៅដោយគ្មានផាសុកភាព ខ្វះអនាម័យ និងបរិស្ថានកខ្វក់ជាដើម។

**១.៤.២.៣. ការអប់រំទាប**

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសតតិយលោកភាគច្រើនអត្រាអនក្ខរជនមានចំនួនច្រើនដែលជាពិសេសនៅតាមតំបន់ជនបទ ចំណែកឯនៅទីក្រុងវិញអត្រាអនក្ខរជនមានចំនួនតិចតួចនេះអាចបញ្ជាក់ថាវិស័យអប់រំនៅក្នុងប្រទេសមិនទាន់ជ្រួតជ្រាបបានគ្រប់ទីកន្លែងនៅឡើយដែលធ្វើឲ្យអ្នកមានជំនាញផ្នែកបច្ចេកវិទ្យានៅមានកម្រិតទាប ឬជួនកាលគ្មានជាលទ្ធផលធ្វើឲ្យមានការពិបាកក្នុងការអភិវឌ្ឍប្រទេស។ប្រទេសកំពុងអភិវឌ្ឍមួយចំនួននៅមិនទាន់មានលទ្ធភាពផ្តល់សេវាសាធារណៈដោយឥតគិតថ្លៃដល់កុមារដែលគ្រប់អាយុចូលរៀននៅឡើយទេ ហើយកុមារមួយចំនួនគ្មានពេលវេលាដើម្បីក្រេបជញ្ជក់ និងទទួលបាននូវចំណេះដឹងផ្សេងៗ ដោយសារតែគ្រួសាររបស់ពួកគេមានជីវភាពក្រលំបាកខ្លាំងពេក។

**១.៤.២.៤. បញ្ហានិកម្មភាព**

បញ្ហានិកម្មភាពគឺជាបញ្ហាមួយដែលគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់សកលលោកជាពិសេសប្រទេសកំពុងអភិវឌ្ឍ។ តាមការអង្កេតជាក់ស្តែងចំនួននៃនិកម្មភាពមានចំនួនខ្ពស់ដែលមនុស្សជាច្រើនមិនអាចរកការងារបានដោយទីផ្សារការងារមិនទាន់មានភាពសម្បូរបែបធ្វើឱ្យប្រជាជនធ្វើការផ្លាស់ទីលំនៅជាច្រើនពីជនបទមកទីក្រុងដោយពួកគេរំពឹងថានឹងរកការងារដែលមានប្រាក់បៀវត្សខ្ពស់ជាងប្រាក់ដែលបានធ្វើរបរកសិកម្ម។ ការផ្លាស់ប្តូរទីលំនៅបានកើនឡើងយ៉ាងសម្បើមលើសពីកំណើននៃឱកាសការងារនៅទីក្រុងនេះបណ្តាលមកពីនិកម្មភាពខ្ពស់និងការបែងចែកពុំស្មើគ្នាក្នុងការផ្តល់ឱកាសការងាររវាងទីក្រុងនិងជនបទ។ បើយោងតាមការវិភាគមួយក្នុងវេបសាយ Wikipedia ដើម្បីទទួលបានផលចំណេញពីសេដ្ឋកិច្ចត្រឹមតែ២/៣ប៉ុណ្ណោះ នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះរាល់បណ្តាប្រទេសកំពុងអភិវឌ្ឍបើធ្វើការប្រមូលផ្តុំគ្នាច្រើនទៅគឺក្លាយជាចលកររារាំងការរីកចម្រើនរបស់សង្គម។ ការខ្វះទីជម្រកនឹងកើតមានឡើងនៅពេលដែលមាននិកម្មភាព ភាពក្រីក្រក៏កើតឡើងជាបន្តបន្ទាប់ដែលអាចបង្កផលលំបាកដល់រដ្ឋាភិបាលក៏ដូចជាប្រទេសជាតិទាំងមូល។ ក្នុងនោះដែរពេលនិកម្ម

ភាពកើតឡើងអំពើចលាចលផ្សេងៗដូចជាពេស្យាចារ ល្បែងស៊ីសង ការលួចឆក់ ប្លន់ និងបញ្ហាផ្សេងៗជាច្រើននឹងកើតមានដែរ។ រាល់បញ្ហានេះសុទ្ធតែកើតឡើងដោយសារនិកម្មភាពហើយបញ្ហានេះនឹងបណ្តាលឱ្យមានភាពរាំងស្ទះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចរួមទាំងបង្កអោយមានភាពអសន្តិសុខសង្គមនិងប្រទេសទៀតផង។

**១.៤. ២. ៥ កត្តានយោបាយ**

ជាការពិតណាស់ប្រទេសមួយអាចអភិវឌ្ឍន៍ឬអត់គឺអាស្រ័យលើស្ថានភាពនយោបាយរបស់ប្រទេសនោះមានស្ថានភាពដូចម្តេច? ប្រសិនបើប្រទេសនោះស្ថិតនៅក្នុងអសន្តិភាពនយោបាយ អសន្តិសុខ ប្រឈមមុខនឹងភាពអនាធិបតេយ្យចលាចល ឬមួយច្បាប់ប្រទេសស្ថិតក្នុងសភាពទន់ជ្រាយដែលមិនអាចធានាសន្តិសុខនិងយុត្តិធម៌ជូនប្រជាពលរដ្ឋបាននោះជាបញ្ហាដ៏ធំមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងប្រទេសជាតិទាំងមូល។ ឬក៏ស្ថិតក្នុងស្ថានភាពមួយទៀតគឺសង្គ្រាមនោះនឹងទទួលរងនូវការខាតបង់យ៉ាងធំធេង។ ផលប៉ះពាល់ទាំងនេះគឺការបាត់បង់នូវទំនុកចិត្តពីបណ្តាប្រទេសនានាក្នុងការចូលមកវិនិយោគ ឬផ្តល់ជំនួយជាដើម។ ហេតុតែគ្មានទំនុកចិត្តមិនថាតែត្រៀមវិនិយោគប៉ុណ្ណោះទេសូម្បីតែវិនិយោគរួចហើយក៏អាចបាត់បង់ទៅវិញដែរ។ នោះនឹងធ្វើឱ្យប្រជាជនក៏ដូចជាប្រជាជាតិទាំងមូលបាត់បង់នូវចំណូលនិងបញ្ហាផ្សេងៗទៀតដែលរាំងស្ទះដល់ការអភិវឌ្ឍប្រទេសជាតិ។

## ១. ៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

ស្របជាមួយគ្នានេះដែរចំពោះយុទ្ធសាស្ត្រនៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៣នៃរដ្ឋសភានិយាយអំពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានលើកឡើងថា៖ បណ្តាញគមនាគមន៍មានតួនាទីជាសរសៃឈាមសម្រាប់តភ្ជាប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្លាយទៅជាសរីរាង្គកាយសេដ្ឋកិច្ចមួយដែលធានាបាននូវសមាហរណកម្មផ្ទៃក្នុងខ្លួនឯង និងសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាជារូបវន្តទៅក្នុងសេដ្ឋកិច្ចតំបន់ផង និងពិភពលោកផង។ លើសពីនេះទៀតសម្រាប់ស្ថានភាពសេដ្ឋកិច្ចកម្ពុជាហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមានតួនាទីដ៏សំខាន់ជា "ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច" និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតមួយសម្រាប់កាត់បន្ថយភាពក្រីក្រ និងទុក្ខលំបាកវេទនារបស់ប្រជាជន។ នៅលើមូលដ្ឋាននៃទស្សនៈវិជ្ជានេះរាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការស្តារ និងកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់រូបភាពរួមមានផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋានដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេសទាំងទីក្រុង ទីប្រជុំជន និងតំបន់ជនបទឆ្ងាយដាច់ស្រយាលមានស្ថេរភាព សុវត្ថិភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងមានតម្លៃទាបក្នុងទិសដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជម្រុញវិស័យទេសចរណ៍ ការអភិវឌ្ឍ

ជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់ និងក្នុងសកលលោកពិសេសគឺបម្រើដល់កិច្ចការពារជាតិថែមទៀត។ [8]

## ១.៦.ការថែទាំខួប និងការសម្អាតផ្លូវថ្នល់

### ១.៦.១.ការថែទាំខួប

ការថែទាំខួប គឺជាការលើកគុណភាពផ្លូវថ្នល់ឲ្យបានស្មើនឹងស្ថានភាពដូចដើមឲ្យមានរាងដើមឡើងវិញក្រោយពេលបានប្រើប្រាស់វាអស់រយៈជាច្រើនឆ្នាំមកហើយ។ ការថែទាំនេះនឹងត្រូវកំណត់ថាតើត្រូវធ្វើឡើងនូវពេលណាតាមរបៀបណាដោយទីបញ្ជាការដ្ឋានពីព្រោះការងារនេះវាពាក់ព័ន្ធដល់ប្រតិបត្តិការធំ។ ការថែទាំនេះធ្វើឡើងដើម្បីកែលំអផ្លូវថ្នល់ឲ្យមានសកម្មភាពដូចដើម និងត្រូវកៀរឡើងវិញហើយប្រសិនបើចាំបាច់លើកកម្ពស់តួផ្លូវថ្នល់ឲ្យបានខ្ពស់ជាងសភាពដីនៅជុំវិញ។ ការថែទាំនេះរួមបញ្ចូលផងដែរនូវការប្តូរស្រទាប់ដីគ្រួសលើផ្លូវថ្នល់ ហើយយើងត្រូវពិនិត្យមើលនូវសំណឹកនិងការរលាត់ដាច់នៃផ្លូវថ្នល់ឲ្យបានល្អិតល្អន់ដើម្បីកំណត់ឲ្យបាននូវបុព្វហេតុដែលបណ្តាលឲ្យមានការខូចខាតរបស់ផ្លូវថ្នល់។ ចំពោះលូវិញមានការពិបាកជាងស្ពានបន្តិចព្រោះត្រូវការសម្អាតជាប្រចាំដូចជា កំទេចកំទីដី កំណក ឬវត្ថុដែលនាំឲ្យស្ទះលូចាំបាច់ត្រូវសម្អាតយកចេញក្នុងការថែទាំជាប្រចាំរាល់ពេលអនាគតត្រូវសម្អាតក្បាលនិងកន្ទុយលូផង។ ជញ្ជាំងទប់ក្បាលលូ ទីមុខក្បាលលូ និងកន្ទុយលូត្រូវជួសជុលឲ្យបានល្អក្នុងកំឡុងពេលថែទាំតាមរបៀបនេះម្តងៗ។ ការងារថែទាំតាមរយៈកាល (ខួប) ត្រូវបានអនុវត្តន៍ម្តងម្កាលលើផ្លូវដែលបានខូចខាតជាទ្រង់ទ្រាយធំតាមលក្ខណៈបច្ចេកទេស។

### ១.៦.២.ការខារសម្អាត

- ការឈូសឆាយ(យកដីដែលមានគុណភាពអន់ចេញ)លើផ្ទៃផ្លូវចាស់ដើម្បីបង្កើតជាស្រទាប់បន្ទុំ
- ពិនិត្យជាដំបូងចំណុចដែលស្រុត-ផុង-រិចរិល-គ្រលុកតូច ធំ ដោយគូសឬបាញ់ថ្នាំចំណាំ
- ដោយប្រើពលករ ឬគ្រឿងយន្ត ជីកកកាយដីខូចគុណភាពយកចេញអោយឆ្ងាយពីតួផ្លូវ
- ការជីកកកាយត្រូវពង្រីកផ្ទៃរណ្តៅអោយធំជាងរណ្តៅដើម ដើម្បីអោយមានភាពងាយស្រួលអោយរ៉ូឡូងាយចូលបង្ហាប់បានល្អ។[9]

---

[8] ទីស្តីការគណៈរដ្ឋមន្ត្រី, យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ចតុកោណ ទី២.ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត័, មុំទី១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍, ឆ្នាំ ២០០៤, ទំព័រទី ៣៦

[9] បទដ្ឋានណែនាំសម្រាប់អនុវត្តការងារ ថែទាំតាមរយៈកាល(ខួប) ,ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០១២, ទំព័រទី៣

# ជំពូកទី២
# ស្ថានភាពទូទៅនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
# រូបវន្តនៅខណ្ឌពោធិ៍សែនជ័យ

# ជំពូកទី២
# ស្ថានភាពទូទៅនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅខណ្ឌពោធិ៍សែនជ័យ

## ២.១ ស្ថានភាពទូទៅនៅខណ្ឌពោធិ៍សែនជ័យ

### ២.១.១ ស្ថានភាពភូមិសាស្ត្រ

ខណ្ឌពោធិ៍សែនជ័យ ជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញដែលបានបង្កើតឡើងតាមអនុក្រឹត្យលេខ ៨០អនក្រ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ មានព្រំប្រទល់ខាងជើងទល់នឹងខណ្ឌសែនសុខ និងខណ្ឌព្រែកព្នៅ ខាងត្បូងទល់នឹងខណ្ឌដង្កោ ខាងកើតទល់នឹងខណ្ឌសែនសុខនិងខណ្ឌមានជ័យ ខាងលិចទល់នឹងខណ្ឌកំបូល មានផ្ទៃដីសរុបចំនួន ៦១,៩៩ គីឡូម៉ែត្រការ៉េស្មើនឹង ៨,៩៥% នៃផ្ទៃដីរាជធានីភ្នំពេញ ។

### ២.១.២ ស្ថានភាពប្រជាសាស្ត្រ

ខណ្ឌពោធិ៍សែនជ័យចែកចេញជា ០៧សង្កាត់ ៧៥ភូមិ និង ១៨សហគមន៍ ចំនួនគ្រួសារសរុប ៣៣,២១០គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ១៩២,២០៨នាក់ ស្រី១០៦,១១៧នាក់ មានដង់ស៊ីតេប្រជាជន ៣,១០០នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ ភូមិសាស្ត្រខណ្ឌពោធិ៍សែនជ័យសម្បូរដោយតំបន់ឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម មូលដ្ឋាន អាជីវកម្ម កសិកម្ម និងលំនៅដ្ឋានដែលស្រូបយកកម្លាំងពលកម្ម(កម្មករ កម្មការនី) នៅក្នុងរាជធានីភ្នំពេញ និងមកពីតាមបណ្តាខេត្តនានាទូទាំងប្រទេសកម្ពុជា។

**ប្រភពទិន្នន័យ៖**ឯកសារព័ត៌មានស្តីពីស្ថានភាពខណ្ឌពោធិ៍សែនជ័យឆ្នាំ២០២២ (ទិន្នន័យ ភូមិ សង្កាត់ ឆ្នាំ២០២១) ។

## ២.២. រចនាសម្ព័ន្ធគ្រប់គ្រង និង តួនាទី ភារកិច្ចសមាជិកខណ្ឌ




10

## ២. ៣ ស្ថានភាពសេដ្ឋកិច្ច[11]

ប្រជាពលរដ្ឋមានមុខរបរចម្បងផ្នែកកសិកម្មសំដៅលើចំនួនមនុស្សមានមុខរបរធ្វើស្រែដាំដំណាំចំការរយៈពេលវែង ដាំដំណាំចំការរយៈពេលខ្លី ដាំដំណាំបន្លែ និងចិញ្ចឹមសត្វ សរុបចំនួន ៥៩៦នាក់ ស្មើនឹង០,៥% អ្នកបម្រើការងារផ្នែកសិប្បកម្មផលិតទ្វារ បង្អួច គ្រឿងឧបភោគបរិភោគ និងសិប្បកម្មផ្សេងៗចំនួន ១,៧២៨នាក់ ស្មើនឹង១,៤% និងបម្រើការងារក្នុងផ្នែកសេវាកម្មជាចម្បងរួមមានមុខរបរលក់ដូរ និងជំនួញ ការងារជាជាងជួសជុល ការងារក្នុងផ្នែកដឹកជញ្ជូន ការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ អ្នកបំរើការងារក្នុងវិស័យឯកជន (កម្មកររោងចក្រ បុគ្គលិក អង្គការ) ជាមន្ត្រីរាជការ និង សេវាផ្សេងៗមានចំនួន១១៧,១១១នាក់ ស្មើនឹង

[10] ការិយាល័យរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ

[11] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

៩៨.១% ដែលមុខរបរទាំងនេះជាសក្តានុពលយ៉ាងសំខាន់ក្នុងការរកចំណូលដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងខណ្ឌទាំងមូល។

**២. ៣. ១ ការងារកសិកម្ម**

ផ្ទៃដីបង្កបង្កើនផលស្រូវវស្សាមានចំនួន ១៤៨ហិចតាទទួលបានទិន្នផលស្រូវជាមធ្យម ១,៥តោន ក្នុង១ហិចតា និងទទួលបានចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ពីដំណាំស្រូវចំនួន០,៣ដុល្លារដែលជាចំណូលសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ ទន្ទឹមនឹងសក្តានុពលខាងលើក៏នៅមានបញ្ហាប្រឈមដែលកើតមានក្នុងវិស័យកសិកម្ម ដូចជាទិន្នផលស្រូវដែលទទួលបាននៅទាបដោយការដាំដុះពុំមានលក្ខណៈបច្ចេកទេស ជួបវិបត្តិគ្រោះទឹកជំនន់ ឬភាពរាំងស្ងួត និងជំងឺសត្វជាដើមដែលតម្រូវឱ្យមានវិធានការការពារ និងធ្វើការផ្សព្វផ្សាយបណ្តុះបណ្តាលបច្ចេកទេសកសិកម្មបន្ថែមដល់ប្រជាកសិករ និងភ្នាក់ងារសុខភាពសត្វភូមិជាការចាំបាច់។ ផ្ទៃដីកសិកម្មកាន់តែរួមតូចដោយផ្ទៃដីមួយចំនួនធំប្រែក្លាយទៅជាតំបន់អភិវឌ្ឍន៍លំនៅឋាន តំបន់អគារពាណិជ្ជកម្មសម្រាប់ដោះដូរទំនិញផ្សេងៗ និង តំបន់ទេសចរណ៍សម្រាប់កម្សាន្តលំហែកាយ ។

**២. ៣. ២ ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

មានរោងចក្រចំនួន២០៧ទីតាំង មានកម្មករចំនួន១១០,៩១០នាក់ ស្រី១១៧,៦២១នាក់ សិប្បកម្មចំនួន៧៣៦ទីតាំង មានកម្មករចំនួន២១,៩០៧នាក់ ស្រី១៦,៥២៣នាក់ និងទីតាំងតម្លើងរថយន្តចំនួន០១កន្លែងដែលកំពុងដំណើរការផលិត គ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់គ្រប់មុខ ទ្វារ បង្អួច និងសិប្បកម្មផ្សេងៗជាច្រើនដែលបាននឹងកំពុងជម្រុញឱ្យមានកំណើនរីកលូតលាស់ផ្នែកសេដ្ឋកិច្ច និងជួយបង្កើតការងារឱ្យប្រជាពលរដ្ឋបានជាច្រើនកន្លែង។

**២. ៣. ៣ ការងារពាណិជ្ជកម្ម**

មានផ្សាររដ្ឋចំនួន០៣ផ្សារ ផ្សារទំនើបមានចំនួន១៣ផ្សារ ផ្សារស្តារម៉ាតមានចំនួន១០ផ្សារ ផ្សារឯកជនមាន១៩ផ្សារ ផ្សារសហគមន៍ចំនួន០៣ផ្សារ ផ្សារចល័តចំនួន១១ផ្សារ ផ្សារវិនិយោគចំនួន០២ផ្សារ ទីតាំងលក់ទំនិញឧបភោគបរិភោគមានចំនួន ១៥០មូលដ្ឋាន និងភោជនីយដ្ឋានចំនួន ៣១កន្លែង។ធនាគារចំនួន១៥ទីតាំង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន១៦កន្លែង សេវាផ្ទេរប្រាក់និងផ្ញើប្រាក់មាន១៣កន្លែង លក់រថយន្តចំនួន១០០កន្លែង លក់ម៉ូតូចំនួន១០០កន្លែង។ សណ្ឋាគារមានចំនួន០៨ ផ្ទះសំណាក់មានចំនួន៨២ទីតាំង ក្លឹបកំសាន្តមានចំនួន២១ទីតាំង និង បៀរហ្គាឌិនមានចំនួន០៤ទីតាំងដែលជាប្រភពសក្តានុពលផ្នែកអាជីវកម្មពាណិជ្ជកម្មសម្រាប់ទ្រទ្រង់ជីវភាពមួយផ្នែកធំរបស់ប្រជាពលរដ្ឋ។ តាមការសង្កេតជាក់ស្តែងមូលដ្ឋានពាណិជ្ជកម្ម អាជីវកម្មភាគច្រើនមានលក្ខណៈជាគ្រួសារដែលមានចំណូលតិចតួចនៅឡើយ។

### ២. ៣. ៤ ការងារសាធារណការ

ក្នុងខណ្ឌមានផ្លូវគមនាគមន៍ខ្វាត់ខ្វែងគ្រប់ប្រភេទដូចជា៖ផ្លូវប្រភេទបេទីមីណឺចំនួន០៤ខ្សែ ប្រវែង ១៣,០៥០ម៉ែត្រ ផ្លូវក្រាលបេតុងចំនួន២៣២ខ្សែ ប្រវែងសរុប១៤៤,៤៦៥ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ក្រាលខ្សាច់ភ្នំ និង មានផ្លូវលំជាច្រើនទៀត ។ មានភ្លើងបំភ្លឺតាមដងផ្លូវសាធារណៈនៅតាមដងផ្លូវសំខាន់ដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ និងប្រកបមុខរបរបានទាំងនៅពេលថ្ងៃ និងពេលយប់។ សមិទ្ធផលទាំងនោះកើតឡើងដោយសារថវិការវិភាជន៍របស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលផ្តល់ឱ្យសាលារាជធានីភ្នំពេញ ខណ្ឌ សង្កាត់ សម្រាប់អនុវត្តន៍គម្រោងកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងថវិកាសប្បុរសជនផងដែរ។

## ២. ៤ ចក្ខុវិស័យ គោលបំណង និង គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងខណ្ឌពោធិ៍សែនជ័យ[12]

### ២. ៤. ១ ចក្ខុវិស័យអភិវឌ្ឍន៍

ខណ្ឌពោធិ៍សែនជ័យមានការអភិវឌ្ឍលើគ្រប់វិស័យ ប្រជាពលរដ្ឋមានជីវភាពធូរធារ រស់នៅក្នុងបរិស្ថានល្អប្រកបដោយសុវត្ថិភាព សុខុមាលភាព និង សេចក្ដីថ្លៃថ្នូរ។

### ២. ៤. ២ គោលបំណងអភិវឌ្ឍន៍

- អភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ភ្លើងបំភ្លឺផ្លូវសាធារណៈ ប្រជាពលរដ្ឋមានផ្លូវធ្វើដំណើរល្អ
- លើកកម្ពស់ផលិតកម្មកសិកម្មក្នុងស្រុក និងទិន្នផលកើនឡើង
- គ្រប់គ្រងមូលដ្ឋានផលិតកម្ម អាជីវកម្ម សេវាកម្ម
- សិប្បកម្មប្រើប្រាស់បច្ចេកវិទ្យាទំនើប មានច្បាប់អនុញ្ញាតត្រឹមត្រូវមានសុពលភាព
- ទីតាំងស្ថានីយប្រេងឥន្ធនៈ ទីតាំងលក់ និងស្តុកឧស្ម័នហ្គាសមានសុវត្ថិភាពល្អត្រឹមត្រូវតាមស្តង់ដារ និងតាមច្បាប់កំណត់
- ផ្តល់ការគាំទ្រលើវិស័យទេសចរណ៍ ទីតាំងអាជីវកម្មមានសោភ័ណ្ឌភាព បដិសណ្ឋារកិច្ចល្អ និងបម្រើសេវាតាមភោជនីយដ្ឋានបានល្អ
- គ្រប់គ្រងមូលដ្ឋានធ្វើអាជីវកម្ម ផលិតកម្ម និងគុណភាពចំណីអាហារបម្រើឲ្យសុខភាព ប្រជាពលរដ្ឋ
- ទិន្នន័យភូមិ សង្កាត់ ខណ្ឌ និងវិភាគព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច មានគុណភាព ប្រជាពលរដ្ឋមានបណ្តាញអគ្គិសនីប្រើប្រាស់។

[12] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

### ២. ៤. ៣ គោលដៅអភិវឌ្ឍន៍

- នៅឆ្នាំ២០២៤ មានប្រព័ន្ធគមនាគមន៍ស្អាត និងការថែទាំផ្លូវបានល្អ
- នៅឆ្នាំ២០២៤ មានភ្លើងបំភ្លឺតាមដងផ្លូវសាធារណៈគ្រប់ផ្លូវសំខាន់ៗ
- នៅឆ្នាំ២០២៤ រៀបចំកាវីឡាចិញ្ចើមផ្លូវតាមដងផ្លូវសាធារណៈ
- នៅឆ្នាំ២០២៤ ម្ចាស់សិប្បកម្មយល់ដឹងពីការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- នៅឆ្នាំ២០២៤ ទីតាំងស្ថានីយប្រេងឥន្ធនៈ និងស្តុកឧស្ម័នហ្គាសមានសុវត្ថិភាព
- នៅឆ្នាំ២០២៤ មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍មានអាជ្ញាប័ណ្ណ
- នៅឆ្នាំ២០២៤ សន្តិសុខ និងសុវត្ថិភាពភ្ញៀវទេសចរ
- នៅឆ្នាំ២០២៤ ធនធានមនុស្សក្នុងវិស័យទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មនៅមានកម្រិត
- នៅឆ្នាំ២០២៤ ចំណីអាហារគ្រប់ប្រភេទមិនមានការប្រើប្រាស់សារធាតុគីមី
- នៅឆ្នាំ២០២៤ ពុំមានទំនិញក្លែងក្លាយ និងខុសច្បាប់ ត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស
- នៅឆ្នាំ២០២៤ គុណភាពទិន្នន័យភូមិ សង្កាត់ ខណ្ឌ មានភាពត្រឹមត្រូវ និងច្បាស់លាស់
- នៅឆ្នាំ២០២៤ ការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគមានការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ
- នៅឆ្នាំ២០២៤ ប្រជាពលរដ្ឋមានបណ្តាញអគ្គិសនីរដ្ឋប្រើប្រាស់គ្រប់ផ្ទះ។

### ២. ៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងខណ្ឌពោធិ៍សែនជ័យ

- ជួសជុលផ្លូវចាក់បេតុង ផ្លូវចាក់អ៊ុតកៅស៊ូ AC
- រៀបកាវីឡាតាមចិញ្ចើមផ្លូវសាធារណៈ ដាក់ភ្លើងបំភ្លឺផ្លូវសាធារណៈ
- ផ្តល់ពូជមានទិន្នផលខ្ពស់ ផ្តល់វ៉ាក់សាំងការពារជំងឺសត្វ
- បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និង ចិញ្ចឹមសត្វ
- បណ្តុះបណ្តាលភ្នាក់ងារសុខភាពពេទ្យសត្វភូមិ
- ផ្សព្វផ្សាយច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- ជម្រុញការចុះបញ្ជីសិប្បកម្ម និងស្រង់ស្ថិតិសិប្បកម្ម
- ពង្រឹងការត្រួតពិនិត្យគុណភាពផលិតផលឧស្សាហកម្ម(ស្បៀង ចំណីអាហារ និងភេសជ្ជៈ) និងណែនាំសិប្បករ ឧស្សាហករ ពីការអនុវត្តផលិតកម្មល្អ GMP និងអនាម័យល្អ GHP និងស5
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ចំណុះតាមស្ថានីយប្រេងឥន្ធនៈ

- ត្រួតពិនិត្យបរិមាណ ទម្ងន់ ចំណុះលើទំនិញផលិត និងទំនិញវេចខ្ចប់គ្រប់ប្រភេទ
- ជម្រុញការចុះបញ្ជីផលិតផល(ចបផ) នៅNSC
- សហការនៅតាមផ្សារនានាក្នុងការត្រួតពិនិត្យជញ្ជីងសមត្ថភាពក្រោម 1,000គ.ក្រ
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ចំណុះតាមស្ថានីយប្រេងឥន្ធនៈនិងចុះជម្រុញម្ចាស់ស្ថានីយប្រេងឥន្ធនៈឲ្យមកចុះបញ្ជីនៅ(មមជ) និងណែនាំម្ចាស់ស្ថានីយប្រេងឥន្ធនៈអំពីសុវត្ថិភាពរបស់ស្ថានីយ
- ជម្រុញតាមទីតាំងក្នុងការស្នើសុំអាជ្ញាប័ណ្ណថ្មី និងបន្ត
- បើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង
- វគ្គបណ្តុះបណ្តាល និងបញ្ជ្រាបការយល់ដឹងបន្ថែមទាក់ទងពីសារៈសំខាន់នៃទេសចរណ៍
- ច្បាប់ទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ចលនាប្រលងប្រណាំង "ទីក្រុងស្អាតរមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" និងចលនាប្រលងប្រណាំងនានា
- ចុះត្រួតពិនិត្យគុណភាពសុវត្ថិភាពចំណីអាហារ និងទំនិញនៅតាមផ្សារ ហាង និងតាមទីតាំងអាជីវកម្ម
- ចុះផ្សព្វផ្សាយដល់អាជីវករឲ្យចេះវិចខ្ចប់ រៀបចំទុកដាក់ចំណីអាហារឲ្យមានអនាម័យត្រឹមត្រូវ
- ចុះស្រង់ស្ថិតិទីតាំងអាជីវកម្មគ្រប់ប្រភេទ
- ចុះផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលតាមផ្សារ
- ចុះពិនិត្យ និងផ្សព្វផ្សាយអំពីច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា និងច្បាប់ពាក់ព័ន្ធនានា
- សហការជាមួយមន្ទីរជំនាញចុះត្រួតពិនិត្យផលិតផលលក់តាមផ្សារ
- ពង្រឹងការចុះស្រង់ទិន្នន័យភូមិ សង្កាត់ និងខណ្ឌ
- ការបណ្តុះបណ្តាល ស្តីពីការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ
- ផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ដល់ប្រជាពលរដ្ឋ។[13]

## ២. ៦. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌពោធិ៍សែនជ័យ (២០១៩-២០២១)[14]

### ២. ៦. ១ បណ្តាញផ្លូវ និង ការជួសជុលដែលបានរួចរាល់

#### ២. ៦. ១. ១ ការងារស្ថាបនា-ជួសជុលផ្លូវដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ

- ឆ្នាំ ២០១៩ ចំនួនផ្លូវបានជួសជុលដោយចាក់បេតុងឆ្អឹងដែករួច ១០០% ចំនួន៩ខ្សែមានប្រវែងសរុប 4,661m និង មានផ្ទៃក្រលាចំនួន 38,295m$^2$ មានដូចខាងក្រោម៖

[13] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

[14] របាយការណ៍លទ្ធផលការងារ ក្នុងរយៈពេលមួយឆ្នាំ ២០១៩ ២០២០ ២០២១ របស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ1998 ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ពីផ្លូវលេខ110ដល់ផ្លូវភូមិត្រពាំងជ្រៃមានប្រវែង 1,728m x 8m x 0.15m = 13,824m²(ពីមុនជាផ្លូវដី + បេតុងឬស្សី)

២. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 107B ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ពីផ្លូវលេខ 110 ដល់ផ្លូវលេខ 1998 មានប្រវែង 430m x 7m x 0.15m = 3,010m² (ពីមុនជាផ្លូវបេតុងឬស្សី)

៣. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ123cc ភូមិត្រពាំងថ្លឹង៣ និងភូមិថ្នល់គោល២ ស្ថិតក្នុងសង្កាត់ចោមចៅទី១ និងសង្កាត់ចោមចៅទី២ ចាប់ពីផ្លូវលេខ 1031(ផ្លូវអង្គតាម៉ិញ)ដល់ផ្លូវលេខ 8cc (ផ្លូវថ្នល់គោល) មានប្រវែង 833m x 7m x 0.15m = 5,831m² (ពីមុនជាផ្លូវបេតុងឆ្អឹងដែក)

៤. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 1084 ភូមិស្រែរាជ្ជ: សង្កាត់សំរោងក្រោមចាប់ពីមហាវិថីឈ្នះ-ឈ្នះ (PKO+00) ដល់ចំណុចPKo + 320 ភូមិអង្គតាកូវ សង្កាត់គោករកា មានប្រវែង 320m x 9m x 0.20m = 2,880m² (ពីមុនជាផ្លូវបេតុងឆ្អឹងដែក)

៥. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 1979 ភូមិព្រៃព្រីងខាងត្បូង២ និងភូមិថ្នល់បំបែក សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវជាតិលេខ៣ដល់ផ្លូវជាតិលេខ៤ មានប្រវែង 450m x 7m x 0.15m = 3,150m² (ពីមុនជាផ្លូវបេតុងឬស្សី)

៦. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ123K2 (ចាប់ពីផ្លូវលេខ110k ដល់ផ្លូវ លេខ114k) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ប្រវែង 440m x 8m x 0.15m = 3.520m² (ពីមុនជាផ្លូវបេតុងឬស្សី)

៧. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ133KH (ចាប់ពីផ្លូវលេខ114k ដល់ផ្លូវលេខ133KE) ស្ថិតនៅភូមិជម្ពូវន្ត២ សង្កាត់ចោមចៅទី៣ ប្រវែង 280m x 8m x 0.15m = 2,240m² (ពីមុនជាផ្លូវបេតុងឬស្សី)

៨. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ133KE (ចាប់ពីផ្លូវលេខ133KR ដល់ផ្លូវ ក្នុងភូមិ) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ ប្រវែង 360m x 6m x 0.15m = 2,160m² (ពីមុនជាផ្លូវបេតុងឬស្សី)

៩. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ133KF (ចាប់ពីផ្លូវលេខ133KH ដល់ផ្លូវក្នុងភូមិ) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ ប្រវែង 280m x 6m x 0.15m = 1,680m² (ពីមុនជាផ្លូវបេតុងឬស្សី)

- ឆ្នាំ២០២០ ចំនួនផ្លូវបានជួសជុលដោយចាក់បេតុងឆ្អឹងដែករួច 100% ចំនួន 12 ខ្សែមានប្រវែងសរុប 9,543m និងមានផ្ទៃក្រឡាចំនួន 73,197m² មានដូចខាងក្រោម៖

១. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 20k ចាប់ពីផ្លូវលេខ23k ដល់ផ្លូវ 68k ស្ថិតក្នុងភូមិចំការឪឡឹក២ សង្កាត់ កាកាបទី២ មានប្រវែង 480m x 7m x 0.15m (ពីមុនជាផ្លូវដី)

២. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 68k ចាប់ពីផ្លូវលេខ20k ដល់ផ្លូវ 105k ស្ថិតក្នុងភូមិចំការឪឡឹក២ សង្កាត់ កាកាបទី២ មានប្រវែង 140m x 7m x 0.15m (ពីមុនបេតុងឬស្សី)

៣. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ផ្លូវលេខ១ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវសហព័ន្ធរុស្សីដល់ផ្លូវបេតុងមុខរោងចក្រ វ៉ន វិច មានប្រវែង 1,255m x 12m x 0.20m (ពីមុនបេតុងឬស្សី)

៤. ការងារជួសជុសផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 87K, ភូមិព្រៃទា២ និងភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ១ ភូមិព្រៃជីសាក់ដល់ផ្លូវ 88k មានប្រវែង 700m x 8m x 0.20m (ពីមុនជាផ្លូវដី)

៥. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 123kA ចាប់ពីផ្លូវលេខ 88k ដល់ប្រឡាយត្រពាំងជ្រៃស្ថិតនៅក្នុងភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ មានប្រវែង 240m x 7m x 0.15m (ពីមុនជាផ្លូវដី)

៦. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 88kចាប់ពីផ្លូវលេខ 123KA ដល់ផ្លូវលេខ87K1 ស្ថិតនៅក្នុងភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ មានប្រវែង 360m x 7m x 0.15m(ពីមុនជាផ្លូវដី)

៧. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 46K, ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 115k ដល់មណ្ឌលកុមារកំព្រា មានប្រវែង 700m x 6m x 0.15m (ពីមុនជាផ្លូវដី)

៨. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ169k ភូមិខ្មែរ សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ 138k មុខវត្តអរុណវត្តីដល់ព្រំប្រទល់សង្កាត់កំបូល(វត្តតាភេម)មានប្រវែង 1800m x 8m x 0.20m(ពីមុនជាផ្លូវដី)

៩. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 131K-4A ភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ 138k ដល់ផ្លូវ 134KB មានប្រវែង 309m x 8m x0.20m (ពីមុនជាផ្លូវដី)

១០. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 131K ភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ 138k ដល់ផ្លូវ 134KB មានប្រវែង 402m x 8m x 0.20m (ពីមុនជាផ្លូវដី)

១១.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃព្រីងខាងជើង១ និងភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣ មានប្រវែង 1200m x mx 0.15m (ពីមុនជាផ្លូវដី)

១២. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 5cc ភូមិថ្មគោល១ សង្កាត់ចោមចៅទី២ និងភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវចោមចៅដល់ផ្លូវបេតុងភូមិថ្មគោល១ មានប្រវែង 1,390m x 6m x 0.15m (ពីមុនជាផ្លូវដី)។

- ឆ្នាំ២០២១

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃល្វា សង្កាត់ចោមចៅទី២ មានប្រវែង 1550m x 6 0.15m សម្រេចបានលទ្ធផល 100%

២.ការងារជួសជុលផ្លូវដោយចាក់ក្រាលបេតុងឆ្អឹងដែក ផ្លូវលេខ 71K ភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ60K ដល់ផ្លូវលេខ 71K មានប្រវែង 300m x 5m x 0.15m សម្រេចបានលទ្ធផល 100%

៣.ការងារជួសជុលផ្លូវដោយចាក់ក្រាលបេតុងឆ្អឹងដែក ផ្លូវលេខ 83K ភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 76K ដល់ផ្លូវរថភ្លើងមានប្រវែង 195m x 5m x 0.15m សម្រេចបានលទ្ធផល 100%

៤. ការងារសាងសង់ស្ពានចំនួន ៧ អំពីបេតុងស្ថិតនៅប្រឡាយទួលពង្រទី១ ក្នុងភូមិទួលពង្រ សង្កាត់ចោមចៅទី១ ដែលមានទំហំ 17m x 15m ចំនួន០១, ទំហំ10m x 10m ចំនួន០១, និងទំហំ 8m x 8m ចំនួន 0៥ ដែលជារួមសម្រេចបានលទ្ធផល 100% ។

### ២. ៦. ១. ២ ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ

- ឆ្នាំ២០១៩ ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែករួច 100% ចំនួន 5ខ្សែមានប្រវែងសរុប 2,070m និងមានផ្ទៃក្រឡាចំនួន 11,339 $m^2$ មានដូចខាងក្រោមគឺ ៖

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 68k ភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 56K មានប្រវែង 802m x 6m x 0.15m = 4,812$m^2$ (ពីមុនជាបេតុងឫស្សី) សម្រេចបាន100%

២. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 60K ភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 56k ដល់ផ្លូវលេខ 2011 មានប្រវែង 518m x 6m x 0.15m = 3,108$m^2$ (ពីមុនជាបេតុងឫស្សី) សម្រេចបាន 100%

៣. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ62k ភូមិក្បាលដំរី១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 103k មានប្រវែង 156m x 5m x 0.15m = 780$m^2$ (ពីមុនជាផ្លូវដីស)សម្រេចបាន100%

៤. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 123k-6A ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 123K-8A ដល់ផ្លូវលេខ123KA មានប្រវែង 263m x 5m x 0.15m = 1,315$m^2$ (ពីមុនជាផ្លូវគ្រួសក្រហម) សម្រេចបាន100%

៥. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកផ្លូវលេខ 14TR សហគមន៍ត្រពាំងអញ្ចាញ១ និង២ សង្កាត់ត្រពាំងក្រសាំងចាប់ពីផ្លូវលេខ 15TR ដល់ផ្លូវក្នុងភូមិមានប្រវែង 331m x 4m x 0.15m (ពីមុនជាផ្លូវដី)សម្រេចបាន 100% ។

### ២. ៦. ១. ៣ ការងារជួសជុលដោយប្រើប្រាស់ថវិកាសប្បុរសជន និង ប្រជាពលរដ្ឋ

- ឆ្នាំ២០១៩

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 6cc-1B ភូមិត្រពាំងល្វា២ និងភូមិគោកចំបក់ សង្កាត់កាកាបទី១ និងសង្កាត់ចោមចៅទី១ ចាប់ពីផ្លូវលេខ 2004 ដល់ផ្លូវលេខ 1031(ផ្លូវអង្គតាម៉ិញ)មានប្រវែង 588m x 10m x 0.15m = 5,880m² (ពីមុនជាផ្លូវដី)សម្រេចបាន100%។

### ២. ៦. ១. ៤ ការងារជួសជុលដោយប្រើប្រាស់ថវិកាមូលនិធិសង្កាត់

- ឆ្នាំ២០១៩

១. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវភូមិត្រពាំងក្រសាំងប្រវែង 532m x 5m x 0.15m = 2,660 m² (ពីមុនជាផ្លូវដី)សម្រេចបាន100%

២. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវ 2ខ្សែនៅភូមិត្រពាំងថ្លឹង៣ និង ភូមិត្រពាំងថ្លឹង១ មានប្រវែង 696m x 6m x 0.15m = 4,176 m² (ពីមុនជាផ្លូវដី)សម្រេច បាន100%

៣. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវ 2ខ្សែ នៅភូមិថ្មគោល និងភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ មានប្រវែង 532m x 5m x 0.15m = 2,660 m² (ពីមុនជាផ្លូវដី)សម្រេចបាន100%

៤. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវ 2ខ្សែនៅភូមិព្រៃព្រីងខាងត្បូង២ និងភូមិព្រៃទា១ សង្កាត់ចោមចៅទី៣មានប្រវែង 692m x 4.50m x 0.15m = 3,114 m² (ពីមុនជាផ្លូវដី)សម្រេចបាន100%

៥. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវ 4ខ្សែនៅភូមិប៉ប្រកខាងជើង, ភូមិត្រពាំងល្វា១, ភូមិចំការឪឡឹក១ និងភូមិតាងួន២ សង្កាត់កាកាបទី១មានប្រវែង 1,383m x 6m x 0.15m = 8,298 m² (ពីមុនជាផ្លូវដី)សម្រេចបាន100%

៦. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវ 2ខ្សែនៅភូមិក្បាលដំរី២ និង ភូមិចំការឪឡឹក២ សង្កាត់កាកាបទី២មានប្រវែង 317m x 4m x 0.15m (ពីមុនជាផ្លូវដី)សម្រេចបាន100%

៧. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែកផ្លូវ3ខ្សែ នៅភូមិតិក្ខបញ្ញោ, ភូមិស្រែរាជ្ជៈ និងភូមិអណ្តូងតាអន សង្កាត់សំរោងក្រោមមានប្រវែង 718m x 4m x 0.15m = 2,872 m² (ពីមុនជាផ្លូវដី)សម្រេចបាន100%

- ឆ្នាំ២០២០

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកផ្លូវភូមិសាមគ្គី៥-៦ សង្កាត់ត្រពាំងក្រសាំងមានប្រវែង 317m x 6m x 0.15m (ពីមុនជាផ្លូវដី)

២. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិអក្សរ សង្កាត់ត្រពាំងក្រសាំងមានប្រវែង 300 x 5m x 0.15m (ពីមុនជាផ្លូវដី)

៣. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិសាមគ្គី សង្កាត់ត្រពាំងក្រសាំងមានប្រវែង 310 x 5m x 0.15m (ពីមុនជាផ្លូវដី)

៤. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិគោកចំបក់ សង្កាត់ចោមចៅទី១ មានប្រវែង 789 x 5m x 0.15m (ពីមុនជាផ្លូវដី)

៥. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកស្ថិតនៅផ្លូវលេខ 62kចាប់ពីផ្លូវលេខ 103K ដល់ផ្លូវលេខ56k ស្ថិតនៅភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ មានប្រវែង 408m x 5m x 0.15m (ពីមុនជាផ្លូវដី)

៦. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃព្រីងខាងត្បូង២ សង្កាត់ចោមចៅទី៣ មានប្រវែង 600m x 5m x 0.15m (ពីមុនជាផ្លូវដី)

៧. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃទា២សង្កាត់ចោមចៅទី៣ មានប្រវែង 365m x 5m x 0.15m (ពីមុនជាផ្លូវដី)។

## ២. ៦. ២ ការជីកដាក់លូ

### ២. ៦. ២. ១ ការងារស្ថាបនា-ជួសជុលលូដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ

- ឆ្នាំ២០១៩ ការងារជីកដាក់លូចំនួន 12ខ្សែ (ទំហំចាប់ពី 0.6m ដល់ 2.5m x 2.5m) មានដូចខាងក្រោម៖

១. ការងារជីកដាក់លូមូលទំហំ1.50m នៅផ្លូវលេខ110 ចាប់ពីរង្វង់មូលចោមចៅដល់ផ្លូវលេខ 9K មានប្រវែង 3,400mនិងពីផ្លូវលេខ១K ដល់ផ្លូវលេខ2011 លូទំហំមុខកាត់1m ប្រវែង ៤00m (សម្រេចបាន100%)

២. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ 123cc ភូមិថ្មគោល២ និងភូមិត្រពាំងថ្លឹង៣ ស្ថិតក្នុងសង្កាត់ចោមចៅទី២ និងសង្កាត់ចោមចៅទី១ ចាប់ពីផ្លូវបេតុងលេខ 8cc ដល់ផ្លូវលេខ1031(ផ្លូវអង្គតាម៉ិញ)មានប្រវែង 1,666m

៣. ការងារជីកដាក់លូមូលទំហំ 1m នៅផ្លូវលេខ 1084 ភូមិស្រែរាជ្ជៈ សង្កាត់សំរោងក្រោម ចាប់ពីមហាវិថីឈ្នះ-ឈ្នះ (PK0+00)ដល់ចំណុចPKo + 320ភូមិអង្គតាកូវ សង្កាត់គោករកាមានប្រវែង 640m (សម្រេចបាន 100%)

៤. ការងារជីកដាក់លូមូលទំហំ 1m នៅផ្លូវលេខ59cc ភូមិចោមចៅ២ សង្កាត់ចោមចៅទី២ ចាប់ពីផ្លូវចោមចៅដល់ប្រឡាយមេមានប្រវែង782m (សម្រេចបាន100%)

៥. ការងារជីកដាក់លូមូលទំហំ 1m មានប្រវែង 173m នៅផ្លូវភូមិថ្មគោល២ សង្កាត់ចោមចៅទី២ (សម្រេចបាន 100%)

៦. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ 1979 ភូមិព្រៃព្រីងខាងត្បូង២ និងភូមិថ្មល់បំបែក សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវជាតិលេខ៣ ដល់ផ្លូវជាតិលេខ៤ មានប្រវែង 450m (សម្រេចបាន 100%)

៧. ការងារជីកដាក់លូមូលភ្លោះទំហំ 1.50m ក្នុងប្រឡាយត្រពាំងជ្រៃចំនួនពីរទីតាំងមានប្រវែង 260m (សម្រេចបាន 70%)

៨. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ 68k និងផ្លូវ 60k ភូមិចំការឪឡឹក១ និងភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 2011 មានប្រវែង 1,320m (សម្រេចបាន100%)

៩. ការងារជីកដាក់លូមូលទំហំ0.60m អមសងខាងផ្លូវលេខ១ភូមិព្រៃជីសាក់សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 110 ដល់ផ្លូវបេតុងមុខរោងចក្រ វ៉ុន រ៉ិច មានប្រវែង 2500m (សម្រេចបាន100%)

១០. ការងារជីកដាក់លូជ្រុងភ្លោះទំហំ (2.50m x 2.50m) ក្នុងប្រឡាយបារាំងភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ចាប់ពីផ្លូវលេខ 6cc-5 ដល់ព្រលានយន្តហោះមានប្រវែង 500m (សម្រេចបាន 25%)

១១. ការងារជីកដាក់លូមូលទំហំ 1.50m ក្នុងប្រឡាយភូមិព្រៃទា២ និងភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ១ ដល់រោងចក្រឥណ្ឌាមានប្រវែង 750m (សម្រេចបាន60%)

១២. ការងារជីកដាក់លូជ្រុងភ្លោះទំហំ (2m x 2m) នៅក្នុងសាច់ផ្លូវលេខ20k ចាប់ពីចុងចំការឪឡឹកដល់ផ្លូវលេខ 105k មានប្រវែង 620m (សម្រេចបាន64%)។

១៣. ការងារជីកដាក់លូភ្លោះកាត់ផ្លូវទំហំ (2m x 2m) នៅផ្លូវលេខ1998ប្រវែង 13m (សម្រេចបាន100%)

១៤. ការងារជីកដាក់លូជ្រុងភ្លោះទំហំ (2mx2m) ប្រវែង 12m ក្នុងប្រឡាយចំការឪឡឹកកាត់ទទឹង ផ្លូវលេខ 107KC (ផ្លូវចូលនាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាត) នៃក្រសួងអភិវឌ្ឍន៍ជនបទ (សម្រេចបាន 100%)។

- ឆ្នាំ២០២០ចំនួនលូមានទំហំមុខកាត់ចាប់ពី (0.80m ដល់ 2m x 2m) ដែលបានជួសជុល១០០% មានចំនួន ៨ ខ្សែមានប្រវែងសរុប 7,922m មានដូចជា៖

១. ការងារដាក់លូជ្រុងក្នុងសាច់ផ្លូវទំហំ 2m x 2m ប្រវែង480m ភ្លោះស្ថិតនៅផ្លូវលេខ 20k ចាប់ពីផ្លូវលេខ 23k ដល់ផ្លូវលេខ 68k ស្ថិតនៅភូមិចំការឪឡឹក២ សង្កាត់កាកាបទី២

២. ការងារដាក់លូជ្រុងក្នុងសាច់ផ្លូវទំហំ 2m x 2m ប្រវែង140m ភ្លោះស្ថិតនៅផ្លូវលេខ 68k ចាប់ពីផ្លូវលេខ 20k ដល់ផ្លូវលេខ 105k ស្ថិតនៅភូមិចំការឪឡឹក២ សង្កាត់កាកាបទី២

៣. ការងារដាក់លូជ្រុងក្នុងសាច់ផ្លូវទំហំ 2m x 2m ប្រវែង 500m មួយជួរស្ថិតនៅផ្លូវលេខ105kចាប់ពីផ្លូវលេខ 68k ដល់ផ្លូវរថភ្លើង នៅភូមិចំការឪឡឹក២ សង្កាត់កាកាបទី២។

៤. ការងារជីកដាក់លូមូលទំហំ1.50m ប្រវែង360m មួយជួរស្ថិតនៅផ្លូវលេខ 123KA ចាប់ពីផ្លូវលេខ 88k ដល់ប្រឡាយត្រពាំងជ្រៃស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ និង ភូមិត្រពាំងជ្រៃ សង្កាត់កាកាបទី២

៥. ការងារជីកដាក់លូមូលទំហំ 1.50m ប្រវែង240m មួយជួរស្ថិតនៅផ្លូវលេខ 8BK ផ្លូវលេខ 123kA ដល់ផ្លូវលេខ87k1 ស្ថិតនៅភូមិព្រៃទា១ សង្កាត់ចោមចៅទី៣

៦. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 1500m នៅភូមិព្រៃជីសាក់ព្រៃព្រីងខាងជើង១ និងភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣

៧. ការងារដាក់លូមូលទំហំ 1.50m ប្រវែង650m មួយជួរនៅផ្លូវលេខ 87k ចាប់ពីផ្លូវលេខ១ ភូមិជីសាក់ដល់ផ្លូវលេខ 88k ស្ថិតនៅភូមិព្រៃទា១ សង្កាត់ចោមចៅទី៣

៨. ការងារដាក់លូមូលទំហំ 1.20m ប្រវែង 1,390m មួយជួរនៅផ្លូវលេខ 5cc ភូមិថ្មគោល១ សង្កាត់ចោមចៅទី២ ចាប់ពីផ្លូវចោមចៅដល់លូផ្លូវលេខ8cc

៩. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 2600m សងខាងផ្លូវភូមិព្រៃល្វាចាប់ពីមហាវិថីចោមចៅដល់ផ្លូវលេខ 105cc ស្ថិតក្នុងសង្កាត់ចោមចៅទី២

១០. ការងារដាក់លូមូលទំហំ 1.50m ប្រវែង 12m ចំនួន3ជួរនិង 50m ចំនួន2ជួរស្ថិតនៅមហាវិថីឈ្នះឈ្នះក្នុងភូមិត្រពាំងថ្លង់ ភូមិស្រែរាជ្ជៈ និងភូមិព្រៃពពេល សង្កាត់សំរោងក្រោម។

**២. ៦. ២. ២ ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ**

- ឆ្នាំ២០១៩

១. ការងារជីកដាក់លូមូលទំហំ 1.20m នៅផ្លូវលេខ 86k(ផ្លូវផ្សារព្រៃទា)ភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ113K ដល់សាលាពន្លឺកុលបុត្រមានប្រវែង 355m សម្រេចបាន100%។

- ឆ្នាំ២០២០ ការងារជួសជុលដាក់បណ្ដាញលូទំហំមុខកាត់0.80m រួច100% ចំនួន 6ខ្សែមានប្រវែងសរុប 1,420m មានដូចខាងក្រោមគឺ :

១. ការងារជីកដាក់លូមូលទំហំ 0.80m ប្រវែង 173m នៅផ្លូវលេខ2011 ភូមិតាងួន១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 2009(ផ្លូវក្រុងខ្មែរ)ដល់ផ្លូវរថភ្លើង

២. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 187m នៅផ្លូវលេខ 2002 ភូមិតាងួន១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 2011 ដល់ Pk + 1871

៣. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 440m នៅផ្លូវលេខ 2007 ចាប់ពីមហាវិថីសហព័ន្ធរុស្សីដល់ផ្លូវលេខ 2002 ស្ថិតនៅភូមិតាងួន១ សង្កាត់កាកាបទី១

៤. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 110m នៅផ្លូវលេខ 142k ចាប់ពីផ្លូវលេខ 167k ដល់ផ្លូវលេខ140k ភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង

៥. ការងារដាក់លូមូលទំហំ 0.80m ប្រវែង110m នៅផ្លូវលេខ 140k ចាប់ពីផ្លូវលេខ 142k ដល់ផ្លូវលេខ155k ភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង

៦. ការងារដាក់លូមូលទំហំ 0.80m ប្រវែង370m នៅផ្លូវ 155k ចាប់ពីផ្លូវលេខ140k ដល់មហាវិថីឈ្នះៈឈ្នះ ភូមិជម្រុក សង្កាត់ត្រពាំងក្រសាំង ។

- ឆ្នាំ២០២១

១. ការងារជីកដាក់លូមូលទំហំ1m អមសងខាងផ្លូវភូមិព្រៃល្វា សង្កាត់ចោមចៅទី២ មានប្រវែង 1,300m ចាប់ពីផ្លូវចោមចៅដល់ផ្លូវបំបែកឆ្ពោះទៅរោងចក្រតុងហ្គាសម្រេចបាន 100%

២.ការងារដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ62k ភូមិចំការឪឡឹក១ និងភូមិក្បាលដំរី១ ស្ថិតនៅក្នុងសង្កាត់កាកាប ប្រវែង362m ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 97k សម្រេចបាន 100%

៣. ការងារដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ102k ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ពីផ្លូវ 105kដល់ផ្លូវលេខ 107KA មានប្រវែង 230m សម្រេចបាន 100%

៤. ការជីកដាក់លូទំហំ 0.80m នៅភូមិជម្រុក សង្កាត់ត្រពាំងក្រសាំង ចាប់ពីមហាវិថីឈ្នះ-ឈ្នះ ដល់ផ្លូវ 167K មានប្រវែង 620m សម្រេចបាន 100%

៥. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃល្វា សង្កាត់ចោមចៅទី២ មានប្រវែង 1550m x 6 0.15m សម្រេចបានលទ្ធផល 100%

៦. ការងារដាក់លូមូលទំហំមុខកាត់ 1,20m មានប្រវែង 584m ស្ថិតនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំងចាប់ពីផ្លូវលេខ 134KB ដល់ប្រឡាយផ្លូវរថភ្លើងសម្រេចបាន100%

៧.ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 437k ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវបេតុងលេខ 432k ដល់ក្នុងភូមិប្រវែង 110m សម្រេចបានលទ្ធផល 100% ៨.ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ68k ភូមិចំការឪឡឹក២, ភូមិព្រៃសាលា សង្កាត់កា កាបទី២ ចាប់ពីផ្លូវ 105k ដល់ភូមិព្រៃសាលាប្រវែង 998m សម្រេចលទ្ធផលបាន 100%

៨. ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 438k ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវបេតុងលេខ 432k ដល់ក្នុងភូមិប្រវែង 110m សំម្រេចបានលទ្ធផល 100%។

៩. ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 436k ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវបេតុងលេខ 432k ដល់ក្នុងភូមិប្រវែង 100m សំម្រេចបានលទ្ធផល 100%។

**២. ៦. ២. ៣ ការងារជួសជុលដោយប្រើប្រាស់ថវិកាសប្បុរសជន និង ប្រជាពលរដ្ឋ**

- ឆ្នាំ២០១៩

១. ការងារជីកដាក់លូទំហំមុខកាត់ 1m នៅផ្លូវលេខ 6cc-18 ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ និង ភូមិគោកចំបក់ សង្កាត់ចោមចៅទី១ចាប់ពីផ្លូវលេខ2004 ដល់ផ្លូវលេខ1031(ផ្លូវអង្គតាមិញ) មានប្រវែង 588mសម្រេចបាន100%

២. ការងារជីកដាក់លូទំហំ 1.50m មានប្រវែង98m នៅមហាវិថីឈ្នះ-ឈ្នះ ស្ថិតនៅភូមិស្រែរាជ្ជៈ និងភូមិតិក្ខបញ្ញាប្រវែង 68m ក្នុងសង្កាត់សំរោងក្រោម សម្រេចបាន100%

៣. ការងារជីកដាក់លូជ្រុងទំហំ 2m x 2m ក្នុងប្រឡាយផ្លូវជាតិលេខ៤ ស្ថិតនៅភូមិអង្គកែវ សង្កាត់ចោមចៅទី៣ មានប្រវែង 16m សម្រេចបាន100%

៤. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ38k ភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ចាប់ពីផ្លូវលេខ 86K ដល់ផ្លូវលេខ 88K មានប្រវែង 200m សម្រេចបាន100%

៥. ការងារជីកដាក់លូជ្រុង៣ជួរទំហំ 2m x 2m ប្រវែង 20m ក្នុងប្រឡាយទួលពង្រទី២ ភូមិទួលពង្រ សង្កាត់ចោមចៅទី១សម្រេចបាន100%។

- ឆ្នាំ២០២០

១. ការងារដាក់លូមូលទំហំ 1.50m ប្រវែង139m ចំនួន 3ជួរ និង 148m ចំនួន2ជួរ ស្ថិតនៅមហាវិថីឈ្នះ-ឈ្នះ ភូមិត្រពាំងថ្កង់និងភូមិស្រែរាជ្ជៈ សង្កាត់សំរោងក្រោម

២. ការងារដាក់លូជ្រុងទំហំ 2m x 2m ប្រវែង 11m ឆ្លោះនៅផ្លូវជាតិលេខ៤ ភូមិអង្គកែវ (នៅទល់មុខនាយកដ្ឋានផ្លូវថ្នល់ក្រសួងសាធារណការ និងដឹកជញ្ជូន) សង្កាត់ចោមចៅទី៣។

### ២. ៦. ២. ៤ ការងារជួសជុលដោយប្រើប្រាស់ថវិកាមូលនិធិសង្កាត់

- ឆ្នាំ២០១៩

១. ការងារជីកដាក់លូទំហំ 0.80m នៅផ្លូវលេខ 109KB ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ពីផ្លូវសហព័ន្ធរុស្សី ដល់ក្នុងភូមិប្រវែង 317m សម្រេចបាន100%

២. ការងារជីកដាក់លូទំហំ 0.80m ភូមិត្រពាំងពោធិ៍ និងភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣ មានប្រវែង 300m សម្រេចបាន100%

៣. ការងារជីកដាក់លូទំហំ 0.80m ផ្លូវភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣ មានប្រវែង 300m សម្រេចបាន100%។

៤. ការងារជីកដាក់លូទំហំ 0.80m ផ្លូវលេខ 108k ភូមិព្រៃព្រីងខាងត្បូង២ សង្កាត់ចោមចៅទី ៣ មានប្រវែង 150m សម្រេចបាន100%

៥. ការងារជីកដាក់លូទំហំ 0.80m នៅផ្លូវលេខ44P-5 ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ប្រវែង 150m សម្រេចបាន100%

៦. ការងារជីកដាក់លូទំហំ 0.80m ប្រវែង 447m នៅផ្លូវភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង សម្រេចបាន100%។

- ឆ្នាំ២០២០

១. ការងារដាក់លូមូលទំហំ 0.60m ប្រវែង408m ចំនួន1 ជួរស្ថិតនៅផ្លូវលេខ 62kចាប់ពីផ្លូវលេខ103K ដល់ផ្លូវលេខ256k ស្ថិតនៅភូមិចំការឪឡឹក១ សង្កាត់កាកាបទី១

២.ការងារដាក់លូមូលទំហំ 0.60m ប្រវែង459m ចំនួន1ជួរ ស្ថិតនៅផ្លូវភូមិជ្រៃកោង សង្កាត់ចោមចៅទី២

៣. ការងារដាក់លូមូលទំហំ 0.60m ប្រវែង300m ចំនួន1ជួរ ស្ថិតនៅផ្លូវភូមិព្រៃល្វ សង្កាត់ចោមចៅទី២ ។

## ២. ៦. ៣ ចំនួនផ្លូវដែលបានជួសជុលពុំទាន់រួច (២០១៩-២០២១)

### ២. ៦. ៣. ១ ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ

- ឆ្នាំ២០១៩ ចំនួនផ្លូវដែលបានជួសជុលដោយចាក់បេតុងឆ្អឹងដែកពុំទាន់រួច១០០%មានចំនួន 2ខ្សែមានប្រវែងសរុប 2,495m និងមានផ្ទៃក្រឡាសរុបចំនួន 27,460m² មានដូចជា៖

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកផ្លូវលេខ១ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 110 ដល់ផ្លូវមុខរោងចក្រ វិន វិច (ផ្លូវ110K)មានប្រវែង 1255m x 12m x 0.20m = 15,060m² សម្រេចបាន 65% ពីមុនជាផ្លូវបេតុងឆ្អឹងដែក ផ្លូវដីស)

២. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកផ្លូវលេខ1031 (ផ្លូវអង្គតាម៉ិញ)ចាប់ពីផ្លូវលេខ110 ដល់ផ្លូវលេខ 2004 ស្ថិតក្នុងសង្កាត់កាកាបទី១ និងសង្កាត់អូរបែកក្អមមានប្រវែង 1240m x 101m x 0.20m = 12,40m² (ពីមុនជាផ្លូវបេតុងឬស្សី)។

- ឆ្នាំ២០២១ ៖

  ការងារបុកស៊ីជាយនៅប្រឡាយទួលពង្រទី១ ប្រវែង 300m នៅភូមិទួលពង្រ សង្កាត់ចោមចៅទី១ សម្រេចបានលទ្ធផល 40%។

### ២. ៦. ៣. ២ ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ

- ឆ្នាំ២០១៩ ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកពុំទាន់រួច100% មានចំនួន 5ខ្សែមានប្រវែងសរុប 1,566m និងមានផ្ទៃក្រឡា 8,624m² មានដូចខាងក្រោមគឺ៖

១. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ1E ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 6cc-1 ដល់ក្នុងភូមិមានប្រវែង 292m x 6m x 0.15m = 1,752m² (ពីមុនជាផ្លូវដី)សម្រេចបាន70%

២. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកផ្លូវលេខ38E ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 1031(ផ្លូវអង្គតាម៉ិញ)ដល់ចំណុច Pko+251 មានប្រវែង251m x 7m x 0.15m 1,757m² (ពីមុនជាផ្លូវបេតុងឬស៊្វី)សម្រេចបាន20%

៣. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិកាកាបចាប់ពីផ្លូវរថភ្លើងដល់ផ្លូវលេខ 137K ភូមិកាកាប សង្កាត់កាកាបទី២មានប្រវែង 371m x 5m x 0.15m = 1,825m² (ពីមុនជាផ្លូវដី)សម្រេចបាន30%

៤. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិតិក្ខបញ្ញោ សង្កាត់សំរោងក្រោមចាប់ពីមហាវិថីឈ្នះ-ឈ្នះ ដល់ផ្លូវបំបែកភូមិចំការល្បែងមានប្រវែង 447m x 5m x 0.15m = 2,235m² (ពីមុនជាបេតុងឆ្អឹងដែក) សម្រេចបាន40%

៥. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃស្ពឺ សង្កាត់ចោមចៅទី២ ចាប់ពីផ្លូវវត្តព្រៃស្ពឺដល់ផ្លូវក្នុងផ្លូវក្នុងភូមិមានប្រវែង 205m x 4 <4m x 0.15m (ពីមុនជាផ្លូវដី) សម្រេចបាន40%។

- ឆ្នាំ២០២១ ការងារជីកដាក់បំពង់លូជ័រមូលទំហំមុខកាត់1m នៅផ្លូវលេខ1080 (ផ្លូវចូលវត្តឆ្លៀត)ភូមិស្រែរាជ្ជៈ, ភូមិអណ្តូងតាអន សង្កាត់សំរោងក្រោម ចាប់ពីមហាវិថីឈ្នះឈ្នះដល់ផ្លូវចូលភូមិព្រៃពពេល (ព្រំប្រទល់ខណ្ឌកំបូល) មានប្រវែង 1400m x 2 = 2800m សម្រេចលទ្ធផលបាន 14%។

## ២.៧.អត្ថប្រយោជន៍សម្រាប់ខណ្ឌពោធិ៍សែនជ័យ

ផ្លូវថ្នល់បានចូលរួមចំណែកយ៉ាងសំខាន់សម្រាប់ជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ និងបានចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទៅលើវិស័យសេដ្ឋកិច្ច។ ទាំងនេះគឺជាអត្ថប្រយោជន៍របស់ផ្លូវថ្នល់៖

### ២.៧.១.ប្រជាពលរដ្ឋ

ជាធម្មតាប្រជាពលរដ្ឋនៅតាមតំបន់នានាគឺត្រូវការផ្លូវថ្នល់សម្រាប់ធ្វើដំណើរក្នុងទិសដៅផ្សេងៗគ្នាដូចជាទៅធ្វើការ និង ប្រកបអាជីវកម្មជាដើម។ មួយវិញទៀតនៅពេលដែលប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធត្រូវបានរៀបចំបានទូលំទូលាយធ្វើអោយការធ្វើដំណើររបស់ប្រជាពលរដ្ឋប្រកបទៅដោយសុខសុវត្ថិភាព និងកាត់បន្ថយនូវគ្រោះថ្នាក់ចរាចរណ៍បានមួយភាគធំផងដែរ។ ដោយឡែកផ្លូវថ្នល់បានចូលរួមជួយនៅពេលដែលមានគ្រោះអាសន្ននានាបានយ៉ាងច្រើនដូចជារថយន្តសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យ និងប៉ូលីសជាដើមក្នុងការធ្វើអន្តរាគមន៍អោយបានទាន់ពេលវេលាជូនប្រជាពលរដ្ឋ។

### ២.៧.២.សេដ្ឋកិច្ច

ផ្លូវថ្នល់គឺជាសរសៃឈាមរបស់សេដ្ឋកិច្ចក្នុងការបម្លាស់ទីដើម្បីដឹកជញ្ជូនទំនិញពីកន្លែងមួយទៅកន្លែងមួយ និងនាំទំនិញចេញទៅក្រៅប្រទេសឬជួយទៅដល់អាជីវកម្មតាមរយៈការនាំចូលទំនិញចូលទៅកាន់ទីផ្សារ

បានឆាប់រហ័ស និងមានសុវត្ថិភាព។ ផ្លូវថ្នល់ដែលមានប្រសិទ្ធភាពវាជួយទៅដល់ការកាត់បន្ថយថ្លៃសេវាដឹកជញ្ជូន និងពេលវេលាបានយ៉ាងច្រើន ។[15]

## ២.៨.បញ្ហាប្រឈមនៃការអភិវឌ្ឍ និងដំណោះស្រាយ

➢ បញ្ហាប្រឈម

ក. អាកាសធាតុ និងពេលវេលា

អាកាសធាតុ គឺជាកត្តាកំណត់មួយដ៏មានសារៈសំខាន់ដែលមានឥទ្ធិពលដល់ការរស់នៅរបស់មនុស្សដែលយើងមិនអាចកំណត់បាន ផ្ទុយមកវិញអាកាសធាតុគឺជាអ្នកកំណត់ពីរបៀបដែលមនុស្សរស់នៅ របៀបនៃការស្លៀកពាក់ និងរបៀបនៃការហូបចុករបស់មនុស្សទៅវិញ។ ដូចគ្នានេះដែរនៅពេលរដូវវស្សាមកដល់ការងារជួសជុលស្ថាបនាផ្លូវត្រូវជួបប្រទះនឹងភាពលំបាកដោយសារតែទឹកភ្លៀងជោគជាំធ្វើឲ្យមានផលវិបាកក្នុងការចរាចរគ្រឿងចក្រ និងកម្មករនៅពេលកំពុងធ្វើការដូចជាទឹកលិចផ្លូវអង្គតាម៉ិញ សង្កាត់ចោមចៅទី១ ចាប់ពីប្រឡាយបារាំងដល់ស្ថានីយប្រេងតន្នះតេលា។ ម្យ៉ាងវិញទៀតនៅពេលដែលមានគ្រោះធម្មជាតិបានបណ្តាលឲ្យមានការរាំងស្ទះដល់ដំណើរការអភិវឌ្ឍផ្លូវ។

ខ. កង្វះកម្លាំងពលកម្ម

កម្លាំងពលកម្មគឺជាប្រភពសំខាន់របស់ប្រទេសកំពុងអភិវឌ្ឍគ្រប់កិច្ចការតែងតែត្រូវការប្រើប្រាស់នូវកម្លាំងពលកម្ម។ ដូចគ្នាដែរតម្រូវការកម្លាំងពលកម្មរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនក៏ជាកត្តាកំណត់នូវភាពជោគជ័យក្នុងការអភិវឌ្ឍផ្លូវថ្នល់ផងដែរ។ ការខ្វះនូវកម្លាំងពលកម្មគឺជាភាពរាំងស្ទះដល់ដំណើរការនៃការជួសជុលស្ថាបនាផ្លូវដែលមន្ទីរសាធារណការ និងដឹកជញ្ជូនកំពុងជួបប្រទះ។ ទាំងនេះគឺដោយសារតែការប្រកបរបរជាកម្មករនេះទទួលបានប្រាក់កម្រៃទាប និងត្រូវប្រើប្រាស់កម្លាំងពលកម្មខ្លាំងទើបប្រជាជនភាគច្រើនបានជ្រើសរើសធ្វើការរោងចក្រ ដូចច្នេះហើយធ្វើឲ្យនៅការដ្ឋានមានការខ្វះខាតកម្មករក្នុងការជួសជុលផ្លូវ។

គ. ថវិកាមានកំណត់

មូលធនគឺជាកត្តាកំណត់មួយដែលនាំឲ្យមាននូវឧបករណ៍ទំនើបៗក៏ជាប្រភពចាំបាច់មួយសម្រាប់ការចាប់ផ្តើមអភិវឌ្ឍន៍ផងដែរ។ ដោយសារតែថវិកាត្រូវបានគេចាត់ទុកជាឧបករណ៍ស្នូលសម្រាប់ចរាចរណ៍ដោះដូរទំនិញនានាដូចនេះហើយទើបបានធ្វើឲ្យមូលធនក្លាយទៅជាតម្រូវការដ៏ចាំបាច់មួយសម្រាប់មនុស្សក៏ដូចជាប្រទេសជាតិនានាក្នុងការអភិវឌ្ឍ។ សម្រាប់ការកសាង ស្ថាបនា និងការអភិវឌ្ឍផ្លូវថ្នល់វិញក៏ដូចគ្នាដែរនៅក្នុងមន្ទីរសាធារណការ និងដឹកជញ្ជូនត្រូវការការផ្តល់ថវិកាជាចាំបាច់ពីសំណាក់រាជរដ្ឋាភិបាល និងអង្គការម្ចាស់

[15] កិច្ចសម្ភាស៍ផ្ទាល់ជាមួយលោក នូ កែតសុគុណ ,ប្រធានការិយាល័យសាធារណៈការនិងដឹកជញ្ជូន, ខណ្ឌពោធិ៍សែនជ័យ

ជំនួយផ្សេងៗក្នុងការផ្តល់ជាថវិកានិងមូលធនដើម្បីធ្វើការអភិវឌ្ឍនូវកិច្ចការនៅក្នុងអង្គភាព។ ការកសាងស្ថាបនាផ្លូវនីមួយៗរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនត្រូវប្រើប្រាស់ថវិការដ្ឋដែលត្រូវបានកំណត់ទៅតាមជំពូកដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុន្តែការស្ថាបនាផ្លូវពេលខ្លះអាចនឹងមានការខ្វះខាតដោយសារតែបញ្ហាសេដ្ឋកិច្ចពិសេសបញ្ហាអតិផរណាដែលធ្វើឲ្យសម្ភារៈមានការឡើងថ្លៃដែលមិនត្រូវទៅតាមគម្រោងប៉ាន់ស្មានតម្លៃដែលបានគ្រោងទុក។

ឃ. អនុវត្តន៍ច្បាប់ចរាចរណ៍នៅមានកម្រិត

ច្បាប់ចរាចរណ៍គឺបង្កើតឡើងក្នុងគោលបំណងជួយរក្សាដល់សុវត្ថិភាពរបស់អ្នកធ្វើដំណើរ និងអ្នកបើកបរតាមផ្លូវ។ ច្បាប់ចរាចរណ៍នេះគឺមានសារសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋក៏ដូចជារដ្ឋាភិបាលដូចជាបញ្ចៀសរាល់គ្រោះថ្នាក់ជាយថាហេតុ និងជួយឲ្យផ្លូវអាចរក្សាគុណភាពបានយូរអង្វែង។ ដោយការអនុវត្តច្បាប់ចរាចរណ៍នៅក្នុងតំបន់នៅមានកម្រិតប្រជាជនមួយចំនួនមិនទាន់យល់ច្បាស់ពីបញ្ហាច្បាប់ចរាចរណ៍ និងសារៈសំខាន់របស់ផ្លូវដោយបានធ្វើការដឹកលើសទម្ងន់ដែលបណ្តាលឲ្យផ្លូវកំពុងជួសជុលនោះរងការខូចខាត។

ង. ប្រជាជនមិនសូវមានឆន្ទៈចូលរួមសហការ និងថែទាំផ្លូវ

ប្រជាជនជាបុគ្គលដែលសង្គមត្រូវការជាចាំបាច់ក្នុងប្រទេសជាតិនីមួយៗ។ ការកើនឡើងនៃប្រជាជនប្រកបដោយធនធាន និងសីលធម៌ល្អគឺជាអ្វីដែលប្រទេសមួយរំពឹងចង់បាន។ យ៉ាងណាមិញការរួមចំណែករបស់ប្រជាជនទាំងអស់ក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសក៏ជាកត្តាជំរុញឲ្យការអភិវឌ្ឍនោះទទួលបានភាពជោគជ័យយ៉ាងខ្លាំងក្លា។ បើយើងងាកមកមើលលើការអភិវឌ្ឍផ្លូវថ្នល់របស់យើងវិញឃើញថាការចូលរួមថែទាំផ្លូវថ្នល់ពីសំណាក់បងប្អូនប្រជាពលរដ្ឋបានជំរុញឲ្យមានភាពងាយស្រួលជាច្រើនដល់ដំណើរការនៃការអភិវឌ្ឍនេះក៏ប៉ុន្តែមានប្រជាជនមួយចំនួនដែលបានប្រកបរបរ លក់ដូរនៅលើផ្លូវសាធារណៈដែលនាំឲ្យមានការស្ទះចរាចាណ៍ពិបាកក្នុងការធ្វើដំណើរ និងប៉ះពាល់ដល់សោភ័ណ្ឌភាពផងដែរ។

ច. បច្ចេកវិទ្យានៅមានកម្រិត

បច្ចេកវិទ្យាជាកត្តាពន្លឿនដល់ការអភិវឌ្ឍ និងភាពជឿនលឿននៃសង្គម។ ការខ្វះខាតសម្ភារៈបរិក្ខាបច្ចេកទេសថ្មីៗ ឧបករណ៍ប្រើប្រាស់ គ្រឿងចក្រថ្មីៗ និងចំណេះដឹងថ្មីៗនៃបច្ចេកវិទ្យារបស់វិស្វករជាឧបសគ្គមួយដែលវិស្វករផ្លូវថ្នល់កំពុងជួបប្រទះដែលបញ្ហាទាំងអស់នេះបណ្តាលឲ្យការជួសជុលផ្លូវមិនទទួលបានគុណភាព និងមន្ត្រីមួយចំនួនពុំមានបច្ចេកទេសច្បាស់លាស់ទៅលើការជួសជុល។

៦ ដំណោះស្រាយ

ក. កត្តាអាកាសធាតុ

ដោយសារអាកាសធាតុគឺជាកត្តាធម្មជាតិដែលយើងមិនអាចកំណត់បាន ដូច្នេះហើយបានជាសាលាខណ្ឌពោធិ៍សែនជ័យបានខិតខំអនុវត្តន៍យ៉ាងមមាញឹកក្នុងដំណើរការកសាង និងស្តារនូវប្រព័ន្ធធារាសាស្ត្រឲ្យបានគ្រប់ច្រកល្ហកនៅក្នុងខណ្ឌទាំងមូល។ ការស្ថាបនានូវប្រព័ន្ធធារាសាស្ត្រដែលមានដូចជាការដាក់លូ និងការស្ថាបនាស្ពានតាមបណ្តាផ្លូវថ្នល់នានា ការជីកប្រលាយតាមដងផ្លូវដែលខណ្ឌបានកំពុងនឹងអនុវត្តន៍នេះគឺក្នុងគោលបំណងបញ្ចៀសនូវបញ្ហាទឹកលិចនៅរដូវវស្សា និងដើម្បីចែកចាយទឹកទៅឲ្យប្រជាពលរដ្ឋវិញនៅពេលរដូវប្រាំងមកដល់។

ខ. ស្វែងរកកម្លាំងពលកម្មថ្មី

ដើម្បីទទួលបាននូវកម្លាំងពលកម្មសម្រាប់ការអភិវឌ្ឍផ្លូវអង្គភាពអភិវឌ្ឍន៍ផ្លូវបានចុះទៅពន្យល់ណែនាំដល់ប្រជាពលរដ្ឋឲ្យយល់ពីផលវិបាកដែលបណ្តាលមកពីបញ្ហាផ្លូវនិងធ្វើការបញ្ចុះបញ្ចូលពួកគាត់ឲ្យងាកមកធ្វើការដោយធ្វើការផ្តល់ប្រាក់កម្រៃឲ្យបានសមស្របទៅនឹងកម្លាំងពលកម្មរបស់កម្មករ លើកទឹកចិត្តកម្មករដោយមានប្រាក់កម្រៃបន្ថែមលើការខិតខំធ្វើការ និងផ្តល់ជាប្រាក់ឧបត្ថម្ភនៅពេលដែលពួកគេមានជម្ងឺ។

គ. ស្នើសុំថវិកាបន្ថែមសម្រាប់ការជួសជុល និងទិញសម្ភារៈ

ដោយយោងទៅតាមស្ថានភាពជាក់ស្តែងនៃបញ្ហាសេដ្ឋកិច្ចទំនិញឡើងថ្លៃដូច្នេះថវិកាដែលត្រូវចំណាយមានការកើនឡើងដែលធ្វើឲ្យថវិកាគ្រោងនៅក្នុងគម្រោងចំណាយមានភាពខ្វះខាតដែលតម្រូវឲ្យមានការស្នើសុំថវិកាចំណាយតាមជំពូកបន្ថែម។ ដូច្នេះហើយទើបសាលាខណ្ឌខំចុះទៅសិក្សាស្វែងយល់ពីតម្លៃទំនិញក្នុងទីផ្សារថាតើទំនិញដែលមានតម្រូវការអាចនឹងឡើងតម្លៃប៉ុណ្ណាហើយធ្វើការប៉ាន់តម្លៃទំនិញនោះឲ្យស្ថិតនៅក្នុងការកើនឡើងដើម្បីកុំឲ្យមានការខ្វះខាតពេលអនុវត្តន៍ទៅលើគម្រោងលើកក្រោយ។

ឃ. ផ្សព្វផ្សាយច្បាប់ចរាចរណ៍

បើកវគ្គបណ្តុះបណ្តាលនិងលើកទឹកចិត្តដល់ប្រជាជន បង្កើនការផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ដោយចុះទៅដល់មូលដ្ឋានរបស់ប្រជាពលរដ្ឋដែលរស់នៅផ្ទាល់ដើម្បីឲ្យពួកគាត់បានជ្រួតជ្រាប និងបានរួមចំណែកក្នុងសង្គមក្នុងការជួយថែរក្សាផ្លូវសាធារណៈ និងគ្រោះថ្នាក់ឬផលវិបាកផ្សេងៗដែលបណ្តាលមកពីផ្លូវដែលមានការខូចខាតដូចជា៖ គ្រោះថ្នាក់ចរាចរណ៍ និងការខាតនូវប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគាត់ដែលត្រូវចំណាយទៅលើការធ្វើដំណើរលើផ្លូវដែលខូចខាត និងបន្ថែមនូវចំណេះដឹងថ្មីៗស្តីពីច្បាប់ចរាចរណ៍ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងខណ្ឌទាំងមូល។

ង. ធ្វើការដាក់ពិន័យធ្ងន់ធ្ងរដល់អ្នកប្រព្រឹត្តល្មើសច្បាប់

ធ្វើការណែនាំជាការពិន័យធ្វើឡើងក្នុងគោលបំណងរឹតបន្តឹងច្បាប់ចរាចរណ៍ និងរក្សាសុវត្ថិភាពដល់អ្នកធ្វើចរាចរណ៍នៅលើដងផ្លូវក៏ដូចជាជួយរក្សានូវគុណភាពផ្លូវឲ្យប្រើប្រាស់បានយូរអង្វែង និងអប់រំដល់ជនដែលតែងតែដឹកទំនិញលើសទម្ងន់កំណត់ដែលជាហេតុនាំឲ្យកើតមាននូវគ្រោះថ្នាក់ចរាចរណ៍។

ច. បញ្ជូនមន្ត្រីបច្ចេកទេសទៅសិក្សាបន្ថែម

ការបន្ថែមចំណេះដឹងពីបច្ចេកទេសថ្មីៗដល់មន្ត្រីជំនាញគឺនាំឲ្យមានប្រសិទ្ធភាព និងធ្វើឲ្យមានភាពជោគជ័យក្នុងការសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍរបស់សាលាខណ្ឌ ។ ការវិវត្តថ្មីរបស់បច្ចេកវិទ្យាបានក្លាយទៅជាមុខព្រួញយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍប្រកបទៅដោយចីរភាព ជាពិសេសសម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។ ដូច្នេះដើម្បីរក្សាឲ្យបាននូវការបន្តការអភិវឌ្ឍគឺយើងមិនត្រូវមើលរំលងពីការបណ្តុះបណ្តាលធនធានមនុស្សរបស់យើងឲ្យយល់ច្បាស់ពីការអភិវឌ្ឍនៃកម្រិតបច្ចេកវិទ្យានិងយកនូវចំណេះដឹងល្អៗទាំងនោះមកធ្វើការអភិវឌ្ឍប្រទេសរបស់យើងឲ្យមានភាពរីកចម្រើនមិនឲ្យចាញ់ប្រទេសជិតខាងឡើយ។

# ជំពូកទី៣
# ការវិភាគទិន្នន័យនៃការអភិវឌ្ឍហេដ្ឋារចនាស
# ម្ព័ន្ធដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ
# ២០១៩ដល់២០២១

# ជំពូកទី៣
# ការវិភាគទិន្នន័យនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១

## ៣.១.ទិន្នន័យផ្លូវដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១

សាលាខណ្ឌពោធិ៍សែនជ័យបានខិតខំប្រឹងប្រែងគួរអោយកត់សម្គាល់ក្នុងការអភិវឌ្ឍទៅលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ពីមួយឆ្នាំទៅមួយឆ្នាំព្រោះថាបច្ចុប្បន្ននេះផ្លូវថ្នល់នៅមិនទាន់មានការអភិវឌ្ឍបានប្រសើរឡើយ។ វាធ្វើអោយមានផលលំបាកទៅដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ និងប៉ះពាល់ទៅដល់វិស័យមួយចំនួនផងដែរ។ ក្នុងនោះផងដែរ ខណ្ឌពោធិ៍សែនជ័យបានជួយសម្រួលក្នុងការអភិវឌ្ឍផ្លូវជូនដល់ប្រជាពលរដ្ឋដើម្បីងាយស្រួលក្នុងការធ្វើដំណើរ និងប្រកបដោយសុខសុវត្ថិភាពនៅតាមតំបន់នៅក្នុងខណ្ឌទាំងមូលផងដែរ។ សរុបមកនៅឆ្នាំ២០១៩បានធ្វើការអភិវឌ្ឍបានសម្រេច១០០ភាគរយមានចំនួន៣១ខ្សែត្រូវនឹង១២,១៨៩ម៉ែត្រ ២០២០មាន១៩ខ្សែត្រូវនឹង ១២,៣២៤ម៉ែត្រ និងនៅឆ្នាំ ២០២១មាន១៦ខ្សែត្រូវនឹង៣,៤៤៥ម៉ែត្រ។

### ៣.១.១.តារាងទិន្នន័យផ្លូវថ្នល់ដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១

ចំនួន និងប្រវែងផ្លូវថ្នល់ ដែលខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍឆ្នាំ២០១៩ បានសម្រេច១០០ភាគរយបានចំនួន ៣១ខ្សែត្រូវនឹង ១២,១៨៩ម៉ែត្រ ២០២០បាន១៩ខ្សែត្រូវនឹង ១២,៣២៤ម៉ែត្រ និងនៅឆ្នាំ ២០២១ បាន១៦ខ្សែត្រូវនឹង៣,៤៤៥ម៉ែត្រ។

តារាង៣.១.១ ទិន្នន័យផ្លូវដែលសម្រេចបាន១០០%ពីឆ្នាំ២០១៩ដល់២០២១

| ឆ្នាំ | ចំនួនផ្លូវ | ប្រវែងគិតជាម៉ែត្រ |
|---|---|---|
| ២០១៩ | ៣១ | ១២,១៨៩ម៉ែត្រ |
| ២០២០ | ១៩ | ១២,៣២៤ម៉ែត្រ |
| ២០២១ | ១៦ | ៣,៤៤៥ម៉ែត្រ |

ឧបសម្ព័ន្ធទី២៖ របាយការណ៍លទ្ធផលអនុវត្តការងារឆ្នាំ២០១៩,២០២០,២០២១ របស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ។

### ៣.១.២.ក្រាហ្វិកផ្លូវថ្នល់ដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១

យោងតាមតារាងទិន្នន័យខាងលើយើងបានក្រាហ្វិកដូចខាងក្រោម៖

ក្រាហ្វិកទិន្នន័យ៖ផ្លូវថ្នល់ដែលសម្រេចបានរបស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យឆ្នាំ២០១៩ដល់២០២១

ក្រាបទី១ ៖ចំនួននិងប្រវែងផ្លូវសរុបដែលសម្រេចបាន






### ៣. ១. ៣ ការវិភាគនិងបកស្រាយទិន្នន័យផ្លូវថ្នល់តាមក្រាហ្វិកដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១

ការវិភាគតាមក្រាហ្វិកខាងលើនេះបានបង្ហាញអោយឃើញថាចំនួននិងប្រវែងផ្លូវដែលរដ្ឋបាលខណ្ឌពោធិ៍សែនជ័យបានអភិវឌ្ឍន៍ និងមូលហេតុដែលមានការធ្លាក់ចុះតាមឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩ដល់២០២១មានស្ថានភាពដូចខាងក្រោមនេះ៖

- នៅឆ្នាំ២០១៩ យើងសង្កេតឃើញថាចំនួនផ្លូវដែលសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍពេញមួយឆ្នាំដោយមានថវិកាគាំទ្រមាន៤ប្រភពធំៗហើយបានចំនួន៣១ខ្សែ និងមានប្រវែង១២,១៨៩ម៉ែត្រ បើប្រៀបធៀបទៅឆ្នាំ២០២០ ដែលមានត្រឹមតែ១៩ខ្សែតែប៉ុណ្ណោះ និងមានប្រវែង១២,៣២៤ម៉ែត្រ ដូច្នេះយើងសង្កេតឃើញថាទោះបីជាឆ្នាំ២០១៩មានការអភិវឌ្ឍបានច្រើនខ្សែ ប៉ុន្តែវាមានប្រវែងខ្លីជាងឆ្នាំ២០២០ ដល់ទៅ១៣៥ម៉ែត្រ កើនឡើងត្រូវនឹង១.១%នៃឆ្នាំ២០១៩ នេះអាចនិយាយបានថានៅឆ្នាំ២០១៩មានការអភិវឌ្ឍច្រើនមែនតែមានប្រវែងខ្លីៗតែប៉ុណ្ណោះ។
- នៅឆ្នាំ២០២០ យើងសង្កេតឃើញថាចំនួនផ្លូវដែលសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍពេញមួយឆ្នាំដោយមានថវិកាគាំទ្រមានត្រឹមតែ២ប្រភពធំៗតែប៉ុណ្ណោះ ហើយបានចំនួន១៩ខ្សែនិងមានប្រវែង១២,៣២៤ម៉ែត្រ បើប្រៀបធៀបទៅឆ្នាំ២០២១មានការអភិវឌ្ឍត្រឹមតែ៤ខ្សែប៉ុណ្ណោះ និងមានប្រវែង៣,៤៤៥ម៉ែត្រ ដូចនេះយើងសង្កេតឃើញថាឆ្នាំ២០២០មានប្រវែងវែងជាងឆ្នាំ២០២១ ដល់ទៅ៨,៨៧៩ម៉ែត្រនេះអាចនិយាយបានថាឆ្នាំ២០២១មានការថយចុះ៧២%។
- នៅឆ្នាំ២០២១ យើងសង្កេតឃើញថាចំនួនផ្លូវដែលសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍពេញមួយឆ្នាំដោយមានថវិកាគាំទ្រមានត្រឹមតែ២ប្រភពធំៗតែប៉ុណ្ណោះ ហើយបានចំនួនត្រឹមតែ១៦ខ្សែ និងមានប្រវែងត្រឹមតែ៣,៤៤៥ម៉ែត្រ បើប្រៀបធៀបទៅឆ្នាំទាំងពីរខាងលើយើងឃើញថាឆ្នាំនេះគឺបានអភិវឌ្ឍន៍តិចជាងឆ្នាំ២០១៩ រហូតដល់៨,៧៤៤ម៉ែត្រថយចុះត្រូវនឹង៦០.៦០% និងឆ្នាំ២០២១តិចជាងរហូតទៅដល់៨,៨៧៩ម៉ែត្រថយចុះត្រូវនឹង៦១.២០%។

### ៣.២.ទិន្នន័យលូដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១

ដោយមើលឃើញពីផលលំបាកនៃការស្ទះលូ និងគ្មានប្រព័ន្ធបង្ហូរទឹកបានគ្រប់គ្រាន់ដូចនេះសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍទៅលើប្រព័ន្ធលូដើម្បីសម្រួលទៅដល់ប្រជាពលរដ្ឋដើម្បីទប់ស្កាត់ពីការលិចនៅតាមភូមិ សង្កាត់និងមានប្រព័ន្ធបង្ហូរទឹកអោយបានត្រឹមត្រូវនិងមានអនាម័យនៅតាមតំបន់មួយចំនួនផងដែរ។ សុរបមកនៅឆ្នាំ ២០១៩ បានធ្វើការអភិវឌ្ឍទៅលើប្រព័ន្ធលូបានចំនួន ២៤ខ្សែមានប្រវែង១២,៤៩២ម៉ែត្រ ឆ្នាំ២០២០បាន ២១ខ្សែត្រូវនឹង១១,៣០៧ម៉ែត្រ និងឆ្នាំ២០២១បាន៩ខ្សែត្រូវនឹង៤,៤១៤ម៉ែត្រ។

### ៣.២.១.តារាងទិន្នន័យលូដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១

ចំនួន និងប្រវែងលូដែលខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍបានសម្រេច១០០ភាគរយនៅឆ្នាំ២០១៩ អភិវឌ្ឍន៍ទៅលើប្រព័ន្ធលូបានចំនួន ២៤ខ្សែមានប្រវែង១២,៤៩២ម៉ែត្រ ឆ្នាំ២០២០បាន២១ខ្សែត្រូវនឹង១១,៣០៧ម៉ែត្រ និងឆ្នាំ២០២១បាន៩ខ្សែត្រូវនឹង៤,៤១៤ម៉ែត្រ។

តារាង៣.២.១ ៖ទិន្នន័យលូដែលសម្រេចបាន១០០%ពីឆ្នាំ២០១៩ដល់២០២១

| ឆ្នាំ | ចំនួនលូ | ប្រវែងគិតជាម៉ែត្រ |
|---|---|---|
| ២០១៩ | ២៤ | ១២,៤៩២ម៉ែត្រ |
| ២០២០ | ២១ | ១១,៣០៧ម៉ែត្រ |
| ២០២១ | ៩ | ៤,៤១៤ម៉ែត្រ |

ឧបសម្ព័ន្ធទី២ របាយការណ៍លទ្ធផលអនុវត្តការងារឆ្នាំ២០១៩,២០២០,២០២១ របស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ។

### ៣.២.២.ក្រាហ្វិកលូដែលសម្រេចបានឆ្នាំ២០១៩ដល់២០២១

ក្រាហ្វិកទិន្នន័យៈលូដែលសម្រេចបានរបស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យឆ្នាំ២០១៩ដល់២០២១







### ៣.២.៣.ការវិភាគនិងបកស្រាយទិន្នន័យលូតាមក្រាហ្វិកដែលខណ្ឌពោធិ៍សែនជ័យសម្រេចបានពីឆ្នាំ២០១៩ដល់២០២១

ការវិភាគតាមក្រាហ្វិកខាងលើនេះបានបង្ហាញអោយឃើញថាចំនួននិងប្រវែងលូដែលរដ្ឋបាលខណ្ឌពោធិ៍សែនជ័យបានអភិវឌ្ឍន៍ និងមូលហេតុដែលមានការធ្លាក់ចុះតាមឆ្នាំនីមួយៗចាប់ពីឆ្នាំ២០១៩ដល់២០២១មានស្ថានភាពដូចខាងក្រោម៖

- នៅក្នុងឆ្នាំ២០១៩យើងសង្កេតឃើញថាចំនួនលូដែលសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍពេញមួយឆ្នាំដោយមានថវិកាគាំទ្រមាន៤ប្រភេទធំៗហើយបានចំនួន២៤ខ្សែ និងមានប្រវែង១២,៤៩២

ម៉ែត្រ បើប្រៀបធៀបទៅឆ្នាំ២០២០ដែលមានត្រឹមតែ២១ខ្សែតែប៉ុណ្ណោះ និងមានប្រវែង១១,៣០៧ម៉ែត្រ ដូច្នេះយើងសង្កេតឃើញថានៅឆ្នាំ២០១៩មានការអភិវឌ្ឍបានច្រើនខ្សែជាងឆ្នាំ២០២០ ដល់ទៅ៣ខ្សែ ន មានប្រវែង១,១៨៥ម៉ែត្រស្មើនឹង៩.៤៨%នេះអាចនិយាយបានថានៅឆ្នាំ២០១៩មានការអភិវឌ្ឍច្រើន ជាងឆ្នាំ២០២០ ។

- នៅឆ្នាំ២០២០ យើងសង្កេតឃើញថាចំនួនលូដែលសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍពេញ មួយឆ្នាំដោយមានថវិកាគាំទ្រមានត្រឹមតែ៣ប្រភពធំៗតែប៉ុណ្ណោះ ហើយបានចំនួន២១ខ្សែ និងមាន ប្រវែង១១,៣០៧ម៉ែត្រ បើប្រៀបធៀបទៅឆ្នាំ២០២១មានការអភិវឌ្ឍត្រឹមតែ៩ខ្សែប៉ុណ្ណោះ និងមានប្រវែង ៤,៤១៤ម៉ែត្រ ដូចនេះយើងសង្កេតឃើញថាឆ្នាំ២០២០នេះគឺជាឆ្នាំដែលបានអភិវឌ្ឍន៍បានច្រើនជាងឆ្នាំ ២០២១ចំនួន១២ខ្សែត្រូវនឹង៦,៨៩៣ម៉ែត្រដែលស្មើនឹង៣៥.៩៤%។
- ចំណែកឯឆ្នាំ២០២១ យើងសង្កេតឃើញថាចំនួនលូដែលសាលាខណ្ឌពោធិ៍សែនជ័យបានធ្វើការ អភិវឌ្ឍពេញមួយឆ្នាំដោយមានថវិកាគាំទ្រមានត្រឹមតែ២ប្រភពធំៗតែប៉ុណ្ណោះ ហើយបានចំនួនត្រឹមតែ៩ ខ្សែ និងមានប្រវែងត្រឹមតែ៤,៤១៥ម៉ែត្រ បើប្រៀបធៀបទៅឆ្នាំទាំងពីរខាងលើយើងឃើញថាឆ្នាំនេះគឺ បានអភិវឌ្ឍន៍តិចជាងគេក្នុងនោះតិចជាងឆ្នាំ២០១៩ចំនួន១៥ខ្សែត្រូវនឹង៨,០៧៨ម៉ែត្រស្មើនឹង ៤៥.៣៤%និងឆ្នាំ២០២០ចំនួន១២ខ្សែត្រូវនឹង៦,៨៩៣ម៉ែត្រស្មើនឹង៣៥.៩៤%ដោយសារនៅក្នុងឆ្នាំ ២០២១នេះគឺជាឆ្នាំដែលមានថវិកាគាំទ្រតិចតួចបំផុតទើបធ្វើអោយមានភាពយឺតយ៉ាវក្នុងការអភិវឌ្ឍ ជាងឆ្នាំនានា។

យោងតាមការវិភាគខាងលើយើងឃើញថាការអភិវឌ្ឍទៅលើផ្លូវថ្នល់ និងការរៀបចំប្រព័ន្ធលូចាប់ពីឆ្នាំ ២០១៩ដល់២០២១មានការធ្លាក់ចុះជាលំដាប់។ ដោយសារក្នុងរយៈពេល៣ឆ្នាំនេះប្រទេសយើងទទួលរងនូវ វិបត្តិនៃការរីករាលដាលនៃជំងឺកូវីត១៩ និងមិនសូវមានថវិកាគាំទ្រនានាទើបធ្វើអោយការអភិវឌ្ឍមានការធ្លាក់ចុះ បែបនេះ។ ក្នុងនោះផងដែរលោកអភិបាលនៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ និងមន្ត្រីដែលពាក់ព័ន្ធក្នុង បញ្ហានេះបាននឹងកំពុងតែពុះពារ ខិតខំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឡើងវិញ។

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ហេដ្ឋារចនាសម្ព័ន្ធដែលទទួលបាននូវការរៀបចំល្អបានធ្វើឲ្យវិស័យសេដ្ឋកិច្ចមានភាពរីកចម្រើននៅក្នុងតំបន់ក៏ដូចជានៅទូទាំងប្រទេសព្រោះថាហេដ្ឋារចនាសម្ព័ន្ធប្រៀបដូចជាសរសៃឈាមសេដ្ឋកិច្ចមួយរបស់ជាតិដែលមិនអាចខ្វះបានដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរ។ ដូច្នេះហើយទើបប្រទេសកម្ពុជាខិតខំប្រឹងប្រែងកសាងឡើងវិញ និងបន្តស្តារនូវហេដ្ឋារចនាសម្ព័ន្ធដែលធ្វើឲ្យមានភាពងាយស្រួលដល់ប្រជាជន ជាពិសេសការធ្វើអាជីវកម្ម និងពាណិជ្ជកម្មផ្សេងៗក្នុងគោលបំណងឲ្យប្រជាជនអាចបង្កើននូវប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារក៏ដូចជាធ្វើឲ្យមានកំណើនសេដ្ឋកិច្ចជាតិ។

ការខិតខំប្រឹងប្រែងរបស់សាលាខណ្ឌពោធិ៍សែនជ័យគោលបំណងគឺដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការរស់នៅ និងការធ្វើដំណើរប្រចាំថ្ងៃ។ ដោយយើងសង្កេតឃើញថាមុនពេលមិនទាន់មានការសាងសង់ផ្លូវ និង ស្តារប្រឡាយការរស់នៅរបស់ប្រជាជនបានជួបប្រទះនូវបញ្ហាក្នុងការធ្វើដំណើរដោយសារផ្លូវមានសភាពខូចខាត មានជុំថ្ម និងហុយដី ហើយក៏បង្កផលរំខានដល់អ្នករស់នៅទីនោះជាពិសេសប៉ះពាល់ដល់អាជីវកម្មរបស់ពួកគេ។ ចំណែកនៅរដូវវស្សាពេលមានភ្លៀងខ្លាំងម្តងៗមានការលិចជាច្រើនថ្ងៃដែលនាំមកនូវការលំបាកក្នុងការរស់នៅ ប្រកបរបរ និងការធ្វើដំណើរ។ ក្រោយពេលមានការសាងសង់ និងស្តារប្រឡាយ ការរស់នៅរបស់ប្រជាជនមានភាពល្អប្រសើរជាងមុនព្រោះការធ្វើដំណើរមានភាពងាយស្រួល មានផ្លូវច្រើនខ្វាត់ខ្វែង ជាពិសេសការលិចក៏មិនយូរដូចមុនទៀតដែរ នេះក៏ព្រោះតែខណ្ឌពោធិ៍សែនជ័យបានធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពីមួយឆ្នាំទៅមួយឆ្នាំ។ការអភិវឌ្ឍប្រកបដោយសមភាព និង ចីរភាពអាចនាំមកនូវកំណើនសេដ្ឋកិច្ចពីដំណើរការនេះ។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីធ្វើការស្រាវជ្រាវរួចមក យើងទាំងពីរនាក់សូមមានយោបល់ខ្លះៗជាគំនិតសម្រាប់សកម្មភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌមានដូចជា៖

- ❖ លើកទឹកចិត្តដល់ប្រជាជនឱ្យចូលរួមថែរក្សាផ្លូវ
- ❖ រកដៃគូសហការនិងអង្គការផ្សេងៗដើម្បីជួយដល់ការអភិវឌ្ឍឱ្យបានទាន់ពេលវេលា
- ❖ បង្កើតគោលការណ៍យ៉ាងតឹងរឹុងចំពោះរថយន្តដែលដឹកលើសទម្ងន់ និងអ្នកដែលប្រព្រឹត្តខុសច្បាប់
- ❖ បង្កើតគណៈកម្មការថែទាំ និងត្រួតពិនិត្យផ្លូវជាប្រចាំ
- ❖ បង្កើតគោលការណ៍ថែទាំប្រចាំណាមួយដែលមានប្រសិទ្ធភាព និងអាចរក្សាគុណភាពផ្លូវបានយូរ
- ❖ ប្រមូលវិភាគទានពីអ្នកប្រើប្រាស់ផ្លូវដើម្បីផ្គត់ផ្គង់ដល់ការថែទាំផ្លូវ

- ❖ រដ្ឋាភិបាលគួរផ្តល់ថវិកាឲ្យបានទាន់ពេលវេលាចំពោះគម្រោងអភិវឌ្ឍន៍ផ្លូវដែលបានដាក់ជូនដោយសាលាខណ្ឌ
- ❖ ជួយថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

# ឯកសារយោង

# ឯកសារយោង

- ការិយាល័យរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- កម្មវិធីវិនិយោគបីឆ្នាំរំកិល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- កិច្ចសម្ភាស៍ផ្ទាល់ជាមួយលោក នូ កែតសុគុណ ប្រធានការិយាល័យសាធារណៈការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និង សណ្តាប់ធ្នាប់សាធារណៈ
- របាយការណ៍លទ្ធផលការងារ ក្នុងរយៈពេលមួយឆ្នាំ ២០១៩ ២០២០ ២០២១ របស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត អ៊ឹង ហ្គេចលី និង ឡេង វួចនា ឆ្នាំ២០១៩ ទំព័រទី ៩
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត អ៊ឹង ហ្គេចលី និង ឡេង វួចនា ឆ្នាំ២០១៩ ទំព័រទី ១២
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ករណីឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង របស់និស្សិត អ៊ឹង ហ្គេចលី និង ឡេង វួចនា ឆ្នាំ២០១៩ ទំព័រទី ១១-១២
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តស្វាយរៀង របស់និស្សិត ឡាយ សុវណ្ណ និង ហោ សាងសាង ឆ្នាំ២០១៣ ទំព័រទី ១៧
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តស្វាយរៀង របស់និស្សិត ឡាយ សុវណ្ណ និង ហោ សាងសាង ឆ្នាំ២០១៣ ទំព័រទី ១៣-១៤
- របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាស្តីពី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តស្វាយរៀង របស់និស្សិត ឡាយ សុវណ្ណ និង ហោ សាងសាង ឆ្នាំ២០១៣ ទំព័រទី ១៥-១៦
- បទដ្ឋានណែនាំសម្រាប់អនុវត្តការងារ ថែទាំតាមរយៈកាល(ខួប) ,ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០១២, ទំព័រទី៣
- ទីស្តីការគណៈរដ្ឋមន្ត្រី, យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ចតិកោណ ទី២.ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, មុំទី១. ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍, ឆ្នាំ ២០០៤, ទំព័រទី ៣៦
- Wikipedia

# ឧបសម្ព័ន្ធទី១


PHNOM PENH
KANDAL PROVINCE
Khan Pou Senchey
42
4
3
Angk Snuol
អង្គស្នួល
KANDAL PROVINCE
PHNOM PENH
Prey Sar
ភូមិព្រៃសរ
3

# រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ



លោក សក់ ច័ន្ទកញ្ញារិទ្ធ
អភិបាល នៃគណៈអភិបាលខណ្ឌ



លោក ផុន សុផាន
អភិបាលរងខណ្ឌ



លោក ព្រាប ម៉ាណែល
អភិបាលរងខណ្ឌ



លោក ប៉ាង លីដា
អភិបាលរងខណ្ឌ



លោកស្រី ឈុន ស៊ុននី
អភិបាលរងខណ្ឌ



លោក យិន គា
អភិបាលរងខណ្ឌ



លោក ឈួន ឆាយារិទ្ធ
នាយក រដ្ឋបាលខណ្ឌ



លោកស្រី គា គឹមយី
នាយិការង រដ្ឋបាលខណ្ឌ



លោក សំ សារ៉ាវុធ
នាយករង រដ្ឋបាលខណ្ឌ



លោក លាង ដេវីត
នាយករង រដ្ឋបាលខណ្ឌ



លោក ម៉ាលី ពិសិដ្ឋ
ប្រ.ការិលេខាធិការក្រុមប្រឹក្សា



លោកស្រី ប៊ុត ដានី
ប្រ.អង្គភាពលទ្ធកម្ម



លោក ព្រំ តុក្ការា
ប្រ.ការិរដ្ឋបាល និងបុគ្គលិក



លោក សំ ឆា
ប្រ.ការិសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍



លោក ឈួង សីហៈ
ប្រ.ការិ ដ.ន.ស.ភ



លោកស្រី ធួន ធូនិម៉ា
ប្រ.ការិផែនការ និងហិរញ្ញវត្ថុ



លោក ទូ កែតសុគុណា
ប្រ.ការិ ស.ជ.អ.ប.ស



លោក ឃឹម តារាស្មៀ
ប្រ.ការិសង្គមកិច្ច និងសុខុមាលភាពសង្គម



លោក គឹម ឈុនណាយ៉ាម៉ាកែន
ប្រ.ការិច្រកចេញចូលតែមួយ



លោក ផាង ផារី
ប្រ.ការិនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន



លោក ពេជ្រ សារ៉ុម
ប្រ.ការិអប់រំ យុវជន និងកីឡា

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
ការិ.សាធារណការ និងដឹកជញ្ជូនខណ្ឌពោធិ៍សែនជ័យ
លេខ៖ ១៣/១៩..... របក

## សូមគោរពជូន
## លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ លទ្ធផលអនុវត្តការងារ ក្នុងរយៈពេលមួយឆ្នាំ ២០១៩។

សេចក្ដីដូចមានចែងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន លោកប្រធានមន្ទីរមេត្តាជ្រាបថា៖ ចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៩ មានលទ្ធផលដូចខាងក្រោម៖

### ១. ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ

**ក. ចំនួនផ្លូវបានជួសជុលដោយចាក់បេតុងឆ្អឹងដែករួច 100% ចំនួន 9 ខ្សែមានប្រវែងសរុប 4,961m និងមានផ្ទៃក្រឡាចំនួន 38,295m² មានដូចខាងក្រោម៖**

1. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 1998 ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ពីផ្លូវលេខ110 ដល់ផ្លូវភូមិត្រពាំងជ្រៃមានប្រវែង 1,728m x 8m x 0.15m = 13,824m²( ពីមុន ជាផ្លូវដី + បេតុងឬស៊ី )។

2. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 107B ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ចាប់ពីផ្លូវលេខ110 ដល់ផ្លូវលេខ 1998 មានប្រវែង 430m x 7m x 0.15m = 3,010m² ( ពីមុនជាផ្លូវ បេតុងឬស៊ី )។

3. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 123cc ភូមិត្រពាំងថ្លឹង៣ និងភូមិថ្មគោល២ ស្ថិតក្នុងសង្កាត់ចោមចៅទី១ និងសង្កាត់ចោមចៅទី២ ចាប់ពីផ្លូវលេខ 1031(ផ្លូវអង្គតាម៉ិញ)ដល់ផ្លូវ លេខ 8cc (ផ្លូវថ្មគោល )មានប្រវែង 833m x 7m x 0.15m = 5,831m² ( ពីមុនជាបេតុងឆ្អឹងដែក )។

4. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 1084 ភូមិស្រែរាជ្ជៈ សង្កាត់សំរោងក្រោមចាប់ពីមហាវិថីឈ្នះ-ឈ្នះ (PK0+00) ដល់ចំណុចPKo + 320 ភូមិអង្គតាកូវ សង្កាត់គោករកា មានប្រវែង 320m x 9m x 0.20m = 2,880m² ( ពីមុនជាផ្លូវបេតុងឆ្អឹងដែក )។

5. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 1979 ភូមិព្រៃព្រីងខាងត្បូង២ និងភូមិ ថ្នល់បំបែក សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវជាតិលេខ៣ ដល់ផ្លូវជាតិលេខ៤ មានប្រវែង 450m x 7m x 0.15m = 3,150m² ( ពីមុនជាផ្លូវបេតុងឬស៊ី )។

CS Scanned with CamScanner

6. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ123K2 (ចាប់ពីផ្លូវលេខ110k ដល់ផ្លូវលេខ114k ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ ប្រវែង 440m x 8m x 0.15m = 3,520$m^2$( ពីមុនជាផ្លូវបេតុងឬ ស្បឺ)។

7. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ133KH (ចាប់ពីផ្លូវលេខ114k ដល់ផ្លូវលេខ133KE) ស្ថិតនៅភូមិជម្ពូវន្ត២ សង្កាត់ចោមចៅទី៣ ប្រវែង 280m x 8m x 0.15m = 2,240$m^2$( ពីមុនជាផ្លូវបេតុងឬស្បឺ) ។

8. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ133KE (ចាប់ពីផ្លូវលេខ133KR ដល់ផ្លូវក្នុងភូមិ) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ ប្រវែង 360m x 6m x 0.15m = 2,160$m^2$( ពីមុនជាផ្លូវបេតុងឬ ស្បឺ)។

9. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ133KF (ចាប់ពីផ្លូវលេខ133KH ដល់ផ្លូវក្នុងភូមិ) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ ប្រវែង 280m x 6m x 0.15m = 1,680$m^2$( ពីមុនជាផ្លូវបេតុងឬ ស្បឺ)។

**ខ. ចំនួនផ្លូវដែលបានជួសជុលដោយចាក់បេតុងឆ្អឹងដែកពុំទាន់រួច១០០%មានចំនួន 2ខ្សែមានប្រវែងសរុប 2,495m និងមានផ្ទៃក្រឡាសរុបចំនួន 27, 460$m^2$ មានដូចជា៖**

1. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ១ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 110 ដល់ផ្លូវមុខរោងចក្រ វ៉ន វ៉ិច (ផ្លូវ110K) មានប្រវែង 1255m x 12m x 0.20m = 15,060$m^2$ សម្រេចបាន65% ពីមុនជាផ្លូវបេតុងឆ្អឹងដែក + ផ្លូវដី ស)។

2. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ1031 (ផ្លូវអង្គតាម៉ិញ) ចាប់ពីផ្លូវលេខ 110 ដល់ផ្លូវលេខ 2004 ស្ថិតក្នុងសង្កាត់កាកាបទី១ និងសង្កាត់អូរបែកក្អមមានប្រវែង 1240m x 101m x 0.20m = 12,40$m^2$ (ពីមុនជាផ្លូវបេតុងឬស្បឺ)។

**គ. ការងារជីកដាក់លូចំនួន 12ខ្សែ (ទំហំចាប់ពី 0.6m ដល់ 2.5m x 2.5m) មានប្រវែងសរុប មានដូចខាងក្រោម៖**

1. ការងារជីកដាក់លូមូលទំហំ 1.50 នៅផ្លូវលេខ 110 ចាប់ពីរង្វង់មូលចោមចៅ ដល់ផ្លូវលេខ 9K មានប្រវែង3,400mនិងពីផ្លូវលេខ9K ដល់ផ្លូវលេខ2011 លូទំហំមុខកាត់1m ប្រវែង ៤០០ម( សម្រេចបាន100%)។

2. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ 123cc ភូមិថ្មគោល២ និងភូមិត្រពាំងថ្លឹង៣ ស្ថិតក្នុងសង្កាត់ចោមចៅទី២ និងសង្កាត់ចោមចៅទី១ ចាប់ពីផ្លូវបេតុងលេខ 8cc ដល់ផ្លូវលេខ 1031 (ផ្លូវអង្គតាម៉ិញ) មានប្រវែង 1,666m ។

3. ការងារជីកដាក់លូមូលទំហំ 1m នៅផ្លូវលេខ 1084 ភូមិស្រែរាជ្ជ: សង្កាត់សំរោងក្រោម ចាប់ ពីមហាវិថីឈ្នះ-ឈ្នះ (PK0+00) ដល់ចំណុចPKo + 320ភូមិអង្គតាកូវ សង្កាត់គោករកា មានប្រវែង 640m (សម្រេចបាន 100%)។

4. ការងារជីកដាក់លូមូលទំហំ 1m នៅផ្លូវលេខ 59ccភូមិចោមចៅ២ សង្កាត់ចោមចៅទី២ ចាប់ពីផ្លូវចោមចៅដល់ប្រឡាយមេ មានប្រវែង 782m (សម្រេចបាន100%)។

Scanned with CamScanner

5. ការងារជីកដាក់លូមូលទំហំ 1m មានប្រវែង 173m នៅផ្លូវភូមិថ្មគោល២ សង្កាត់ចោមចៅទី២ (សម្រេចបាន100%)។

6. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ 1979 ភូមិព្រៃព្រីងខាងត្បូង២ និងភូមិថ្នល់ បំបែកសង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវជាតិលេខ៣ ដល់ផ្លូវជាតិលេខ៤ មានប្រវែង 450m សម្រេចបាន 100%។

7. ការងារជីកដាក់លូមូលភ្លោះទំហំ 1.50m ក្នុងប្រឡាយត្រពាំងជ្រៃចំនួនពីរ ទីតាំងមានប្រវែង 260m (សម្រេចបាន70%)។

8. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ 68k និងផ្លូវ 60k ភូមិចំការឪឡឹក១ និងភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 2011 មានប្រវែង 1,320m សម្រេច បាន100%។

9. ការងារជីកដាក់លូមូលទំហំ0.60m អមសងខាងផ្លូវលេខ១ភូមិព្រៃជីសាក់សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 110 ដល់ផ្លូវបេតុងមុខរោងចក្រ វ៉ុន វ៉ិច មានប្រវែង 2500m (សម្រេចបាន100%)។

10. ការងារជីកដាក់លូជ្រុងភ្លោះទំហំ (2.50m x 2.50m) ក្នុងប្រឡាយបារាំងភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ចាប់ពីផ្លូវលេខ 6cc-5 ដល់ព្រលានយន្តហោះមានប្រវែង 500m (សម្រេចបាន 25%)។

11. ការងារជីកដាក់លូមូលទំហំ 1.50m ក្នុងប្រឡាយភូមិព្រៃទា២ និងភូមិព្រៃទា១ សង្កាត់ចោម ចៅទី៣ ចាប់ពីផ្លូវលេខ១ ដល់រោងចក្រឥណ្ឌាមានប្រវែង 750m (សម្រេចបាន60%)។

12. ការងារជីកដាក់លូជ្រុងភ្លោះទំហំ (2m x 2m) នៅក្នុងសាច់ផ្លូវលេខ20k ចាប់ពីចុងចំការ ឪឡឹកដល់ផ្លូវលេខ 105k មានប្រវែង 620m (សម្រេចបាន64%)។

13. ការងារជីកដាក់លូភ្លោះកាត់ផ្លូវទំហំ(2m x 2m) នៅផ្លូវលេខ1998ប្រវែង 13m បាន100%)។

14. ការងារជីកដាក់លូជ្រុងភ្លោះទំហំ (2m x2m) ប្រវែង 12m ក្នុងប្រឡាយចំការឪឡឹកកាត់ទទឹង ផ្លូវលេខ 107KC (ផ្លូវចូលនាយកដ្ឋានផ្គត់ផ្គង់ទឹកស្អាត) នៃក្រសួងអភិវឌ្ឍន៍ជនបទ(សម្រេចបាន 100%)។

## ២. ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ

**ក. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែករួច 100% ចំនួន 5ខ្សែមានប្រវែងសរុប 2,070m និងមានផ្ទៃក្រឡាចំនួន 11, 339 m² មានដូចខាងក្រោមគឺ :**

1. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 68k ភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 56K មានប្រវែង 802m x 6m x 0.15m = 4,812m² (ពីមុនជាបេតុងឬស្សី) សម្រេចបាន100%។

2. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 60K ភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 56k ដល់ផ្លូវលេខ 2011 មានប្រវែង 518m x 6m x 0.15m = 3,108m² (ពីមុនជាបេតុងឬស្សី) សម្រេចបាន100%។

CS Scanned with CamScanner

3. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ262k ភូមិក្បាលដំរី១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ105k ដល់ផ្លូវលេខ 103k មានប្រវែង 156m x 5m x 0.15m = 780m² ( ពីមុនជាផ្លូវដីស ) សម្រេចបាន 100%។

4. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 123k-6A ភូមិត្រពាំងពោធិ៍ សង្កាត់ ចោមចៅទី៣ ចាប់ពីផ្លូវលេខ 123K-8A ដល់ផ្លូវលេខ123KA មានប្រវែង 263m x 5m x 0.15m = 1,315m²( ពីមុនជាផ្លូវគ្រួសក្រហម )សម្រេចបាន100%។

5. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែកផ្លូវលេខ 14TR សហគមន៍ ត្រពាំងអញ្ចាញ១ និង២ សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ 15TR ដល់ផ្លូវក្នុងភូមិមានប្រវែង 331m x 4m x 0.15m ( ពីមុនជាផ្លូវដី ) សម្រេចបាន 100% ។

**ខ. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ពុំទាន់រួច100% មានចំនួន 5ខ្សែមានប្រវែងសរុប 1,566m និងមានផ្ទៃក្រឡា 8,624m² មានដូចខាងក្រោមគឺ៖**

1. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 1E, ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី ១ ចាប់ពីផ្លូវលេខ 6cc-1 ដល់ក្នុងភូមិមានប្រវែង 292m x 6m x 0.15m = 1,752m² ( ពីមុនជាផ្លូវដី ) សម្រេចបាន70%។

2. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ238E, ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី ១ ចាប់ពីផ្លូវលេខ 1031 (ផ្លូវអង្គតាម៉ិញ )ដល់ចំណុច Pko+251 មានប្រវែង 251m x 7m x 0.15m 1,757m² ( ពីមុនជាផ្លូវបេតុងឬស្សី )សម្រេចបាន20%។

3. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិកាកាបចាប់ពីផ្លូវរថភ្លើង ដល់ផ្លូវលេខ 137K ភូមិកាកាប សង្កាត់កាកាបទី២ មានប្រវែង 371m x 5m x 0.15m = 1,825m² ( ពីមុនជាផ្លូវដី ) សម្រេចបាន30%។

4. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិតិក្ខបញ្ញោ សង្កាត់សំរោងក្រោម ចាប់ពី មហាវិថីឈ្នះ-ឈ្នះ ដល់ផ្លូវបំបែកភូមិចំការស្បែង មានប្រវែង 447m x 5m x 0.15m = 2,235m² ( ពីមុន ជាបេតុងឆ្អឹងដែក )សម្រេចបាន40%។

5. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃស្ពឺ សង្កាត់ចោមចៅទី២ ចាប់ពីផ្លូវវត្ត ព្រៃស្ពឺ ដល់ផ្លូវក្នុងផ្លូវក្នុងភូមិមានប្រវែង 205m x 4 <4m x 0.15m ( ពីមុនជាផ្លូវដី )សម្រេចបាន40%។

**គ.ការងារដាក់ជីកលូមូលទំហំ 1.20m នៅផ្លូវលេខ 86k ( ផ្លូវផ្សារព្រៃទា ) ភូមិព្រៃទា១ សង្កាត់ ចោមចៅទី៣ ចាប់ពីផ្លូវលេខ113K ដល់សាលាពន្លឺកុលបុត្រមានប្រវែង 355m សម្រេចបាន100%។**

**៣. <u>ការងារជួសជុលដោយប្រើប្រាស់ថវិកាសប្បុរសជននិងប្រជាពលរដ្ឋ</u>**

1. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 6cc-1B ភូមិត្រពាំងល្វា២ និងភូមិគោកចំបក់ សង្កាត់កាកាបទី១ និងសង្កាត់ចោមចៅទី១ ចាប់ពីផ្លូវលេខ 2004 ដល់ផ្លូវលេខ 1031 ( ផ្លូវអង្គតាម៉ិញ ) មានប្រវែង 588m x 10m x 0.15m = 5,880m² ( ពីមុនជាផ្លូវដី )សម្រេចបាន100%។

CS Scanned with CamScanner

2. ការងារជីកដាក់លូទំហំមុខកាត់ 1m នៅផ្លូវលេខ 6cc-18 ភូមិត្រពាំងល្វា២ សង្កាត់កាកាបទី១ និងភូមិគោកចំបក់ សង្កាត់ចោមចៅទី១ ចាប់ពីផ្លូវលេខ2004 ដល់ផ្លូវលេខ 1031 (ផ្លូវអង្គតាមិញ) មានប្រវែង 588m

សម្រេចបាន100%។

3. ការងារជីកដាក់លូទំហំ 1.50m មានប្រវែង98m នៅមហាវិថីឈូះ-ឈ្មះ ស្ថិតនៅភូមិស្រែរាជ្ជះ និងភូមិតិត្ថបញ្ញោប្រវែង 68m ក្នុងសង្កាត់សំរោងក្រោម សម្រេចបាន100%។

4. ការងារជីកដាក់លូជ្រុងទំហំ 2m x 2m ក្នុងប្រឡាយផ្លូវជាតិលេខ៤ ស្ថិតនៅភូមិអង្គកែវ សង្កាត់ចោមចៅទី៣ មានប្រវែង 16m សម្រេចបាន100%។

5. ការងារជីកដាក់លូមូលទំហំ 0.80m នៅផ្លូវលេខ238k ភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 86K ដល់ផ្លូវលេខ 88K មានប្រវែង 200m សម្រេចបាន100%។

6. ការងារជីកដាក់លូជ្រុង៣ជួរ ទំហំ 2m x 2m ប្រវែង 20m ក្នុងប្រឡាយទួលពង្រទី២ ភូមិទួលពង្រ សង្កាត់ចោមចៅទី១ សម្រេចបាន100%។

**៤.ការងារជួសជុលផ្លូវដោយប្រើថវិកាមូលនិធិសង្កាត់**

1. ការងារជីកដាក់លូទំហំ 0.80m នៅផ្លូវលេខ 109KB ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ ពីផ្លូវសហព័ន្ធរុស្សី ដល់ក្នុងភូមិប្រវែង 317m សម្រេចបាន100%។

2. ការងារជីកដាក់លូទំហំ 0.80m ភូមិត្រពាំងពោធិ៍ និងភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅ ទី៣ មានប្រវែង300m សម្រេចបាន100% ។

3. ការងារជីកដាក់លូទំហំ 0.80m ផ្លូវភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣ មានប្រវែង 300m សម្រេចបាន100%។

4. ការងារជីកដាក់លូទំហំ 0.80m ផ្លូវលេខ 108k ភូមិព្រៃព្រីងខាងត្បូង២ សង្កាត់ចោមចៅទី៣ មានប្រវែង 150m សម្រេចបាន100%។

5. ការងារជីកដាក់លូទំហំ 0.80m នៅផ្លូវលេខ244P-5 ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ប្រវែង 150m សម្រេចបាន100%។

6. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវភូមិត្រពាំងក្រសាំង ប្រវែង 532m x 5m x 0.15m = 2,660 m² ( ពីមុនជាផ្លូវដី ) សម្រេចបាន100%។

7. ការងារជីកដាក់លូទំហំ 0.80m ប្រវែង 447m នៅផ្លូវភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង សម្រេចបាន100%។

8. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវ 2ខ្សែ នៅភូមិត្រពាំងថ្លឹង៣ និងភូមិត្រពាំងថ្លឹង១ មានប្រវែង 696m x 6m x 0.15m = 4,176 m² ( ពីមុនជាផ្លូវដី ) សម្រេចបាន100%។

9. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវ 2ខ្សែ នៅភូមិថ្មគោល និងភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅទី២ មានប្រវែង 532m x 5m x 0.15m = 2,660 m² ( ពីមុនជាផ្លូវដី ) សម្រេចបាន100%។

CS Scanned with CamScanner

10. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវ 2ខ្សែ នៅភូមិព្រៃព្រីងខាងត្បូង២ និងភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ មានប្រវែង 692m x 4.50m x 0.15m = 3,114 $m^2$ ( ពីមុនជាផ្លូវដី )សម្រេចបាន 100%។

11. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវ 4ខ្សែ នៅភូមិប៉ប្រកខាងជើង, ភូមិត្រពាំងល្វា១, ភូមិចំការឪឡឹក១ និងភូមិតាងួន២ សង្កាត់កាកាបទី១ មានប្រវែង 1,383m x 6m x 0.15m = 8,298 $m^2$ ( ពីមុនជាផ្លូវដី )សម្រេចបាន100%។

12. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវ 2ខ្សែ នៅភូមិក្បាលដំរី២ និងភូមិចំការឪឡឹក២ សង្កាត់កាកាបទី២ មានប្រវែង 317m x 4m x 0.15m ( ពីមុនជាផ្លូវដី )សម្រេចបាន100%។

13. ការងារជួសជុលផ្លូវដោយចាក់បេតុងគ្មានសរសៃដែក ផ្លូវ 3ខ្សែ នៅភូមិតិក្ខបញ្ញោ, ភូមិស្រែរាជ្ជៈ និងភូមិអណ្តូងតាអន សង្កាត់សំរោងក្រោម មានប្រវែង 718m x 4m x 0.15m = 2,872 $m^2$ ( ពីមុនជាផ្លូវដី )សម្រេចបាន100%។

អាស្រ័យដូចបានគោរព ជម្រាបជូនខាងលើ សូមលោក ប្រធានមន្ទីរ មេត្តាជ្រាប សេចក្តីរាយការណ៍ និងសុំ មតិដឹកនាំ ដោយក្តីអនុគ្រោះ។

សូមលោក ប្រធានមន្ទីរ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំកុរ ទោស័ក ព.ស២៥៦៣

ពោធិ៍សែនជ័យ, ថ្ងៃទី១៨ ខែធ្នូឆ្នាំ២០១៩

**ប្រធានការិ.សាធារណការ ដឹកជញ្ជូនខណ្ឌពោធិ៍សែនជ័យ**

**ឡូ កែតសុគុណា**

( Tel. 016 323 078 )

CS Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
ការិ.សាធារណការ និងដឹកជញ្ជូនខណ្ឌពោធិ៍សែនជ័យ
លេខ៖ ១៣/២០.របក

<u>សូមគោរពជូន</u>

**លោកអភិបាលនៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ**

<u>កម្មវត្ថុ</u> ៖ លទ្ធផលអនុវត្តការងារ ក្នុងរយៈពេលមួយឆ្នាំ ២០២០ របស់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ។

សេចក្តីដូចមានចែងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន លោកអភិបាល មេត្តាជ្រាបថា៖
ចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០២០ មានលទ្ធផលដូចខាងក្រោម៖

១. **<u>ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលារាជធានីភ្នំពេញ</u>**

ក. ចំនួនផ្លូវបានជួសជុលដោយចាក់បេតុងឆ្អឹងដែករួច 100% ចំនួន 12 ខ្សែមានប្រវែងសរុប 9,643m និងមានផ្ទៃក្រឡាចំនួន 73,197m² មានដូចខាងក្រោម៖

1. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹង ផ្លូវលេខ 20k ចាប់ពីផ្លូវលេខ23k ដល់ផ្លូវ 68k ស្ថិតក្នុងភូមិចំការឪឡឹក២ សង្កាត់ កាកាបទី២ មានប្រវែង 480m x 7m x 0.15m (ពីមុនជាផ្លូវដី)។

2. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹង ផ្លូវលេខ 68k ចាប់ពីផ្លូវលេខ20k ដល់ផ្លូវ 105k ស្ថិតក្នុងភូមិចំការឪឡឹក២ សង្កាត់ កាកាបទី២ មានប្រវែង 140m x 7m x 0.15m (ពីមុនបេតុងឫស្សី)។

3. ការងារជួសជុលផ្លូវចាក់បេតុងឆ្អឹងដែក ផ្លូវលេខ១ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវ សហពន្ធរុស្ស៊ី ដល់ផ្លូវបេតុងមុខរោងចក្រ វ៉ន វ៉ៃ មានប្រវែង 1,255m x 12m x 0.20m (ពីមុនបេតុងឫស្សី)។

4. ការងារជួសជុសផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 87K1 ភូមិព្រៃទា២ និងភូមិ ព្រៃទា១ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ១ ភូមិព្រៃជីសាក់ ដល់ផ្លូវ 88k មានប្រវែង 700m x 8m x 0.20m (ពីមុនជាផ្លូវដី)។

5. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 123kA ចាប់ពីផ្លូវលេខ 88k ដល់ ប្រឡាយត្រពាំងជ្រៃ ស្ថិតនៅក្នុងភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ មានប្រវែង 240m x 7m x 0.15m (ពីមុនជាផ្លូវដី)។

6. ការងារជួសជុលដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 88k ចាប់ពីផ្លូវលេខ 123KA ដល់ផ្លូវលេខ87K1 ស្ថិតនៅក្នុងភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ មានប្រវែង 360m x 7m x 0.15m (ពីមុនជាផ្លូវដី) ។

CS Scanned with CamScanner

7. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 46K₁ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវលេខ 115k ដល់មណ្ឌលកុមារកំព្រា មានប្រវែង 700m x 6m x 0.15m (ពីមុនជាផ្លូវដី) ។

8. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ169k ភូមិខ្វៃ សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ138k មុខវត្តអរុណវត្តី ដល់ព្រំប្រទល់សង្កាត់កំបូល (វត្តតាភេម) មានប្រវែង 1800m x 8m x 0.20m (ពីមុនជាផ្លូវដី) ។

9. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 131K-4A ភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំងចាប់ពីផ្លូវលេខ138k ដល់ផ្លូវ134KB មានប្រវែង 309m x 8m x0.20m (ពីមុនជាផ្លូវដី)

10. ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ131K ភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ138k ដល់ផ្លូវ134KB មានប្រវែង 402mx8mx 0.20m (ពីមុនជាផ្លូវដី) ។

11.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃព្រីងខាងជើង១ និងភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣ មានប្រវែង 1200m x 6m x 0.15m (ពីមុនជាផ្លូវដី)។

12.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវលេខ 5cc ភូមិថ្មគោល១ សង្កាត់ចោមចៅទី២ និងភូមិព្រៃជីសាក់ សង្កាត់ចោមចៅទី៣ ចាប់ពីផ្លូវចោមចៅ ដល់ផ្លូវបេតុងភូមិថ្មគោល១ មានប្រវែង 1,390m x 6m x 0.15m (ពីមុនជាផ្លូវដី) ។

ខ. ចំនួនលូមានទំហំមុខកាត់ ចាប់ពី(0.80m ដល់ 2m x 2m) ដែលបានជួសជុល១០០% មានចំនួន ៩ខ្សែមានប្រវែងសរុប 7,922m មានដូចជា៖

1.ការងារដាក់លូជ្រុងក្នុងសាច់ផ្លូវទំហំ 2m x 2m ប្រវែង480m ភ្លោះស្ថិតនៅផ្លូវលេខ 20k ចាប់ពីផ្លូវលេខ 23k ដល់ផ្លូវលេខ 68k ស្ថិតនៅភូមិចំការឪឡឹក២ សង្កាត់កាកាបទី២។

2.ការងារដាក់លូជ្រុងក្នុងសាច់ផ្លូវទំហំ 2m x 2m ប្រវែង140m ភ្លោះស្ថិតនៅផ្លូវលេខ 68k ចាប់ពីផ្លូវលេខ 20k ដល់ផ្លូវលេខ 105k ស្ថិតនៅភូមិចំការឪឡឹក២ សង្កាត់កាកាបទី២ ។

3.ការងារដាក់លូជ្រុងក្នុងសាច់ផ្លូវទំហំ 2m x 2m ប្រវែង 500m មួយជួរស្ថិតនៅផ្លូវលេខ105kចាប់ពីផ្លូវលេខ 68k ដល់ផ្លូវរថភ្លើង នៅភូមិចំការឪឡឹក២ សង្កាត់កាកាបទី២។

4.ការងារជីកដាក់លូមូលទំហំ1.50m ប្រវែង360m មួយជួរ ស្ថិតនៅផ្លូវលេខ 123KA ចាប់ពីផ្លូវលេខ 88k ដល់ប្រឡាយត្រពាំងជ្រៃ ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅទី៣ និងភូមិត្រពាំងជ្រៃ សង្កាត់កាកាបទី២។

5.ការងារជីកដាក់លូមូលទំហំ1.50m ប្រវែង240m មួយជួរ ស្ថិតនៅផ្លូវលេខ 88K ចាប់ពីផ្លូវលេខ 123kA ដល់ផ្លូវលេខ87k1 ស្ថិតនៅភូមិព្រៃទា១ សង្កាត់ចោមចៅទី៣។

6. ការងារដាក់លូមូលទំហំ 0.80m ប្រវែង1500m នៅភូមិព្រៃជីសាក់ ព្រៃព្រីងខាងជើង១ និងភូមិព្រៃព្រីងខាងជើង២ សង្កាត់ចោមចៅទី៣។

7. ការងារដាក់លូមូលទំហំ 1.50m ប្រវែង650m មួយជួរ នៅផ្លូវលេខ 87k₁ ចាប់ពីផ្លូវលេខ១ ភូមិជីសាក់ ដល់ផ្លូវលេខ 88k ស្ថិតនៅភូមិព្រៃទា១ សង្កាត់ចោមចៅទី៣។

8. ការងារដាក់លូមូលទំហំ 1.20m ប្រវែង 1,390m មួយជួរនៅផ្លូវលេខ 5cc ភូមិថ្មគោល១ សង្កាត់ចោមចៅទី២ ចាប់ពីផ្លូវចោមចៅដល់លូ ផ្លូវលេខ8cc ។

Scanned with CamScanner

9. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 2600m សងខាងផ្លូវភូមិព្រៃល្វា ចាប់ពីមហាវិថីចោមចៅ ដល់ផ្លូវលេខ 105cc ស្ថិតក្នុងសង្កាត់ចោមចៅទី២។

10. ការងារដាក់លូមូលទំហំ 1.50m ប្រវែង 12m ចំនួន 3 ជួរនិង 50m ចំនួន 2 ជួរ ស្ថិតនៅមហាវិថីឈ្មះឈ្មះ ក្នុងភូមិត្រពាំងធ្នង់ ភូមិស្រែរាជ្ជៈ និងភូមិព្រៃពពេល សង្កាត់សំរោងក្រោម។

## ២. ការងារស្ថាបនា-ជួសជុលដោយប្រើប្រាស់ថវិកាសាលាខណ្ឌ

ក. ការងារជួសជុលដាក់បណ្ដាញលូទំហំមុខកាត់0.80m រួច 100% ចំនួន 6ខ្សែមានប្រវែងសរុប 1,420m មានដូចខាងក្រោមគឺ :

1. ការងារជីកដាក់លូមូលទំហំ 0.80m ប្រវែង 173m នៅផ្លូវលេខ 2011 ភូមិតាងួន១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 2009(ផ្លូវក្រុងខ្មែរ) ដល់ផ្លូវរថភ្លើង។

2. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 187m នៅផ្លូវលេខ 2002 ភូមិតាងួន១ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 2011 ដល់ $Pk_0 + 187$។

3. ការងារដាក់លូមូលទំហំ 0.80m ប្រវែង 440m នៅផ្លូវលេខ 2007 ចាប់ពីមហាវិថីសហព័ន្ធរុស្ស៊ី ដល់ផ្លូវលេខ 2002 ស្ថិតនៅភូមិតាងួន១ សង្កាត់កាកាបទី១ ។

4. ការងារដាក់លូមូលទំហំ 0.80m ប្រវែង110m នៅផ្លូវលេខ 142k ចាប់ពីផ្លូវលេខ 167k ដល់ផ្លូវលេខ140k ភូមិជម្រុក សង្កាត់ត្រពាំងក្រសាំង ។

5. ការងារដាក់លូមូលទំហំ 0.80m ប្រវែង110m នៅផ្លូវលេខ 140k ចាប់ពីផ្លូវលេខ 142k ដល់ផ្លូវលេខ155kភូមិជម្រុក សង្កាត់ត្រពាំងក្រសាំង ។

6. ការងារដាក់លូមូលទំហំ 0.80m ប្រវែង370m នៅផ្លូវ 155k ចាប់ពីផ្លូវលេខ140k ដល់មហាវិថីឈ្មះឈ្មះ ភូមិជម្រុក សង្កាត់ត្រពាំងក្រសាំង ។

## ៣. ការងារជួសជុលដោយប្រើប្រាស់ថវិកាសប្បុរសជននិងប្រជាពលរដ្ឋ

1.ការងារដាក់លូមូលទំហំ 1.50m ប្រវែង139m ចំនួន 3ជួរ និង 148m ចំនួន2ជួរ ស្ថិតនៅមហាវិថីឈ្មះ-ឈ្មះ ភូមិត្រពាំងធ្នង់និងភូមិស្រែរាជ្ជៈ សង្កាត់សំរោងក្រោម ។

2.ការងារដាក់លូជ្រុងទំហំ 2m x 2m ប្រវែង11m ភ្លោះ នៅផ្លូវជាតិលេខ៤ ភូមិអង្គកែវ (នៅទល់មុខនាយកដ្ឋាន ផ្លូវថ្នល់ក្រសួងសាធារណការ និងដឹកជញ្ជូន) សង្កាត់ចោមចៅទី៣។

## ៤.ការងារជួសជុលផ្លូវដោយប្រើថវិកាមូលនិធិសង្កាត់

1.ការងារដាក់លូមូលទំហំ 0.60m ប្រវែង408m ចំនួន 1ជួរ ស្ថិតនៅផ្លូវលេខ 62kចាប់ពីផ្លូវលេខ103K ដល់ផ្លូវលេខ56k ស្ថិតនៅភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ ។

2.ការងារដាក់លូមូលទំហំ 0.60m ប្រវែង459m ចំនួន 1ជួរ ស្ថិតនៅផ្លូវ ភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ។

3.ការងារដាក់លូមូលទំហំ 0.60m ប្រវែង300m ចំនួន 1ជួរ ស្ថិតនៅផ្លូវភូមិព្រៃល្វ សង្កាត់ចោមចៅទី២ ។

4.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិសាមគ្គី៥-៦ សង្កាត់ត្រពាំងក្រសាំង មានប្រវែង 317m x 6m x 0.15m (ពីមុនជាផ្លូវដី)។

CS Scanned with CamScanner

5.ការងារជូសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិអក្សរ សង្កាត់ត្រពាំងក្រសាំង មានប្រវែង 300 x 5m x 0.15m (ពីមុនជាផ្លូវដី)។

6.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិសាមគ្គី សង្កាត់ត្រពាំងក្រសាំង មានប្រវែង 310 x 5m x 0.15m (ពីមុនជាផ្លូវដី)។

7.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិគោកចំបក់ សង្កាត់ចោមចៅទី១ មានប្រវែង 789 x 5m x 0.15m (ពីមុនជាផ្លូវដី)។

8.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ស្ថិតនៅផ្លូវលេខ 62kចាប់ពីផ្លូវលេខ103K ដល់ផ្លូវលេខ56k ស្ថិតនៅភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ មានប្រវែង 408m x 5m x 0.15m (ពីមុនជាផ្លូវដី)។

9.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃព្រីងខាងត្បូង២ សង្កាត់ចោមចៅទី៣ មានប្រវែង 600m x 5m x 0.15m (ពីមុនជាផ្លូវដី)។

10.ការងារជួសជុលផ្លូវដោយចាក់បេតុងឆ្អឹងដែក ផ្លូវភូមិព្រៃទា២សង្កាត់ចោមចៅទី៣ មានប្រវែង 365m x 5m x 0.15m (ពីមុនជាផ្លូវដី)។

អាស្រ័យដូចបានគោរព ជម្រាបជូនខាងលើ សូមលោក អភិបាល នៃគណៈអភិបាលខណ្ឌ មេត្តាជ្រាប សេចក្តីរាយការណ៍ និងសុំមតិដឹកនាំ ដោយក្តីអនុគ្រោះ។

សូម**លោក អភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃ ចន្ទ ១៤ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
ពោធិ៍សែនជ័យ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២០
**ប្រធានការិ.សាធារណការ ដឹកជញ្ជូន អនាម័យ**
**បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ**

**ទូ កែតសុគុណា**
(Tel. 016 323 078)

CS Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ
រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
ការិ.សាធារណការ ដឹកជញ្ជូន អនាម័យ
បរិស្ថាន និងសណ្ដាប់ធ្នាប់សាធារណៈ
លេខ៖ ១៧/២១ របក

## សូមគោរពជូន

### លោកអភិបាលនៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ

**<u>កម្មវត្ថុ</u>៖ របាយការណ៍ប្រចាំឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២**

សេចក្ដីដូចមានចែងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន លោកប្រធានមន្ទីរមេត្តាជ្រាបថា៖ សកម្មភាពការងារដែលបានអនុវត្តក្នុងខណ្ឌពោធិ៍សែនជ័យរាជធានីភ្នំពេញ មានលទ្ធផលដូចខាងក្រោម៖

I. **<u>ការងារសាធារណការ</u>**

1.ការងារជីកដាក់លូមូលទំហំ1m អមសងខាងផ្លូវ ភូមិព្រៃល្វា សង្កាត់ចោមចៅទី២ មានប្រវែង 1,300m ចាប់ពីផ្លូវចោមចៅដល់ផ្លូវ បំបែកឆ្ពោះទៅរោងចក្រ តុងហ្គា សម្រេចបាន 100%។

2.ការងារដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ262k ភូមិចំការឪឡឹក១ និងភូមិក្បាលដំរី១ ស្ថិតនៅក្នុងសង្កាត់កាកាប ប្រវែង362m ចាប់ពីផ្លូវលេខ 105k ដល់ផ្លូវលេខ 97k សម្រេចបាន 100% ។

3. ការងារដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 102k ភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ចាប់ពីផ្លូវ 105k ដល់ផ្លូវលេខ 107KA មានប្រវែង 230m សម្រេចបាន 100% ។

4.ការជីកដាក់លូទំហំ 0.80m នៅភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង ចាប់ពីមហាវិថីឈ្នះ-ឈ្នះ ដល់ផ្លូវ167K មានប្រវែង 620m សម្រេចបាន 100% ។

5. ការងារជួសជុលផ្លូវដោយចាក់បេតុងផ្លឹងដែក ផ្លូវភូមិព្រៃល្វា សង្កាត់ចោមចៅទី២ មានប្រវែង 1550m x 6m x 0.15m សម្រេចបានលទ្ធផល 100% ។

6.ការងារជួសជុលផ្លូវដោយចាក់ក្រាលបេតុងផ្លឹងដែក ផ្លូវលេខ 71K ភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 60K ដល់ផ្លូវលេខ 71K មានប្រវែង 300m x 5m x 0.15m សម្រេចបានលទ្ធផល 100%។

7.ការងារជួសជុលផ្លូវដោយចាក់ក្រាលបេតុងផ្លឹងដែក ផ្លូវលេខ 83K ភូមិតាងួន២ សង្កាត់កាកាបទី១ ចាប់ពីផ្លូវលេខ 76K ដល់ផ្លូវរត់ភ្លើង មានប្រវែង 195m x 5m x 0.15m សម្រេចបានលទ្ធផល 100%។

8.ការងារសាងសង់ស្ពានចំនួន ៧ អំពីបេតុងស្ថិតនៅប្រឡាយខ្វូលពង្រទី១ ក្នុងភូមិខ្វូលពង្រ សង្កាត់ចោមចៅទី១ ដែលមានទំហំ 17m x 15m ចំនួន ០១,ទំហំ 10m x 10m ចំនួន ០១, និងទំហំ 8m x 8m ចំនួន ០៥ ដែលជារួម សម្រេចបានលទ្ធផល 100% ។

9.ការងារដាក់លូមូលទំហំ មុខកាត់ 1,20m មានប្រវែង 584m ស្ថិតនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ចាប់ពីផ្លូវលេខ 134KB ដល់ប្រឡាយផ្លូវរថភ្លើង សម្រេចបាន 100% ។

10.ការងារបុកស៊ីផាយ នៅប្រឡាយខ្វូលពង្រទី១ ប្រវែង 300m នៅភូមិខ្វូលពង្រ សង្កាត់ចោមចៅទី១ សម្រេចបានលទ្ធផល 40% ។

11.ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 437k ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវបេតុងលេខ 432k ដល់ក្នុងភូមិប្រវែង 110m សំរេចបានលទ្ធផល 100%។

CS Scanned with CamScanner

12.ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ268k ភូមិចំការឪឡឹក២,ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវ 105k ដល់ភូមិព្រៃសាលា ប្រវែង 998m សម្រេចលទ្ធផលបាន 100%។

13.ការងារជីកដាក់បំពង់លូជ័រមូលទំហំមុខកាត់1m នៅផ្លូវលេខ1080(ផ្លូវចូលវត្តភ្លៀត)ភូមិស្រែរាជ្ជៈ, ភូមិអណ្តូងតាអន សង្កាត់សំរោងក្រោម ចាប់ពីមហាវិថីឈ្នះឈ្នះ ដល់ ផ្លូវចូលភូមិព្រៃពពេល(ព្រំប្រទល់ខណ្ឌកំបូល) មានប្រវែង 1400m x 2 = 2800m សម្រេចលទ្ធផលបាន 14%។

14.ការងារថ្ពលថុលពង្រីកផ្លូវដោយចាក់បេតុងផ្អឹងដែក ផ្លូវលេខ 1080(ផ្លូវចូលវត្តភ្លៀត)ភូមស្រែរាជ្ជៈ, ភូមិអណ្តូងតាអន សង្កាត់សំរោងក្រោម ចាប់ពីមហាវិថីឈ្នះឈ្នះ ដល់ព្រំប្រទល់ខណ្ឌកំបូលមានប្រវែង 1400m x 12m x 0.20m សម្រេចលទ្ធផលបាន 10%។

15.ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 438k ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវបេតុងលេខ 432k ដល់ក្នុងភូមិប្រវែង 110m សំរេចបានលទ្ធផល 100%។

16.ការងារជីកដាក់លូមូលទំហំមុខកាត់ 0.80m នៅផ្លូវលេខ 436k ភូមិព្រៃសាលា សង្កាត់កាកាបទី២ ចាប់ពីផ្លូវបេតុងលេខ 432k ដល់ក្នុងភូមិប្រវែង 100m សំរេចបានលទ្ធផល 100%។

## II. បញ្ហាប្រឈម និង ដំណោះស្រាយ

CS Scanned with CamScanner

### ១. ការិយាល័យ អន្តរាគមន៍ទាញ